# លទ្ធផលលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនៅ ២៤ មណ្ឌល (ខេត្ត-រាជធានី)



អភិបាលកិច្ចល្អ



ការលើកស្ទួយ វិស័យកសិកម្ម



ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត



ការអភិវឌ្ឍវិស័យឯកជន និងការងារ



ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
កម្មវិធីនយោបាយ
របស់រាជរដ្ឋាភិបាល នៃនីតិកាលទី ៤ នៃរដ្ឋសភា
( ២៥-កញ្ញា-២០០៨ )

បញ្ជីរាយនាម សមាជិករាជរដ្ឋាភិបាល
- នាយករដ្ឋមន្ត្រី
- ឧបនាយករដ្ឋមន្ត្រី. ទេសរដ្ឋមន្ត្រី
- រដ្ឋមន្ត្រី
- រដ្ឋលេខាធិការ
- អនុរដ្ឋលេខាធិការ

២៥-កញ្ញា-ឆ្នាំ២០០៨


រាជរដ្ឋាភិបាលកម្ពុជា

សន្ទរកថា
របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ស្តីពី
<<យុទ្ធសាស្ត្រចតុកោណ>>
ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា
ដំណាក់កាលទី២

ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ
សំរាប់នីតិកាលទី ៤ នៃរដ្ឋសភា
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨

ខុមហ្វ្រែល COMFREL

ផលិតដោយ ខុមហ្វ្រែល ខែ មករា ឆ្នាំ ២០១០

# លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោត

# ក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនៅ ២៤មណ្ឌល (ខេត្ត-រាជធានី)

# មាតិកា


១. សេចក្តីផ្តើម ........ ១

២. សង្ខេបវិធីសាស្ត្រនិងគោលបំណង ........ ២

២.១. ការពន្យល់ពាក្យគន្លឹះ ........ ៣

៣. លទ្ធផលនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពដែលបានកំណត់ដោយម្ចាស់ឆ្នោត ........ ៤

៣.១. លក្ខខណ្ឌសន្ទស្សន៍ក្នុងវិស័យកសិកម្ម ........ ៤

៣.១.១. ការលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី១ នៃចតុកោណទី១) ........ ៥

៣.១.២. កំណែទម្រង់ដីធ្លី និងការបោសសំអាតមីន : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី២ នៃចតុកោណទី១) ........ ៦

៣.១.៣. កំណែទម្រង់ជលផល: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី៣ នៃចតុកោណទី១) ........ ៦

៣.១.៤. កំណែទម្រង់ព្រៃឈើ: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី៤ នៃចតុកោណទី១) ........ ៧

៣.២. លក្ខខណ្ឌសន្ទស្សន៍ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........ ៧

៣.២.១. ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី១ នៃចតុកោណទី២) ........ ៨

៣.២.២. ការគ្រប់គ្រងធានធានទឹក និងប្រព័ន្ធធារាសាស្ត្រ :លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី២ នៃចតុកោណទី ២:) ........ ៨

៣.២.៣. ការអភិវឌ្ឍវិស័យថាមពល: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី៣ នៃ ចតុកោណទី២) .. ៩

៣.២.៤. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី៤ នៃចតុកោណទី២) ........ ៩

៣.៣. លក្ខខណ្ឌសន្ទស្សន៍ក្នុងវិស័យឯកជន និងការងារ ........ ៩

៣.៣.១. ការពង្រឹងវិស័យឯកជន និងការទាក់ទាញវិនិយោគ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយ ម្ចាស់ឆ្នោត ( មុំទី១ នៃចតុកោណទី ៣) ........ ៩

៣.៣.២. ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរ: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី២ នៃចតុកោណទី ៣) ........ ១០

៣.៣.៣. ការលើកស្ទួយ សហគ្រាសធុនតូច និងមធ្យម: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី៣ នៃចតុកោណទី ៣) ........ ១០

៣.៣.៤. ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី៤ នៃចតុកោណទី ៣) ........ ១០

៣.៤. លក្ខខណ្ឌសន្ទស្សន៍ក្នុងវិស័យកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស ........ ១១

៣.៤.១. ការពង្រឹងគុណភាពវិស័យអប់រំ: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី១ នៃចតុកោណទី ៤) ........ ១១

៣.៤.២. ការលើកកម្ពស់សេវាសុខាភិបាល: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី២ នៃចតុកោណទី ៤) ........ ១២

៣.៤.៣. ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី៣ នៃចតុកោណទី ៤) ........ ១២

៣.៤.៤. ការអនុវត្តគោលនយោបាយជាតិប្រជាជន: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( មុំទី៤ នៃចតុកោណទី ៤) ........ ១៣

៣.៥. លក្ខខណ្ឌសន្ទស្សន៍ក្នុងវិស័យអភិបាលកិច្ចល្អ ........ ១៣

៣.៥.១. ការប្រយុទ្ធប្រឆាំងអំពើពុករលួយ: លក្ខខណ្ឌសន្ទស្សនបអាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( ចំនុចទី១ នៃអភិបាលកិច្ចល្អ) ........ ១៣

៣.៥.២. កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( ចំនុចទី២ នៃអភិបាលកិច្ចល្អ) ........ ១៤

៣.៥.៣. កំណែទម្រង់រដ្ឋបាលសាធារណៈ: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( ចំនុចទី៣ នៃអភិបាលកិច្ចល្អ) ........ ១៥

៣.៥.៤. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត ( ចំនុចទី៤ នៃអភិបាលកិច្ចល្អ) ........ ១៥

៣.៦. សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់: លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ ឆ្នោត.... ១៥

៤. ការគាំទ្ររបស់មន្ត្រីជាប់ឆ្នោតក្នុងការជម្រុញការអនុវត្តលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងមណ្ឌល ( ខេត្ត-រាជធានី) របស់ខ្លួន ........ ១៥

ឧបសម្ព័ន្ធ ក: លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពតាមមណ្ឌល ( ខេត្ត-រាជធានី) ........ ១៨

ក.១. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកណ្តាល ........ ១៨

ក.២. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ចាម ........ ១៩

ក.៣. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ឆ្នាំង ........ ២០

ក.៤. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ធំ ........ ២១

ក.៥. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ស្ពឺ ........ ២២

ក.៦. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពត ........ ២៣

ក.៧. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកែប ........ ២៤

ក.៨. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកោះកុង......២៥
ក.៩. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តក្រចេះ......២៦
ក.១០. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តតាកែវ......២៧
ក.១១. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តបន្ទាយមានជ័យ......២៨
ក.១២. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តប៉ៃលិន......២៩
ក.១៣. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តបាត់ដំបង......៣០
ក.១៤. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រៃវែង......៣១
ក.១៥. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តពោធិ៍សាត់......៣២
ក.១៦. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រះវិហារ......៣៣
ក.១៧. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រះសីហនុ......៣៥
ក.១៨. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងរាជធានីភ្នំពេញ......៣៦
ក.១៩. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តមណ្ឌលគិរី......៣៧
ក.២០. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តរតនគិរី......៣៨
ក.២១. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តសៀមរាប......៣៩
ក.២២. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តស្ទឹងត្រែង......៤០
ក.២៣. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តស្វាយរៀង......៤១
ក.២៤. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តឧត្តរមានជ័យ......៤២
ឧបសម្ព័ន្ធ ខៈ វិធីសាស្ត្រ......៤៣
១. ដំណើរការសិក្ខាសាលា......៤៣
២. ទីកន្លែងសិក្ខាសាលា និងពេលវេលា......៤៧
៣. អ្នកចូលរួម......៤៨
៤.ការផ្សព្វផ្សាយរបាយការណ៍ស្តីពីលទ្ធផលដល់តំណាងរាស្ត្រ គណបក្សនយោបាយ និងសាធារណជន......៤៨
៥.ការតាមដាន......៤៩
៦. ការពិភាក្សាតាមរយៈកម្មវិធីវិទ្យុ......៤៩
ឧបសម្ព័ន្ធ គៈ អង្គការ សមាគម សហការជាមួយខុមហ្វ្រែលរៀបចំសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់
លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពតាមខេត្ត-រាជធានី......៥០

# របាយការណ៍ស្តីពីលទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោត
# ក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនៅ២៤មណ្ឌល (ខេត្ត-រាជធានី)

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៤ បន្ទាប់ពីបានទទួលការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីសមាជិករដ្ឋសភានីតិកាលទី៤ មក រាជរដ្ឋាភិបាលបានចេញនូវកម្មវិធីនយោបាយដើម្បីពន្លឿនកិច្ចអភិវឌ្ឍ និងនីតិរដ្ឋនៅកម្ពុជា និងបានចេញនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ដើម្បីអនុវត្តកម្មវិធីនយោបាយ។

ទោះបីយ៉ាងណាទាំងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលមានលក្ខណៈទូលំទូលាយ និងទូទៅ ជាជាងការផ្តោតទៅលើមណ្ឌលមួយៗ និងមិនមានសូចនាករច្បាស់លាស់ដែលធ្វើឱ្យម្ចាស់ឆ្នោតពិបាកក្នុងការវាយតម្លៃ និងតាមដានពីការអនុវត្តកម្មវិធីនយាបាយរបស់រាជរដ្ឋាភិបាល។

ដោយយល់ឃើញពីតម្រូវការនេះ ហើយកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ "ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព" គ្របដណ្តប់ស្ទើរគ្រប់វិស័យ (ប្រសិនបើមិនគ្រប់វិស័យ) ខុមហ្វ្រែលមានបំណងឱ្យម្ចាស់ឆ្នោតក្នុងមណ្ឌល (ខេត្ត-រាជធានី) គឺជាអ្នកកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពសម្រាប់ការអភិវឌ្ឍក្នុងតំបន់របស់ខ្លួនដើម្បីជម្រាបជូនដល់អ្នកតំណាងរាស្ត្រ រាជរដ្ឋាភិបាល ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី និងស្ថាប័នពាក់ព័ន្ធនានា។

ការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព គឺជាការកំណត់វិស័យអាទិភាពដែលមានលក្ខណៈច្បាស់លាស់ ហើយអាចវាស់វែង ឬតាមដានពិនិត្យបាន។ **លក្ខខណ្ឌសន្ទស្សន៍គឺ សំដៅទៅលើការអនុវត្ត ឬសន្យាអ្វីមួយដែលឆ្លើយសំណួរទាំងនេះ គឺ ធ្វើអ្វី? ធ្វើនៅកន្លែងណា? ធ្វើចំនួនប៉ុន្មាន? ធ្វើដោយរបៀបណា? និងសម្រេចបាននៅពេលណា?**

ការតាក់តែងលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនឹងជួយសម្រួលឱ្យម្ចាស់ឆ្នោតធ្វើការវាយតម្លៃទៅលើការបំពេញរបស់អ្នកតំណាងរាស្ត្រ រាជរដ្ឋាភិបាល ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី និងស្ថាប័នពាក់ព័ន្ធនានា។

ហេតុដូចនេះ **ខុមហ្វ្រែល**ក្រោមការឧបត្ថម្ភពីម្ចាស់ជំនួយមួយចំនួន ក៏បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល សមាគម សហគមន៍នៅតាមខេត្ត-រាជធានីរៀបចំសិក្ខាសាលានៅគ្រប់មណ្ឌល (ខេត្ត-រាជធានី) ដើម្បីឱ្យម្ចាស់ឆ្នោតក្នុងមណ្ឌលជួបជុំគ្នាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងមណ្ឌលរបស់ខ្លួន។

នៅក្នុងសិក្ខាសាលាទាំង ២៤ ខេត្ត-រាជធានីនេះ មានវត្តមានអាជ្ញាធរថ្នាក់ខេត្តជា អភិបាលខេត្ត អភិបាលរងខេត្ត និងជាមន្ត្រីសាលាខេត្តចំនួន **២០រូប** ដើម្បីបើកសិក្ខាសាលា និងបានគាំទ្រសិក្ខាសាលានេះ ហើយមានតំណាងរាស្ត្រមកពីគ្រប់គណបក្ស

នយោបាយសរុបចំនួន **១៥រូប** និងសមាជិកក្រុមប្រឹក្សាខេត្ត-រាជធានីចំនួន **២១រូប** បានចូលរួមដើម្បីទទួលយកលទ្ធផលដោយផ្ទាល់ដៃ។

ដោយឡែក អ្នកចូលរួមសិក្ខាសាលា (សិក្ខាកាម) សរុបក្នុង២៤ ខេត្ត-រាជធានី មានចំនួន**២.១០៤ នាក់** ក្នុងនោះមានស្ត្រី **៣៥%**។ សិក្ខាកាមចូលរួមជាប្រជាពលរដ្ឋធម្មតា (កសិករ កម្មករ សិស្ស និស្សិត) មានចំនួន**៩៤៦នាក់** អ្នកចូលរួម ជាប្រធាន/សមាជិកសហគមន៍មានចំនួន**៤៦៣នាក់** អ្នកចូលរួមជាមេភូមិ និងអនុប្រធានភូមិមានចំនួន**៦៧នាក់** អ្នកចូលរួម ជាប្រធាន/សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ និងមកពីគណបក្សនយោបាយមានចំនួន**៩៩នាក់** អ្នកចូលរួមជាមន្ត្រីរាជការ (គ្រូបង្រៀន គ្រូពេទ្យ បុគ្គលិកតាមមន្ទីរខេត្ត ប៉ូលីស) មានចំនួន**១៧៧នាក់** អ្នកចូលរួមមកពីសមាគម អង្គការមិនមែន រដ្ឋាភិបាលមានចំនួន**៣៨៤នាក់** និងអ្នកសារព័ត៌មានចំនួន**៨នាក់**។

សិក្ខាសាលានេះគឺជាផ្នែកមួយ នៃគម្រោងរបស់ខុមហ្វ្រែលក្នុងការឃ្លាំមើលការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ ហើយសិក្ខាសាលានេះត្រូវបានធ្វើឡើងទូទាំង២៤ ខេត្ត-រាជធានី។

## ២. សង្ខេបវិធីសាស្ត្រ[១] និងគោលបំណង

សិក្ខាសាលានេះត្រូវបានធ្វើឡើងនៅ ២៤ ខេត្ត-រាជធានី ដោយមានអ្នកចូលរួមចន្លោះពី ៩០ ទៅ ១១០ នាក់ ដែលមកពីស្រុកផ្សេងៗគ្នាក្នុងមណ្ឌលរបស់ខ្លួន។ អ្នកចូលរួមជាម្ចាស់ឆ្នោតដែលតំណាងឱ្យសហគមន៍នានា អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ ។ល។ ម្ចាស់ឆ្នោតដែលបានចូលរួមត្រូវបានបែងចែកជាក្រុមដើម្បីពិភាក្សាទៅលើលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពសម្រាប់មណ្ឌលរបស់ខ្លួន។ បន្ទាប់ពីការកំណត់ និងជ្រើសរើសលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពរួចហើយ សិក្ខាសាលានេះក៏មានការចូលរួមពីមន្ត្រីជាប់ឆ្នោត (តំណាងរាស្ត្រ និងក្រុមប្រឹក្សាខេត្ត-រាជធានី) ដើម្បីទទួលយកលទ្ធផលនៃលក្ខខណ្ឌសន្ទស្សន៍ដែលបានកំណត់ដោយម្ចាស់ឆ្នោត។

សិក្ខាសាលានេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត-រាជធានី) របស់ខ្លួន

[១] វិធីសាស្ត្រពិស្តារមាននៅក្នុងឧបសម្ព័ន្ធ ខ។

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ ។

## ២.១. ការពន្យល់ពាក្យគន្លឹះប្រើប្រាស់ក្នុងរបាយការណ៍នេះ

**កម្មវិធីនយោបាយរាជរដ្ឋាភិបាលៈ** ជាការសន្យារបស់រាជរដ្ឋាភិបាល ។

(របៀប ឬបែបផែន ឬព្រឹត្តការណ៍ ឬសកម្មភាពនានាដែលរាជរដ្ឋាភិបាលបានរៀបចំ ឬរៀបផែនការទុកជាស្រេចក្នុងការគ្រប់គ្រង/ដឹកនាំប្រទេស ។)

**យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី ២ :** ជាឧបករណ៍ដ៏សំខាន់សំរាប់ទ្រទ្រង់ការអនុវត្ត " កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល" ។

**វិស័យអាទិភាពៈ** ផ្នែក/អ្វីមួយ ឬច្រើនៗ (អប់រំ តុលាការ សេដ្ឋកិច្ច ពាណិជ្ជកម្ម កាត់ដេរ......) ដែលសំខាន់ជាងគេ ហើយចាំបាច់ត្រូវធ្វើអោយបានមុនផ្នែក ឬអ្វីមួយផ្សេងទៀត ។ ឧ. វិស័យអប់រំមានអាទិភាពជាងពាណិជ្ជកម្ម ។

**សូចនាករច្បាស់លាស់ៈ** គឺជារង្វាស់/ឬខ្នាត ឬជាអ្វីមួយដែលមានលក្ខណៈច្បាស់លាស់ ហើយអាចវាស់វែង ឬតាមដានពិនិត្យបាន ។ សូចនាករក្នុងន័យនេះគឺសំដៅទៅលើការអនុវត្ត ឬសន្យាអ្វីមួយដែលឆ្លើយសំណួរទាំងនេះគឺ ធ្វើអ្វី? ធ្វើនៅកន្លែងណា? ធ្វើចំនួនប៉ុន្មាន? ធ្វើដោយរបៀបណា? និងសម្រេចបាននៅពេលណា? ឧ. ការសន្យាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយអោយបានត្រឹមចុងឆ្នាំ ២០០៥ ។ ការបង្កើនប្រាក់ខែសម្រាប់មន្ត្រីរាជការអោយបាន ២០% ជារៀងរាល់ឆ្នាំ ។

**លក្ខខណ្ឌសន្ទស្សន៍ៈ** គឺជាការសន្យាមានសូចនាករច្បាស់លាស់ និងមានវិធីសាស្ត្រនៃការអនុវត្តដោយរួមទាំងគុណភាពនៃការសន្យា នោះផងដែរ ។

**ការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្ត-រាជធានីៈ** គឺជាការតាក់តែង ឬកំណត់ថា ផ្នែកអ្វី ឬសកម្មភាពអ្វីដែលខេត្ត-រាជធានីរបស់ខ្លួនត្រូវការជាចាំបាច់ ហើយផ្នែក ឬសកម្មភាពនេះត្រូវធ្វើនៅ **កន្លែងណា ចំនួនប៉ុន្មាន គុណភាពយ៉ាងណា ហើយត្រូវបញ្ចប់អោយបាន នៅពេលណា.....** ។

## ៣. លទ្ធផលនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពដែលបានកំណត់ដោយម្ចាស់ឆ្នោត

លទ្ធផលខាងក្រោមគឺជាការសង្ខេបទៅលើវិស័យអាទិភាពដែលបានកំណត់ដោយម្ចាស់ឆ្នោតនៅក្នុងសិក្ខាសាលាទាំង ២៤ ខេត្ត-រាជធានី ទៅតាម "កម្មវិធីនយោបាយ" និង "យុទ្ធសាស្ត្រចតុកោណ" ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភា។

ដោយឡែករបាយការណ៍ពិស្តារនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពដែលមានកំណត់សកម្មភាព ទីកន្លែង ពេលវេលា ចំនួន និងគុណភាពជាក់លាក់នៅតាមមណ្ឌល (ខេត្ត-រាជធានី) នីមួយៗដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងមណ្ឌល (ខេត្ត-រាជធានី) នីមួយមានភ្ជាប់ជាមួយនៅក្នុងឧបសម្ព័ន្ធ "ក"។

### ៣.១. លក្ខខណ្ឌសន្ទស្សន៍ក្នុងវិស័យកសិកម្ម

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ ក៏បានចាត់ទុកការលើកស្ទួយវិស័យកសិកម្មជាវិស័យអាទិភាពរបស់ខ្លួននៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់ខ្លួនផងដែរ។ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលក៏បានដាក់ចេញគោលនយោបាយក្នុងវិស័យកសិកម្មផងដែរដែលក្នុងនោះរួមមាន **"ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន" "ការគ្រប់គ្រងធនធានទឹក" "កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន"**។ ជាងនេះទៅទៀត ការលើកស្ទួយវិស័យកសិកម្មគឺជាចតុកោណទី១ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល។ ចតុកោណទី ១ ក៏បានបែងចែកជាមុំចំនួន ៤ ទៀត រួមមានមុំទី ១ **"ការលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម"** មុំទី២ **"កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន"** មុំទី៣ **"កំណែទម្រង់ជលផល"** និងមុំទី៤ **"កំណែទម្រង់ព្រៃឈើ"**។

ម្ចាស់ឆ្នោតទាំង ២៤ ខេត្ត-រាជធានីដែលបានចូលរួមសិក្ខាសាលាសុទ្ធតែបានកំណត់ការលើកស្ទួយវិស័យកសិកម្មថា ជាវិស័យអាទិភាពសម្រាប់មណ្ឌលរបស់ខ្លួន។ ទោះបីយ៉ាងណា ការកំណត់វិស័យអាទិភាពរបស់ម្ចាស់ឆ្នោតទាក់ទងនឹងវិស័យកសិកម្មគឺភាគច្រើនមានកំណត់ក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាល។ ក៏ប៉ុន្តែអ្វីដែលសំខាន់ និងខុសគ្នានោះគឺថា ម្ចាស់ឆ្នោតបានកំណត់ពីសកម្មភាពនៃវិស័យអាទិភាពសម្រាប់មណ្ឌលរបស់ខ្លួនច្បាស់លាស់ និងមានលក្ខខណ្ឌសន្ទស្សន៍។

វិស័យអាទិភាពទាក់ទងនឹងកសិកម្មដែលត្រូវបានកំណត់ដោយម្ចាស់ឆ្នោតមានដូចខាងក្រោម (សូមមើលឧបសម្ព័ន្ធ ក សម្រាប់លក្ខខណ្ឌសន្ទស្សន៍ពិស្តារសម្រាប់មណ្ឌលខេត្ត-រាជធានី នីមួយៗ) :

### ៣.១.១. ការលើកកម្ពស់ផលិតភាព និងពិពិធភាពូបនីយកម្មកសិកម្ម : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី១ នៃចតុកោណទី១)

- *ផ្តល់វគ្គបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្ម (ការធ្វើស្រែ និងដាំបន្លែ និងការចិញ្ចឹមសត្វ) ដល់ប្រជាកសិករ* ត្រូវបានម្ចាស់ឆ្នោតចំនួន ១៦ ខេត្ត ( កោះកុង កំពង់ឆ្នាំង កែប សៀមរាប តាកែវ ប៉ៃលិន ស្វាយរៀង កណ្តាល ព្រះសីហនុ ឧត្តរមានជ័យ កំពង់ចាម ស្ទឹងត្រែង មណ្ឌលគីរី រតនគីរី កំពង់ធំ ព្រៃវែង) កំណត់ថា ជាផ្នែកមួយនៃវិស័យអាទិភាពរបស់ខ្លួន ហើយដែលត្រូវអនុវត្តពីឆ្នាំ២០០៩ តទៅ។
- *ផ្តល់ស្រូវទិន្នផលខ្ពស់ដល់ប្រជាកសិករចាប់ពីឆ្នាំ ២០១០ តទៅ* ត្រូវបានទាមទារដោយប្រជាពលរដ្ឋម្ចាស់ឆ្នោតចំនួន ៤ ខេត្ត (ពោធិ៍សាត់ កែប មណ្ឌលគីរី និងឧត្តរមានជ័យ)។
- *សូមផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ និងពូជសត្វ (គោ ក្របី ជ្រូក មាន់ ទា....)* ត្រូវបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្ត មណ្ឌលគីរី កោះកុង រតនគីរី កែប និងកំពង់ធំ។
- *សូមឱ្យពេទ្យសត្វមានកម្មវិធីចាក់ថ្នាំបង្ការដល់សត្វ (គោ ក្របី ជ្រូក មាន់ ទា...)* ត្រូវបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តចំនួន ៣ ( តាកែវ កំពង់ស្ពឺ រតនគីរី ) ថា ជាវិស័យអាទិភាពរបស់ខ្លួន។
- *សូមជួយបង្កើតសហគមន៍ចិញ្ចឹមសត្វ* គឺជាវិស័យអាទិភាពដែលត្រូវកំណត់ដោយប្រជាពលរដ្ឋនៅខេត្ត ព្រៃវែង សុំអោយបាននៅឆ្នាំ ២០១០ ។
- *សុំអោយជួយរកទីផ្សារសហគមន៍ដើម្បីលក់ផលិតផលកសិកម្ម* គឺជាវិស័យអាទិភាពរបស់ប្រជាពលរដ្ឋចំនួន ១០ ខេត្ត (មណ្ឌលគីរី ប៉ៃលិន សៀមរាប ស្វាយរៀង បាត់ដំបង ព្រះវិហារ កណ្តាល ព្រៃវែង កំពង់ធំ កំពង់ចាម) ហើយដែលត្រូវធ្វើឱ្យហើយនៅចន្លោះពីឆ្នាំ ២០០៩ ដល់ ២០១១។
- *រដ្ឋាភិបាលត្រូវជួយទិញកសិផលនៅពេលគ្មានទីផ្សារសំរាប់ផលិតផលកសិកម្ម* គឺជាវិស័យអាទិភាពមួយដែលត្រូវបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តកំពង់ស្ពឺ ហើយត្រូវអនុវត្តចាប់ពីឆ្នាំ ២០០៩ តទៅ។
- *រដ្ឋាភិបាលផ្តល់ប្រាក់កម្ចីដោយមានការប្រាក់ទាប* គឺជាវិស័យអាទិភាពរបស់ម្ចាស់ឆ្នោតក្នុងខេត្តចំនួន ៨ (កណ្តាល កំពង់ឆ្នាំង តាកែវ ប៉ៃលិន កំពង់ធំ បាត់ដំបង កំពត សៀមរាប) ហើយត្រូវអនុវត្តក្នុងឆ្នាំ ២០០៩ ឬ២០១០ តទៅ។
- *យកពន្ធតិចលើតំលៃកសិផលជាងតំលៃបច្ចុប្បន្ន ៥០%* ជាវិស័យអាទិភាពមួយរបស់ប្រជាពលរដ្ឋក្នុងមណ្ឌល ប៉ៃលិន។
- *សុំអោយសភាពាណិជ្ជកម្មប្រកាសតំលៃផលិតផលអោយបាន ៣ដង ក្នុង១ឆ្នាំ ព្រមទាំងបង្កើនតំលៃផលិតផលអោយបាន ២០%* ជាវិស័យអាទិភាពដែលលើកឡើងនៅខេត្តឧត្តរមានជ័យ។

- *សុំអោយបង្កើតមជ្ឈមណ្ឌលប្រឹក្សាយោបល់ និងដោះស្រាយបញ្ហាលើដំណាំកសិកម្ម* គឺជាវិស័យអាទិភាពរបស់ម្ចាស់ឆ្នោតនៅខេត្តបាត់ដំបង ។
- *សុំអោយទប់ស្កាត់ផលិតផលក្រៅស្រុក* ជាវិស័យដែលលើកឡើងដោយប្រជាពលរដ្ឋនៅខេត្តសៀមរាប ។
- *សុំបន្ថយតំលៃការយកពន្ធជីនាំចូល* ជាវិស័យអាទិភាពរបស់ប្រជាពលរដ្ឋនៅខេត្ត ព្រៃវែង ។

### ៣.១.២. កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី២ នៃចតុកោណទី១)

- *ផ្តល់ដីសម្បទានសង្គមកិច្ចដល់គ្រួសារគ្មានដីសំរាប់ការដាំដំណាំកសិកម្ម* ត្រូវបានម្ចាស់ឆ្នោតក្នុងខេត្តចំនួន ១២ ខេត្ត (កំពង់ឆ្នាំង ក្រចេះ កំពង់ចាម សៀមរាប មណ្ឌលគីរី កំពង់ស្ពឺ បាត់ដំបង ឧត្តរមានជ័យ ព្រះវិហារ ព្រះសីហនុ កោះកុង ស្ទឹងត្រែង ) កំណត់ថា ជាវិស័យអាទិភាពក្នុងខេត្តរបស់ខ្លួនដែលត្រូវអនុវត្តឱ្យចប់ត្រឹមឆ្នាំ ២០១០ ។
- *ផ្តល់ប្លង់កម្មសិទ្ធិដី និងចុះបញ្ជីដីធ្លីដល់ប្រជាជនឱ្យចប់ចន្លោះឆ្នាំ ២០១០ ដល់២០១៣* គឺជាវិស័យអាទិភាពរបស់ម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៦ (កំពង់ឆ្នាំង ក្រចេះ កែប ឧត្តរមានជ័យ ភ្នំពេញ កំពង់ស្ពឺ) ។
- *រដ្ឋាភិបាលមុននឹងផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់អ្នកវិនិយោគត្រូវអនុវត្តលើការសិក្សាពីទីតាំង និងវាយតំលៃផលប៉ះពាល់* គឺជាការកំណត់ដោយម្ចាស់ឆ្នោតក្នុងមណ្ឌលខេត្តព្រះសីហនុ ដោយត្រូវអនុវត្តចាប់ពីឆ្នាំ ២០១០ តទៅ ។
- *សុំអោយមានការបែងចែកដីសម្បទានសេដ្ឋកិច្ចអោយដាច់ពីគ្នា និងទប់ស្កាត់ការផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលប៉ះពាល់ដល់ដីប្រជាពលរដ្ឋ* គឺជាវិស័យអាទិភាពរបស់ម្ចាស់ឆ្នោតនៅខេត្ត ក្រចេះ និងស្ទឹងត្រែង ដោយចាប់អនុវត្តពីឆ្នាំ ២០០៩ នេះតទៅ ។
- *ត្រូវដោះស្រាយទំនាស់ដីធ្លី និងការផ្តល់សំណងឱ្យបានសមរម្យតាមទីផ្សា* ត្រូវបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តចំនួន ៤ (កំពង់ស្ពឺ សៀមរាប ស្វាយរៀង និងកំពង់ឆ្នាំង) ចាប់ពីឆ្នាំ ២០០៩ តទៅ ។

### ៣.១.៣. កំណែទម្រង់វលផល : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី៣នៃចតុកោណទី១)

- *ទប់ស្កាត់បទល្មើសនេសាទ និងសម្រួលការចុះបញ្ជីសហគមន៍នេសាទ* ត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៦ (កំពង់ឆ្នាំង ក្រចេះ កែប សៀមរាប កំពត បាត់ដំបង) ចាត់ទុកជាវិស័យអាទិភាពក្នុងមណ្ឌលរបស់ខ្លួន ។

- *សុំអោយបើក បឹង ព្រែក ប្រឡាយណាដែលក្រុមហ៊ុនបានបិទ* ត្រូវបានចាត់ទុកថា ជាវិស័យអាទិភាពមួយសម្រាប់ម្ចាស់ឆ្នោតក្នុងមណ្ឌលកណ្ដាលដែលត្រូវអនុវត្តឱ្យបានក្នុងឆ្នាំ ២០១០។

### ៣.១.៤. កំណែទម្រង់ព្រៃឈើ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី៤នៃចតុកោណទី១)

- *ទប់ស្កាត់បទល្មើសការកាប់ព្រៃឈើ* គឺជាវិស័យអាទិភាពមួយរបស់ម្ចាស់ឆ្នោតក្នុងមណ្ឌលកំពង់ស្ពឺ កំពង់ឆ្នាំង បាត់ដំបង និងព្រះវិហារ។
- *សុំបង្កើតព្រៃសហគមន៍* គឺជាវិស័យអាទិភាពរបស់ប្រជាពលរដ្ឋនៅខេត្ត កំពង់ស្ពឺ ។
- *សុំអោយលុបបំបាត់ការរំលោភដីធ្លីគ្រប់រូបភាព និងដកដីពីអ្នករានព្រៃខុសច្បាប់* គឺជាការលើកឡើងរបស់ម្ចាស់ឆ្នោតនៅខេត្ត ស្ទឹងត្រែង ដោយអនុវត្តចាប់ពីឆ្នាំ ២០១០ តទៅ ។

## ៣.២. លក្ខខណ្ឌសន្ទស្សន៍ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

គោលនយោបាយក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ត្រូវបានកំណត់ក្នុងកម្មវិធីនយោបាយរាជរដ្ឋាភិបាលពីចំនុចទី ២៩ ដល់ ៣៣។

ដោយឡែក យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលបានកំណត់ "**ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត**" ជាចតុកោណទី ២ ដែលមានមុំចំនួន៤ គឺ មុំទី១ "**ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍**" មុំទី២ "**ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ**" មុំទី៣ "**ការអភិវឌ្ឍវិស័យថាមពល**" និងមុំទី ៤ "**ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍**"។

ម្ចាស់ឆ្នោតទាំង២៤ ខេត្ត-រាជធានីដែលបានចូលរួមសិក្ខាសាលាសុទ្ធតែបានកំណត់ការលើកស្ទួយវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តថា ជាវិស័យអាទិភាពសម្រាប់មណ្ឌលរបស់ខ្លួន។ ទោះបីយ៉ាងណា ការកំណត់វិស័យអាទិភាពរបស់ម្ចាស់ឆ្នោតទាក់ទងនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺភាគច្រើនមានកំណត់ក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាល។ ក៏ប៉ុន្តែអ្វីដែលសំខាន់ និងខុសគ្នានោះគឺថា ម្ចាស់ឆ្នោតបានកំណត់ពីសកម្មភាពនៃវិស័យអាទិភាពសម្រាប់មណ្ឌលរបស់ខ្លួនច្បាស់លាស់ និងមានលក្ខខណ្ឌសន្ទស្សន៍។

វិស័យអាទិភាពទាក់ទងនឹងវិស័យហេដ្ឋារចនារូបវន្តដែលត្រូវបានកំណត់ដោយម្ចាស់ឆ្នោតមានដូចខាងក្រោម (សូមមើលឧបសម្ព័ន្ធ ក សម្រាប់លក្ខខណ្ឌសន្ទស្សន៍ពិស្តារសម្រាប់មណ្ឌលខេត្ត-រាជធានី នីមួយៗ):

**៣.២.១. ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី១ នៃចតុកោណទី២)**

- *ជួសជុលផ្លូវ កសាងផ្លូវ យន្តការថែទាំផ្លូវ លូ និងស្ពាន* ត្រូវបានម្ចាស់ឆ្នោតក្នុង ១៥ មណ្ឌល ( ព្រៃវែង ក្រចេះ កំពង់ចាម ប៉ៃលិន ស្វាយរៀង មណ្ឌលគិរី រតនគិរី កំពង់ធំ ឧត្តរមានជ័យ ព្រះវិហារ ព្រះសីហនុ កំពត កែប បាត់ដំបង កោះកុង) ចាត់ទុកថា ជាវិស័យអាទិភាពសម្រាប់មណ្ឌលរបស់ខ្លួននីមួយៗ ហើយដែលត្រូវធ្វើឱ្យហើយនៅចន្លោះពីឆ្នាំ ២០១០ ដល់ ២០១២។
- *បំពាក់អំពូលភ្លើងគ្រប់ដងវិថីទាំងអស់* គឺជាវិស័យអាទិភាពមួយរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលព្រៃវែង ហើយត្រូវអនុវត្តឱ្យបានចាប់ពីឆ្នាំ ២០១០ តទៅ។

**៣.២.២. ការគ្រប់គ្រងធានធានទឹក និងប្រព័ន្ធធារាសាស្ត្រ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី២ នៃចតុកោណទី ២)**

- *ស្តារទំនប់ទឹក និងសង់ប្រឡាយ និងទ្វារទឹក, ប្រព័ន្ធធារាសាស្ត្រ ស្ពាន និងស្តារប្រព័ន្ធលូ ដើម្បីកុំអោយស្ទះទឹក* ត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៩ (ពោធិ៍សាត់ កែប តាកែវ ប៉ៃលិន ស្វាយរៀង បាត់ដំបង កំពត ឧត្តរមានជ័យ ភ្នំពេញ ) កំណត់ថា ជាវិស័យអាទិភាពសម្រាប់ខេត្តរបស់ខ្លួន ហើយដែលត្រូវចាប់ផ្តើមធ្វើឱ្យបានក្នុងចន្លោះឆ្នាំ ២០១០ ទៅ ២០១២។
- *សុំតប្រព័ន្ធទឹកស្អាត និងបញ្ចុះតំលៃប្រើប្រាស់ចាប់ពីឆ្នាំ ២០១០ តទៅ* គឺជាវិស័យអាទិភាពមួរបស់ម្ចាស់ឆ្នោតក្នុងមណ្ឌលតាកែវ។
- *ការកសាងអណ្តូងទឹកបន្ថែមទៀតឱ្យបានក្នុងឆ្នាំ ២០១០* ត្រូវបានម្ចាស់ឆ្នោតក្នុងខេត្ត មណ្ឌលគិរី ចាត់ទុកថា ជាវិស័យអាទិភាពមួយសម្រាប់មណ្ឌលរបស់ខ្លួន។

### **៣.២.៣. ការអភិវឌ្ឍវិស័យថាមពល : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី៣ នៃចតុកោណទី២)**

- *តំលៃសេវាក្នុងការតបណ្តាញអគ្គីសនី និងកំណត់តំលៃអគ្គីសនីអោយបានទាប* គឺជាវិស័យអាទិភាពរបស់ម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៩ ( ពោធិ៍សាត់ កំពង់ឆ្នាំង សៀមរាប ស្វាយរៀង ឧត្តរមានជ័យ ព្រះវិហារ កណ្តាល ភ្នំពេញ ព្រះសីហនុ ) ហើយត្រូវអនុវត្តឱ្យបានចាប់ពីឆ្នាំ ២០១០ តទៅ។

### **៣.២.៤. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី៤ នៃចតុកោណទី២)**

- តភ្ជាប់ និងបញ្ចុះតម្លៃសេវាប្រព័ន្ធប្រៃណីយ៍ និងសារទូរគមនាគមន៍ និងបង្កើតវគ្គបង្រៀនខ្លីៗ គឺជាវិស័យអាទិភាពមួយក្នុងមណ្ឌលចំនួនពីរ (តាកែវ និងកំពត) ហើយដែលត្រូវអនុវត្តឱ្យបានក្នុងឆ្នាំ ២០១០។

## **៣.៣. លក្ខខណ្ឌសន្ទស្សន៍ក្នុងវិស័យឯកជន និងការងារ**

ក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល មានចំនុចជាច្រើនបានលើកឡើងពីវិស័យឯកជន និងការងារ ដូចជានៅក្នុងគោលនយោបាយក្នុងវិស័យសេវា វិស័យសង្គមកិច្ច ។ល។ ចំណែកយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលបានកំណត់ច្បាស់ថា "ការអភិវឌ្ឍវិស័យឯកជន និងការងារ" ជាចតុកោណទី ៣ ដែលមានមុំចំនួន៤ គឺ មុំទី១ "ការពង្រឹងវិស័យឯកជន និងការទាក់ទាញវិនិយោគ" មុំទី២ "ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរ" មុំទី៣ "ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម" និងមុំទី ៤ "ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម"។

វិស័យអាទិភាពទាក់ទងនឹងវិស័យឯកជន និងការងារដែលត្រូវបានកំណត់ដោយម្ចាស់ឆ្នោតមានដូចខាងក្រោម (សូមមើលឧបសម្ព័ន្ធ ក សម្រាប់លក្ខខណ្ឌសន្ទស្សន៍ពិស្តារសម្រាប់មណ្ឌលខេត្ត-រាជធានីនីមួយៗ) :

### **៣.៣.១. ការពង្រឹងវិស័យឯកជន និងការទាក់ទាញវិនិយោគ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី១ នៃចតុកោណទី ៣)**

- *ការកំណត់តំលៃទំនិញលើទីផ្សារឱ្យបានច្បាស់លាស់ និងកុំឱ្យតម្លៃមានភាពអនាធិបតេយ្យ* គឺជាការកំណត់របស់ម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៥ (ស្វាយរៀង តាកែវ ព្រះវិហារ ស្ទឹងត្រែង និងកំពង់ធំ) ដែលត្រូវអនុវត្តឱ្យបានក្នុងឆ្នាំ ២០០៩ តទៅ។
- *ផ្តល់ការបណ្តុះបណ្តាលទំនាក់ទំនងទីផ្សារ និងបង្កើតទីផ្សារដល់កសិករ ព្រមទាំងបង្កើនពន្ធការនាំចូលនូវផលិតផលកសិកម្ម* គឺជាវិស័យអាទិភាពដែលបានលើកឡើងដោយម្ចាស់ឆ្នោតនៅខេត្ត កំពត។

### ៣.៣.២. ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី២ នៃចតុកោណទី៣)

- *សុំអោយបង្កើតទីផ្សាការងារអោយបានយ៉ាងហោចណាស់ ៥០% នៃយុវជនរៀនចប់មហាវិទ្យាល័យ* គឺជាវិស័យអាទិភាពមួយសម្រាប់ម្ចាស់ឆ្នោតក្នុងរាជធានីភ្នំពេញដែលត្រូវធ្វើឱ្យបានក្នុងឆ្នាំ ២០១០ តទៅ។

### ៣.៣.៣. ការលើកស្ទួយ សហគ្រាសធុនតូច និងមធ្យម : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី៣ នៃចតុកោណទី ៣)

- *ការបង្កើតរោងចក្រ សហគ្រាស (កាត់ដេរ ស្ករស ម្សៅមី) និងការតំលើងប្រាក់បៀវត្សដល់កម្មករ* គឺជាវិស័យអាទិភាពរបស់ម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៨ (ព្រៃវែង កំពង់ឆ្នាំង ក្រចេះ ឧត្តរមានជ័យ មណ្ឌលគិរី រតនគិរី កំពង់ធំ បាត់ដំបង)។

### ៣.៣.៤. ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី៤ នៃចតុកោណទី ៣)

មុំទី៤ នៃចតុកោណទី៣ នេះ មិនត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលណាមួយកំណត់ថា ជាលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពសម្រាប់ខេត្តរបស់ខ្លួនឡើយ។

## ៣.៤. លក្ខខណ្ឌសន្ទស្សន៍ក្នុងវិស័យកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស

ក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលផ្នែកទី៣ មានកំណត់ច្បាស់ពី "ការអភិវឌ្ឍធនធានមនុស្ស" ដោយផ្តោតសំខាន់ទៅលើវិស័យអប់រំ និងវិស័យសុខាភិបាល។ រីឯយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលបានកំណត់យក "ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស" ជាចតុកោណទី៤ ដែលមានមុំចំនួន៤ គឺ មុំទី១ "ការពង្រឹងគុណភាពវិស័យអប់រំ" មុំទី២ "ការលើកកម្ពស់សេវាសុខាភិបាល" មុំទី៣ "ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ" និងមុំទី ៤ "ការអនុវត្តគោលនយោបាយជាតិប្រជាជន"។

វិស័យអាទិភាពទាក់ទងនឹងការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស និងការងារដែលត្រូវបានកំណត់ដោយម្ចាស់ឆ្នោតមានដូចខាងក្រោម (សូមមើលឧបសម្ព័ន្ធ ក សម្រាប់លក្ខខណ្ឌសន្ទស្សន៍ពិស្តារសម្រាប់មណ្ឌលខេត្ត-រាជធានីនីមួយៗ)៖

### ៣.៤.១. ការពង្រឹងគុណភាពវិស័យអប់រំ ៖ លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី១ នៃចតុកោណទី ៤)

- *សុំបង្កើតសកលវិទ្យាល័យ វិទ្យាល័យ បឋមសិក្សា* គឺជាវិស័យអាទិភាពមួយសម្រាប់ម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៥ (ពោធិ៍សាត់ តាកែវ មណ្ឌលគិរី រតនគិរី ព្រះវិហារ) ដោយត្រូវអនុវត្តឱ្យហើយយ៉ាងយូឆ្នាំ ២០១១។
- *សុំបំបាត់ការប្រមូលលុយពីសិស្ស និងកុំលក់ក្រដាសមេរៀនអោយសិស្ស និងបំបាត់ការយកលុយពេលប្រលងឌីប្លូម បាក់ឌុប និងការបង្រៀនគួរក្នុងម៉ោងចាប់ពីឆ្នាំ ២០១០ តទៅ* គឺជាវិស័យអាទិភាពរបស់ម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន៣ (កំពង់ចាម កណ្តាល និងព្រះសីហនុ)។
- *សុំបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ* ត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៥ ( កែប កំពង់ធំ បាត់ដំបង កំពត ឧត្តរមានជ័យ ) កំណត់ថា ជាវិស័យអាទិភាពសម្រាប់មណ្ឌលរបស់ខ្លួន។
- *ផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូគ្រប់កំរិត* ជាអ្វីដែលប្រជាពលរដ្ឋបានលើកឡើងនៅខេត្ត កំពង់ស្ពឺ និងព្រះវិហារ។
- *បង្កើនប្រាក់បៀវត្សមន្ត្រីរាជការ ក៏ដូចជាគ្រូបង្រៀន* គឺជាវិស័យអាទិភាពរបស់ម្ចាស់ឆ្នោតនៅមណ្ឌលចំនួន ១០ (កំពង់ស្ពឺ កំពត ប៉ៃលិន សៀមរាប ភ្នំពេញ ព្រះវិហារ ព្រៃវែង ឧត្តរមានជ័យ កោះកុង ពោធិ៍សាត់)

**៣.៤.២. ការលើកកម្ពស់សេវាសុខាភិបាល : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី២ នៃចតុកោណទី ៤)**

- *កុំយកប្រាក់មុនការព្យាបាលនៅគ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក និងអនុវត្តនយោបាយមិនយកលុយចំពោះប្រជាពលរដ្ឋក្រីក្រដែលព្យាបាលនៅមន្ទីរពេទ្យ ហើយមណ្ឌលសុខភាពត្រូវមានថ្នាំព្យាបាលគ្រប់គ្រាន់* ត្រូវបានប្រជាពលរដ្ឋចំនួន ៨ មណ្ឌលកំណត់ថា ជាវិស័យអាទិភាពសម្រាប់មណ្ឌលរបស់ខ្លួន ហើយដែលត្រូវអនុវត្តឱ្យបានចាប់ពីឆ្នាំ ២០០៩ ឬ២០១០ តទៅ។
- *តំលៃសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យអោយបានទាបជាងតំលៃបច្ចុប្បន្ន និងមានបុគ្គលិកប្រចាំការអោយបានពេញម៉ោង* គឺជាវិស័យអាទិភាពមួយទៀតសម្រាប់មណ្ឌលចំនួន ៨ គឺពោធិ៍សាត់ កោះកុង ប៉ៃលិន ស្វាយរៀង កំពង់ឆ្នាំង ភ្នំពេញ កំពង់ស្ពឺ កណ្តាល ដោយត្រូវអនុវត្តឱ្យបានចាប់ពីឆ្នាំ ២០១០ តទៅ។
- *ការសុំមណ្ឌលសុខភាពបន្ថែមទៀត* គឺជាវិស័យអាទិភាពមួយរបស់ខេត្ត កែប។
- *ពង្រឹងចុះត្រួតពិនិត្យ និងបិទឱសថស្ថានណាដែលគ្មានច្បាប់អនុញ្ញាត និងគ្មានសមត្ថភាពវិជ្ជាជីវៈ* គឺជាវិស័យអាទិភាពរបស់ម្ចាស់ឆ្នោតក្នុងមណ្ឌលភ្នំពេញ។
- *ដកហូតតំណែង និងដាក់ពិន័យរដ្ឋបាលដល់បុគ្គលិកពេទ្យដែលមិនមានក្រមសីលធម៌* គឺជាវិស័យអាទិភាពកំណត់ដោយម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៤ (ក្រចេះ កំពង់ចាម ស្វាយរៀង ភ្នំពេញ) ដោយចាប់អនុវត្តពីឆ្នាំ ២០០៩ តទៅ។

**៣.៤.៣. ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី៣ នៃចតុកោណទី ៤)**

- *បំបាត់ការរើសអើងចំពោះស្ត្រី និងលើកទឹកចិត្តស្ត្រីចូលរួមក្នុងថ្នាក់ដឹកនាំ ជាពិសេសវិស័យនយោបាយតាំងពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន* ត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៣ (ភ្នំពេញ បាត់ដំបង និងក្រចេះ) កំណត់ថា ជាវិស័យអាទិភាពរបស់ខ្លួន។
- *លុបបំបាត់សេវាបំរើផ្លូវភេទគ្រប់រូបភាព* គឺជាវិស័យអាទិភាពដែលកំណត់ដោយម្ចាស់ឆ្នោតក្នុងមណ្ឌល សៀមរាប ដោយត្រូវអនុវត្តឱ្យបានចាប់ពីឆ្នាំ ២០១០ តទៅ។

### ៣.៤.៤. ការអនុវត្តគោលនយោបាយជាតិប្រជាជន : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (មុំទី៤ នៃចតុកោណទី ៤)

មុំទី៤ នៃចតុកោណទី៤ នេះ មិនត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលណាមួយកំណត់ថា ជាលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពសម្រាប់ខេត្តរបស់ខ្លួនឡើយ។

## ៣.៥. លក្ខខណ្ឌសន្ទស្សន៍ក្នុងវិស័យអភិបាលកិច្ចល្អ

"ការកំណែទម្រង់អភិបាលកិច្ច" ត្រូវបានកំណត់ក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ហើយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលបានចាត់ទុក "អភិបាលកិច្ចល្អ" គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ។ ក្នុងអភិបាលកិច្ចល្អក៏បានកំណត់កំណែទម្រង់៤ទៀតគឺ ទី១ "ការប្រយុទ្ធប្រឆាំងអំពើពុករលួយ" ទី២ "កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" ទី៣ "កំណែទម្រង់រដ្ឋបាលសាធារណៈ" និងទី៤ "កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ"។

វិស័យអាទិភាពទាក់ទងនឹងអភិបាលកិច្ចល្អដែលត្រូវបានកំណត់ដោយម្ចាស់ឆ្នោតមានដូចខាងក្រោម (សូមមើលឧបសម្ព័ន្ធ ក សម្រាប់លក្ខខណ្ឌសន្ទស្សន៍ពិស្តារសម្រាប់មណ្ឌលខេត្ត-រាជធានី នីមួយៗ) :

### ៣.៥.១. ការប្រយុទ្ធប្រឆាំងអំពើពុករលួយ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (ចំនុចទី១ នៃអភិបាលកិច្ចល្អ)

- *ការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ* ត្រូវបានប្រជាពលរដ្ឋចំនួន ១៥ មណ្ឌល ( ពោធិ៍សាត់ ព្រៃវែង កំពង់ឆ្នាំង ក្រចេះ សៀមរាប តាកែវ ប៉ៃលិន ស្វាយរៀង កំពង់ស្ពឺ រតនគិរី កំពង់ធំ បាត់ដំបង ភ្នំពេញ ព្រះសីហនុ ស្ទឹងត្រែង) កំណត់ជាវិស័យអាទិភាពរបស់ខ្លួន ហើយអនុម័តឱ្យបានក្នុងចន្លោះឆ្នាំ ២០០៩ ទៅ ២០១០។
- *បញ្ឈប់ការស៊ីសំណូកគ្រប់រូបភាព* គឺជាវិស័យអាទិភាពដែលកំណត់ដោយម្ចាស់ឆ្នោតក្នុងមណ្ឌលពោធិ៍សាត់ និងក្រចេះ ដោយត្រូវអនុវត្តឱ្យបានចាប់ពីឆ្នាំ ២០១០ តទៅ។
- *សុំអោយសមត្ថកិច្ចឈប់យកប្រាក់ពីជនរងគ្រោះនៅពេលដែលទៅយកវត្ថុតាង* ត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលកំពង់ចាម ចាត់ទុកជាវិស័យអាទិភាពមួយដែលត្រូវអនុវត្តឱ្យបានចាប់ពីឆ្នាំ ២០០៩ តទៅ។
- *មិនអោយមានការយកលុយបន្ថែមទៅលើតំលៃពន្ធផ្លូវដែលមាន* គឺជាវិស័យអាទិភាពមួយរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលកណ្ដាល ហើយដែលត្រូវអនុវត្តឱ្យបានចាប់ពីឆ្នាំ ២០១០ តទៅ។

- *សុំអោយមានការបិទផ្សាយជាសាធារណៈពីតំលៃសេវា និងរយៈពេលដែលត្រូវទទួលសេវា* ត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលសីហនុ និងស្ទឹងត្រែង ចាត់ទុកជាវិស័យអាទិភាពមួយរបស់ខេត្តខ្លួន ហើយចាប់អនុវត្តនៅដើមឆ្នាំ ២០១០ តទៅ។
- *សុំអោយមានការដាក់តារាងកំណត់តំលៃអោយបានជាក់លាក់ ដូចជាប្រាក់ប្រដាប់ក្តី ប្រាក់ចុះបញ្ជីពាក្យបណ្តឹង* គឺជាវិស័យអាទិភាពមួយដែលម្ចាស់ឆ្នោតក្នុងមណ្ឌលព្រះសីហនុបានកំណត់សម្រាប់មណ្ឌលរបស់ខ្លួន។
- *រដ្ឋាភិបាលជួយផ្សព្វផ្សាយព័តមានពីអ្វីដែលរដ្ឋាភិបាលបានធ្វើ* គឺជាវិស័យអាទិភាពមួយដែលម្ចាស់ឆ្នោតក្នុងមណ្ឌលភ្នំពេញបានកំណត់សម្រាប់មណ្ឌលខ្លួន។

### ៣.៥.២. កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (ចំនុចទី២ នៃអភិបាលកិច្ចល្អ)

- *ការបង្កើតច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា* ត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ៣ ( កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ ) ចាត់ទុកជាផ្នែកមួយនៃវិស័យអាទិភាពក្នុងខេតតរបស់ខ្លួន។
- *កំណែទំរង់ប្រព័ន្ធតុលាការអោយមានឯករាជ្យ, ចាត់វិធានការចំពោះបណ្តឹងអោយបានឆាប់រហ័ស, និងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាព និងការបង្កើតយុទ្ធនាការណ៍ថ្នាក់ជាតិសំរាប់ប្រឆាំងទៅនឹងនិទណ្ឌភាព* គឺជាវិស័យអាទិភាពរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលចំនួន ៥ ( សៀមរាប ស្ទឹងត្រែង កំពង់ធំ ពោធិ៍សាត់ និងក្រចេះ)។
- *ពង្រឹងការអនុវត្តច្បាប់ដោយផ្តន្ទាទោសមន្ត្រីអនុវត្តច្បាប់ដែលប្រព្រឹត្តខុសច្បាប់អោយបានយ៉ាងហោចណាស់ ៧០% នៃករណីរំលោភច្បាប់* ត្រូវបានកំណត់ជាវិស័យអាទិភាពមួយក្នុងមណ្ឌលកណ្តាល និងក្រចេះ។
- *មិនត្រូវយកប្រាក់ពីប្រជាពលរដ្ឋក្រីក្រនៅពេលគាត់ដាក់ពាក្យបណ្តឹងចូលតុលាការ និងរាល់ការទៅសួរសុខទុក្ខអ្នកទោសក្នុងពន្ធនាគារមិនត្រូវយកប្រាក់ឡើយ* ក៏ត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលរតនគីរី ចាត់ទុកជាវិស័យអាទិភាពសម្រាប់មណ្ឌលខ្លួនផងដែរ។
- *ការផ្តល់មេធាវីដល់ប្រជាពលរដ្ឋក្រីក្រដោយឥតគិតថ្លៃ* គឺជាវិស័យអាទិភាពមួយរបស់មណ្ឌល ឧត្តរមានជ័យ។

**៣.៥.៣. កំណែទម្រង់រដ្ឋបាលសាធារណៈ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (ចំនុចទី៣ នៃអភិបាលកិច្ចល្អ)**

- *ឈប់យកប្រាក់ពីថ្លៃសេវាកម្មសំបុត្រអាពាហ៍ពិពាហ៍* ត្រូវបានកំណត់ជាវិស័យអាទិភាពសម្រាប់មណ្ឌលកំពង់ចាម ដោយម្ចាស់ឆ្នោតក្នុងមណ្ឌលកំពង់ចាម ។
- *ការស្នើតំឡើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការ* ត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលចំនួន ១០ (កណ្តាល ពោធិ៍សាត់ ព្រៃវែង សៀមរាប ប៉ៃលិន កំពង់ស្ពឺ កំពត ឧត្តរមានជ័យ ព្រះវិហារ ភ្នំពេញ) កំណត់ថាជាវិស័យអាទិភាពសម្រាប់មណ្ឌលរបស់ខ្លួន ។

**៣.៥.៤. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត (ចំនុចទី៤ នៃអភិបាលកិច្ចល្អ)**

- *សុំកុំយកកងកំលាំងប្រដាប់អាវុធជាតិទៅបំរើផលប្រយោជន៍ជនមួយក្តាប់តូច* ត្រូវបានម្ចាស់ឆ្នោតក្នុងមណ្ឌលរតនគិរី កំណត់ថា ជាវិស័យអាទិភាពរបស់មណ្ឌលខ្លួន ។

**៣.៦. សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់ : លក្ខខណ្ឌសន្ទស្សន៍អាទិភាពកំណត់ដោយម្ចាស់ឆ្នោត**

- *កាត់បន្ថយរាល់បទល្មើសសង្គម និងលុបបំបាត់ក្មេងទំនើង ល្បែងស៊ីសង* ត្រូវបានកំណត់ជាវិស័យអាទិភាពក្នុងមណ្ឌលចំនួន ២ (ព្រៃវែង និងកែប) ។

**៤. ការគាំទ្ររបស់មន្ត្រីជាប់ឆ្នោតក្នុងការជម្រុញការអនុវត្តលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងមណ្ឌល (ខេត្ត-រាជធានី) របស់ខ្លួន**

សិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនេះបានអញ្ជើញ អ្នកតំណាងរាស្ត្រមកពីគ្រប់គណបក្សដែលមានអាសនៈក្នុងមណ្ឌលដែលសិក្ខាសាលាបានរៀបចំ ។ ទោះបីយ៉ាងណា អ្នកតំណាងរាស្ត្រមួយចំនួនមិនអាចចូលរួមបាន ដោយជាប់មានធុរៈ ។

ជាលទ្ធផល សិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង **២៤ មណ្ឌល** មានការចូលរួម ពីតំណាងរាស្ត្រមកពីគ្រប់គណបក្សនយោបាយសរុបចំនួន **១៥នាក់** និង ប្រធាន និងសមាជិកក្រុមប្រឹក្សាខេត្តចំនួន

**២១ នាក់** មកពីគ្រប់គណបក្សនយោបាយ ហើយនិងមានការចូលរួមពីអាជ្ញាធរខេត្ត-រាជធានី (អភិបាលខេត្ត អភិបាលរងខេត្ត ឬមន្ត្រី សាលាខេត្ត) សរុបចំនួន **២០ រូប**។

អ្នកតំណាងរាស្ត្រដែលបានចូលរួមមកពីគណបក្សប្រជាជនកម្ពុជាមានចំនួន **៤រូប** អ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីមាន ចំនួន **៨រូប** អ្នកតំណាងរាស្ត្រមកពីគណបក្សហ៊្វុនស៊ិនប៉ិចមានចំនួន **១រូប** អ្នកតំណាងរាស្ត្រមកពីគណបក្សជាតិនិយមមានចំនួន **១រូប** និងអ្នកតំណាងរាស្ត្រមកពីគណបក្សសិទ្ធិមនុស្សមានចំនួន **១រូប**។ ចំណែកឯប្រធាន និងសមាជិកក្រុមប្រឹក្សាខេត្តដែលមកពីគណបក្សប្រជាជនកម្ពុជាមានចំនួន **១០រូប** សមាជិកក្រុមប្រឹក្សាខេត្តមកពីគណបក្សសមរង្ស៊ីមានចំនួន **១០រូប** និងក្រុមប្រឹក្សាខេត្តមកពីគណបក្ស ជាតិនិយម មានចំនួន **១រូប** ។

ខាងក្រោមគឺជានាម/ឈ្មោះអ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សាខេត្ត និងអាជ្ញាធរមូលដ្ឋានដែលបានចូលរួមក្នុងសិក្ខាសាលា :

១- **កំពង់ស្ពឺ :** អ្នកតំណាងរាស្ត្រ ឯកឧត្តម **លី សុន** និង ឯកឧត្តម **នុត រំដួល** និងអភិបាលរងខេត្តកំពង់ស្ពឺ លោកស្រី **ទឹម សាវ៉ាត**។

២- **កំពង់ធំ :** សមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តម **កែវ ចំរើន** និងឯកឧត្តម **មុំ សារី** និងអភិបាលរងខេត្តឯកឧត្តម **គង់ វិមាន**។

៣- **ប៉ៃលិន :** អ្នកតំណាងរាស្ត្រ ឯកឧត្តម **អ៊ិច សារូ** និងអភិបាលរងខេត្តប៉ៃលិន ឯកឧត្តម **ម៉ី មគ្គ**។

៤- **បាត់ដំបង :** សមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តម **ជា ជីវ** ។

៥- **តាកែវ :** អ្នកតំណាងរាស្ត្រ ឯកឧត្តម **គួយ ប៊ុនរឿន** និងអភិបាលរងខេត្តតាកែវ ឯកឧត្តម **កង សំអឿន**។

៦- **សៀមរាប :** អ្នកតំណាងរាស្ត្រ លោកជំទាវ **កែ សុវណ្ណរតន៏** និងសមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តម **កុយ សង** និងឯកឧត្តម **សុខ គីមសេង** និងអភិបាលរងខេត្តសៀមរាប លោកស្រី **ឯម ផល្លាមុនី**។

៧- **កំពង់ចាម :** អ្នកតំណាងរាស្ត្រ លោកជំទាវ **ថាក់ ឡានី** និងអភិបាលរងខេត្តកំពង់ចាម លោកស្រី **ខុង ស៊ុនអេង**។

៨- **កែប :** សមាជិកក្រុមប្រឹក្សាខេត្តកែប ឯកឧត្តម **មុត មន** និងអភិបាលរងខេត្តកែប ឯកឧត្តម **កែវ សត្ថា**។

៩- **ក្រចេះ :** អ្នកតំណាងរាស្ត្រ ឯកឧត្តម **កាទើ តូយ៉េប** និង សមាជិកក្រុមប្រឹក្សាខេត្តក្រចេះ ឯកឧត្តម **ទឹម សុធន់** និងអភិបាលរងខេត្តក្រចេះ លោក **ធុន ទ្រី**។

១០- **កំពង់ឆ្នាំង :** អ្នកតំណាងរាស្ត្រ ឯកឧត្តម **ឃី វណ្ណដេត** និងសមាជិកក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង ឯកឧត្តម **ឡុង ឈុនឡៃ** ឯកឧត្តម **ទាំ សារី** និង ឯកឧត្តម **ទឹម ប៊ុណ្ណា** និងអភិបាលរងខេត្តកំពង់ឆ្នាំង លោក **សៀត គីមលៀង**។

១១- **ព្រៃវែង :** អ្នកតំណាងរាស្ត្រ ឯកឧត្តម **មឹន ស៊ាន** ឯកឧត្តម **គង់ បូរ៉ា** ឯកឧត្តម **សៅ រ៉ានី** និង អភិបាលរងខេត្តព្រៃវែង លោក **ថង គឿន**។

១២- **ពោធិ៍សាត់ :** សមាជិកក្រុមប្រឹក្សាខេត្តពោធិ៍សាត់ ឯកឧត្តម **ងួន ប៉ោសេង** និង អភិបាលរងខេត្តពោធិ៍សាត់ លោក **ពេជ ហន**។

១៣- **ព្រះវិហារ :** សមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តម **នង ចន** ឯកឧត្តម **សុខ ណារឿន** និងអភិបាលរងខេត្តព្រះវិហារ លោកស្រី **ខូយ ប៊ុនថាន**។

១៤- **ព្រះសីហនុ :** សមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តម **វង្ស ផាណាត** ឯកឧត្តម **សុខ សាវ៉ាត** និងនាយរងខុទ្ទការល័យសាលាខេត្ត លោក **សេរី សម្បត្តិ**។

១៥- **ភ្នំពេញ :** អ្នកតំណាងរាស្ត្រ ឯកឧត្តម **សុនឆ័យ** និងសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ឯកឧត្តម **ព្រហ្ម គន**។

១៦- **កណ្តាល :** អ្នកតំណាងរាស្ត្រ ឯកឧត្តម **ឃឹម ឡាគី** ឯកឧត្តម **អ៊ូ ច័ន្ទរិទ្ធ** និងសមាជិកក្រុមប្រឹក្សាខេត្ត លោកជំទាវ **នួន និរតី** និងអភិបាលរងក្រុងតាខ្មៅ លោក **នូ សាខន**។

១៧- **បន្ទាយមានជ័យ :** អ្នកតំណាងរាស្ត្រ ឯកឧត្តម **ញឹក ប៊ុនឆៃ** និងសមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តម **ជង់ ប្រសើដ្ឋ** ឯកឧត្តម **កែវ សម្ផស្ស** និងអភិបាលរងខេត្តលោក **រៀម សារិន**។

១៨- **ស្ទឹងត្រែង :** សមាជិកក្រុមប្រឹក្សាខេត្តស្ទឹងត្រែង ឯកឧត្តម **ពុយ ចាន់ថាឡា** ។

១៩- **កំពត :** អតីតអភិបាលរងខេត្តកំពត ឯកឧត្តម **សាឡោះ សេន** (បច្ចុប្បន្នជាតំណាងរាស្ត្រ មណ្ឌលកំពត)។

២០- **រតនគិរី :** អភិបាលរងខេត្តរតនគិរី ឯកឧត្តម **ម៉ុម សារឿន**។

២១- **កោះកុង :** អភិបាលរងខេត្តកោះកុង ឯកឧត្តម **សាយ សុជាតិ**។

២២- **ស្វាយរៀង :** អគ្គលេខាធិការសាលាខេត្តស្វាយរៀង លោក **ចាន់ សាវ៉ាន់**។

២៣- **មណ្ឌលគិរី :** អភិបាលរងខេត្តមណ្ឌលគិរី ឯកឧត្តម **ហេង សំណាង**។

២៤- **ឧត្តរមានជ័យ :** ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ ឯកឧត្តម **ឃឹម ធីន**។

# ឧបសម្ព័ន្ធ ក : លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពតាមមណ្ឌល (ខេត្ត-រាជធានី)

## ក.១. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកណ្ដាល

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត កណ្ដាល |
|---|
| ១) សុំឱ្យរដ្ឋាភិបាលផ្ដល់វគ្គបណ្ដុះបណ្ដាលបច្ចេកទេសក្នុងការដាំដំណាំស្រូវ ពោត សណ្ដែក បន្លែ... និងបច្ចេកទេសការចិញ្ចឹមសត្វជ្រូក គោ ក្របី មាន់ ទា ត្រី ដល់កសិករគ្រប់ស្រុកទូទាំងខេត្តកណ្ដាល ដោយមួយឆ្នាំមាន ២ វគ្គ ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ២) សុំឱ្យរាជរដ្ឋាភិបាលស្វែងរកទីផ្សារសំរាប់លក់ផលិតផលកសិកម្ម (ស្រូវ ពោត សណ្ដែក បន្លែ...) ហើយតម្លៃឱ្យបានចំណេញ ៥០% នៃការចំណាយទៅលើការផលិតចាប់ពីឆ្នាំ ២០១០ តទៅ។ និងបង្កើតឱ្យមានកន្លែងទិញស្រូវសម្រាប់ស្តុកទុកនៅទីរួមខេត្តកណ្ដាលនៅត្រឹមឆ្នាំ ២០១០។ |
| ៣) សូមកុំលក់ក្រដាសមេរៀនឱ្យសិស្សនៅក្នុងថ្នាក់រៀននៅគ្រប់សាលាទាំងអស់ទូទាំងខេត្តកណ្ដាលចាប់ពីដើមឆ្នាំ ២០១០តទៅ។ ត្រូវតំឡើងប្រាក់បៀវត្សមន្ត្រីរាជការទាំងអស់មានប្រាក់បៀវត្សយ៉ាងតិច ១៥០ ដុល្លារអាមេរិក ក្នុងមួយខែ នៅទូទាំងខេត្តកណ្ដាលទាំងអស់ដោយអនុវត្តចាប់ពីដើមឆ្នាំ ២០១០ តទៅ។ |
| ៤) សុំឱ្យរាជរដ្ឋាភិបាលបើកបឹង ព្រែក ប្រឡាយនៅក្នុងខេត្តកណ្ដាលដែលក្រុមហ៊ុនឯកជនបានបិទដោយត្រូវបើកចាប់ពីឆ្នាំ ២០១០ តទៅ ដើម្បីឱ្យប្រជាពលរដ្ឋបានបង្កបង្កើនផល និងអាចនេសាទបាន។ |
| ៥) ពង្រឹងការអនុវត្តច្បាប់ដោយផ្ដន្ទាទោសមន្ត្រីអនុវត្តច្បាប់ ដែលប្រព្រឹត្តខុសច្បាប់ដែលកំពុងតែមានស្រាប់ ដោយផ្ដន្ទាទោសឱ្យមានយ៉ាងហោចណាស់៧០% នៃករណីរំលោភច្បាប់ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៦) មិនអោយមានការយកលុយបន្ថែមទៅលើតំលៃពន្ធផ្លូវដែលមានដាក់នៅលើប័ណ្ណសំគាល់បង់ពន្ធយានជំនិះនៅទូទាំងខេត្តកណ្ដាល ដោយអនុវត្តអោយបាន ១០០% អោយបាននៅឆ្នាំ ២០១០។ |
| ៧) សុំបណ្ដាញអគ្គិសនីតភ្ជាប់ចូលទៅក្នុងស្រុកកណ្ដាលស្ទឹង ស្រុកខ្សាច់កណ្ដាល ស្រុកមុខកំពូល ស្រុកល្វាឯម ស្រុកពញាឮ និងស្រុកលើកដែក ហើយតម្លៃអគ្គិសនីគឺ៤០០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ |
| ៨) សុំឱ្យរាជរដ្ឋាភិបាលផ្ដល់ប្រាក់កម្ចីដោយមានការប្រាក់ទាបត្រឹម ៣% ក្នុងមួយឆ្នាំ ទៅលើវិស័យកសិកម្ម ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៩) គ្រប់មន្ទីរពេទ្យរដ្ឋទាំងអស់ក្នុងខេត្តកណ្ដាលត្រូវអនុវត្តគោលនយោបាយមិនយកលុយចំពោះប្រជាពលរដ្ឋក្រីក្រដែលព្យាបាលនៅមន្ទីរពេទ្យអោយបាន ១០០%ចាប់ពី ដើមឆ្នាំ ២០១០ តទៅ។ |
| ១០) គ្រប់មណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋទាំងអស់ក្នុងខេត្តកណ្ដាលត្រូវមានគ្រូពេទ្យប្រចាំការ២៤ម៉ោង ហើយគ្រប់គ្រូពេទ្យទាំងអស់ត្រូវគោរពម៉ោងធ្វើការឱ្យបានទៀងទាត់ ចាប់ពីដើមឆ្នាំ ២០១០តទៅ។ |

## ក.២. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ចាម

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង ១០ នៅក្នុងខេត្ត កំពង់ចាម |
|---|
| ១) សុំឱ្យរកទីផ្សារសំរាប់លក់កសិផល ដោយកំណត់តម្លៃ ដូចជា ស្រូវ ឱ្យបានស្មើនឹង ៣០% ក្នុងតម្លៃប្រេងសាំង ០១លីត្រ សណ្តែកសៀង ឱ្យបានស្មើនឹង ៥០% ក្នុងតម្លៃប្រេងសាំង ០១លីត្រ ដំឡូងមីក្រៀមឱ្យបានស្មើនឹង ២០% ក្នុងតម្លៃប្រេងសាំង ០១លីត្រ និង ល្ង ឱ្យបានស្មើនឹង ១០០% ក្នុងតម្លៃប្រេងសាំង ០១លីត្រ [អោយបាននៅចុងឆ្នាំ ២០០៩] ។ |
| ២) សុំជំរុញឱ្យមានការអនុម័ត លក្ខន្តិកក្រមសីលធមិសំរាប់ចៅក្រម និងព្រះរាជអាជ្ញា ឱ្យបានមុនឆ្នាំ២០១០ ។ |
| ៣) សុំកុំឱ្យយកប្រាក់ពីអ្នកជំងឺដែលមកព្យាបាលនៅមន្ទីរពេទ្យរដ្ឋ ចាប់ពីខែ១០ ឆ្នាំ២០០៩ នេះតទៅ និងសុំឱ្យបុគ្គលិកសុខាភិបាលគោរព ក្រមសីលធមិ និងវិជ្ជាជីវៈរបស់ខ្លួនឱ្យបានចាប់ពីដើមឆ្នាំ២០១០ នេះតទៅ ។ |
| ៤) សំណូមពរដល់តំណាងរាស្រ្ត រាជរដ្ឋាភិបាល ជំរុញឱ្យអាជ្ញាធរភូមិ ឃុំ ស្រុក ខេត្ត និងស្ថាប័នពាក់ព័ន្ធឈប់យកប្រាក់ពីថ្លៃសេវាកម្ម ដូចជា សំបុត្រអាពាហ៍ពិពាហ៍ ធ្វើអត្តសញ្ញាណប័ណ្ណ ... និងឱ្យមានប្រសិទ្ធិភាព គោរពក្រមសីលធមិចាប់ពីចុងឆ្នាំ ២០០៩ នេះតទៅ ។ |
| ៥) សុំផ្ទេរ ឬប្រគល់ការគ្រប់គ្រងរមណីយដ្ឋានទឹកធ្លា ដែលសព្វថ្ងៃគ្រប់គ្រងដោយឯកជនមកនៅក្រោមការគ្រប់គ្រងរបស់សហគមន៍[២] ចាប់ពី ដើមឆ្នាំ២០១០ តទៅ ។ |
| ៦) សុំឱ្យសមត្ថកិច្ចបញ្ឈប់ការយកប្រាក់ពីជនរងគ្រោះនៅពេលជនរងគ្រោះទៅយកវត្ថុតាង ដូចជា ម៉ូតូ គោ ក្របី ... ដែលសមត្ថកិច្ចដកហូត បានពីចោរចាប់ពីខែ ១០ ឆ្នាំ២០០៩ នេះតទៅ ។ |
| ៧) សំណូមពរឱ្យរាជរដ្ឋាភិបាល អ្នកតំណាងរាស្រ្ត ធ្វើយុទ្ធនាការថ្នាក់ជាតិ (ដូចជាការដង្ហែរជាក្បួន ឬប្រារព្ធពិធីផ្សេងៗ,......) សំរាប់ប្រឆាំង ទៅនឹងនិទណ្ឌភាពនៅទូទាំងខេត្តកំពង់ចាម ចាប់ផ្តើមពីឆ្នាំ២០១០ នេះតទៅ ។ |
| ៨) សុំបំបាត់ការប្រមូលលុយពីសិស្ស (ក្នុងម៉ោងសិក្សា, ពេលប្រលង និងទិញពិន្ទុពីគ្រូ) នៅទូទាំងខេត្តកំពង់ចាម ចាប់ផ្តើមនៅដើមឆ្នាំ ២០១០ នេះតទៅ ។ |
| ៩) សុំផ្លូវចាក់គ្រួសក្រហម ប្រវែង ៧គីឡូម៉ែត្រ ទទឹង ៥ម ដាក់លូមួយកន្លែង ចាប់ពីភូមិផ្ទះខ្ពស់ ដល់បឹង អូរតាញៀន ឃុំតុងរ៉ុង ស្រុកព្រៃឈរ កសាងចាប់ពីឆ្នាំ២០១០ ដល់២០១២ ។ និងមួយខ្សែទៀតប្រវែង ៦គីឡូម៉ែត្រ ទទឹង ៦ម ចាប់ពីភូមិ មៀន ត្រង់ក្លោងទ្វារ ឃ្លោយ ដល់បឹងធំ ចាប់កសាងពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១០ ។ សុំកសាងផ្លូវគ្រួសក្រហមឡើងវិញមួយខ្សែ ពីទំនប់កែងថ្មដារ ទល់ផ្លូវស្វាយភ្លើង ភូមិស្វាយភ្លើង ឃុំស្វាយភ្លើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានប្រវែង ៥គីឡូម៉ែត្រ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២ ។ |
| ១០) សុំឱ្យមានដីសម្បទានសង្គមកិច្ចដើម្បីចែកឱ្យប្រជាពលរដ្ឋក្រីក្រសំរាប់ធ្វើកសិកម្មគ្រួសារដោយក្នុងមួយគ្រួសារយ៉ាងតិចអោយបាន ២ ហិចតា ចាប់ពីដើមឆ្នាំ២០១០ ឱ្យចប់ក្នុងឆ្នាំ២០១២ និងសុំការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មតម្រូវតាមពូជដាក់ស្តែងអោយបានពីរវគ្គ ក្នុងមួយឃុំ សំរាប់រយៈពេល ១ ឆមាស អោយបាននៅទូទាំងខេត្តកំពង់ចាម ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ ២០១២ ។ |

[២] ដូចជា សហគមន៍ស្រីគ្រប់លក្ខណ៍ ។

## ក.៣. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ឆ្នាំង

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង ១០ នៅក្នុងខេត្ត កំពង់ឆ្នាំង |
|---|
| ១) សូមឱ្យរដ្ឋាភិបាលទប់ស្កាត់បទល្មើសនេសាទ និងការកាប់ព្រៃឈើឱ្យបាន ១០០% ក្នុងខេត្តកំពង់ឆ្នាំង ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ២) សូមឱ្យរដ្ឋាភិបាលផ្តល់ដីសម្បទានសង្គមកិច្ចសំរាប់ការដាំដំណាំដល់គ្រប់គ្រួសារប្រជាពលរដ្ឋក្រីក្រដែលខ្វះខាតដីក្នុងខេត្ត កំពង់ឆ្នាំង ឱ្យបានត្រឹមឆ្នាំ ២០១០។ |
| ៣) ត្រូវមានការដេញថ្លៃជាសាធារណៈចំពោះការផ្គត់ផ្គង់ថាមពលអគ្គិសនីសម្រាប់ទូទាំងខេត្តកំពង់ឆ្នាំងចាប់ពីឆ្នាំ ២០១១ និង បញ្ចុះតំលៃអគ្គិសនី មកត្រឹម ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង អោយបានចាប់ពីឆ្នាំ ២០១០តទៅ។ |
| ៤) រដ្ឋាភិបាលត្រូវចេញច្បាប់ប្រឆាំងអំពើពុករលួយអោយចេញនៅដើមឆ្នាំ ២០១០។ |
| ៥) សូមជួយជំរុញការដោះស្រាយទំនាស់ដីធ្លី ដោយចេញប្លង់កម្មសិទ្ធិឱ្យបានគ្រប់ៗគ្នាទូទាំងខេត្តកំពង់ ឆ្នាំង យ៉ាងយូត្រឹមឆ្នាំ ២០១៣។ |
| ៦) សូមផ្តល់វគ្គបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មដល់ប្រជាកសិករក្នុងខេត្តឱ្យបាន ១០វគ្គ ក្នុងមួយឆ្នាំអោយបានគ្រប់ភូមិក្នុងខេត្ត កំពង់ឆ្នាំង ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៧) សូមឱ្យរដ្ឋាភិបាលជួយធ្វើអន្តរាគមន៍ ដល់វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងខេត្តកំពង់ឆ្នាំងបញ្ចុះតំលៃអត្រាការប្រាក់មកនៅត្រឹមតែ ១.៥ %/ ខែ ដើម្បីជួយសំរួលប្រជាពលរដ្ឋក្រីក្រចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៨) សូមឱ្យរដ្ឋាភិបាលជួយធ្វើបទអន្តរាគមន៍ដល់រោងចក្រនានានៅក្នុងខេត្ត កំពង់ឆ្នាំង ដោយតម្លើងប្រាក់ខែដល់កម្មករឱ្យបានសមស្របទៅនឹងតម្រូវការទីផ្សារ យ៉ាងហោចណាស់ចាប់ពី ៧០ដុល្លារ/ខែ (ប្រាក់ខែគោល) ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៩) បញ្ចុះតំលៃសុខភាពអោយទាប ឬមិនគិតថ្លៃសំរាប់អ្នកក្រ អោយបាន៨០ភាគរយនៃតម្លៃបច្ចុប្បន្ននៅតាមគ្រប់មណ្ឌលសុខភាព និង មន្ទីរពេទ្យបង្អែកអោយបាននៅឆ្នាំ ២០១០ តទៅ។ |
| ១០) រដ្ឋាភិបាលត្រូវបង្កើតលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាអោយចេញនៅពាក់កណ្តាលឆ្នាំ ២០១០។ |

## ក.៤. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ធំ

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពនៅក្នុងខេត្ត កំពង់ធំ |
| --- |
| ១) សុំអោយតុលាការកាត់ក្តីឱ្យមានយុត្តិធម៌ មិនលំអៀង មិនឱ្យមានអន្តរាគមន៍ មិនស៊ីសំណូក ស្របតាមការកំណត់នៃច្បាប់ ចាប់ពីឆ្នាំ ២០០៩ ព្រមទាំងអនុម័តច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឱ្យបាននៅត្រឹមឆ្នាំ ២០១០។ |
| ២) សុំឱ្យធ្វើការបណ្តុះបណ្តាលកសិករ ពីបច្ចេកទេសកសិកម្ម (ចិញ្ចឹមសត្វ-ធ្វើជីកំប៉ុស្តិ៍ ជីអ៊ីអឹម...) នៅទូទាំងខេត្តកំពង់ធំឱ្យបាន ៤ វគ្គ ក្នុងមួយឃុំ អោយបានគ្រប់ឃុំ ក្នុងមួយឆ្នាំ ចាប់ផ្តើមពីចុងឆ្នាំ ២០០៩ នេះតទៅ។ |
| ៣) សុំឱ្យរដ្ឋាភិបាលផ្តល់ឥណទានដែលមានការប្រាក់ទាបជាង ៣% ក្នុងមួយឆ្នាំ សម្រាប់កសិករក្រីក្រក្នុងខេត្តកំពង់ធំ យកទៅប្រកបរបរកសិកម្មចាប់ពីចុងឆ្នាំ ២០០៩ នេះតទៅ។ |
| ៤) សុំផ្លូវ ៤ ខ្សែ ក្នុងស្រុកកំពង់ស្វាយ (១-ជួសជុលផ្លូវគ្រួសក្រហម និងក្រាលកៅស៊ូ តភ្ជាប់ពីឃុំព្រៃតាហ៊ូ ដែលមានថ្នល់កៅស៊ូស្រាប់ តភ្ជាប់ទៅឃុំក្តីដូង និងភូមិពាមក្រែងចម្ងាយប្រហែល ៧គីឡូម៉ែត្រ និងទទឹងប្រហែល ៨ម៉ែត្រ យ៉ាងយូរបញ្ចប់ត្រឹមពាក់កណ្តាលឆ្នាំ ២០១០ ។ ២-សុំផ្លូវក្រាលគ្រួសក្រហមពីមុខវត្តក្តីដូងទៅមណ្ឌលសុខភាពគោកងួនចម្ងាយ ៣គីឡូម៉ែត្រ និងទទឹងប្រហែល ៨ម៉ែត្រ យ៉ាងយូរបញ្ចប់ត្រឹមចុងឆ្នាំ ២០១០។ ៣-សុំផ្លូវក្រាលកៅស៊ូពីចុងភូមិកំពង់ក្របៅ ទៅដល់ភូមិកំពង់ស្វាយចម្ងាយ ១០គីឡូម៉ែត្រ និងទទឹងប្រហែល ៨ម៉ែត្រ យ៉ាងយូរបញ្ចប់នៅចុងឆ្នាំ ២០១១។ ៤-សុំផ្លូវគ្រួសក្រហមពីភូមិកូនត្នោតទៅស្រុកប្រាសាទសំបូរ ត្រូវការជួសជុល និងក្រាលកៅស៊ូចម្ងាយប្រហែល ១៣គីឡូម៉ែត្រ ចាប់ផ្តើមនៅដើមឆ្នាំ ២០១០ និងបញ្ចប់ត្រឹមចុងឆ្នាំ ២០១២។) |
| ៥) ជួយរកទីផ្សារជាតិ និងអន្តរជាតិ (ក្រុមហ៊ុន ឬសហគ្រាសក្នុងខេត្តកំពង់ធំដើម្បីនាំចេញទៅកាន់ទីក្រុងភ្នំពេញ និងក្រៅប្រទេស) សម្រាប់ការលក់កសិផល (ស្រូវ សណ្តែកសៀង សណ្តែកបាយ ដំឡូងមី ពោត...) ចាប់ពីចុងឆ្នាំ ២០០៩ នេះតទៅ។ |
| ៦) ជំរុញឱ្យអនុម័តច្បាប់ប្រឆាំងអំពើពុករលួយឱ្យបាននៅដើមឆ្នាំ២០១០ និងអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាពតាមគោលការណ៍នៃច្បាប់នេះ។ |
| ៧) ចាប់ពីដើមឆ្នាំ ២០១០ ដល់ ២០១៥ សុំឱ្យមានរោងចក្រកាត់ដេរក្នុងទីរួមខេត្តកំពង់ធំចំនួន ២ កន្លែង (ក្នុងមួយរោងចក្រប្រើប្រាស់កម្លាំងពលកម្មពី ៥០០ ទៅ ២០០០ នាក់)។ |
| ៨) បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញតម្បាញ ចម្លាក់ ។ល។ ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១១ ឱ្យមាន ២កន្លែង ក្នុងទីរួមខេត្តកំពង់ធំ។ |
| ៩) កំណត់តម្លៃស្រូវឱ្យមានតម្លៃ (១ គីឡូក្រាមស្រូវ = ១/៤ នៃតម្លៃសាំង ១លីត្រ ) ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១១ នៅក្នុងខេត្តកំពង់ធំ ។ |

## ក.៥. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ស្ពឺ

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំងដប់នៅក្នុងខេត្ត កំពង់ស្ពឺ |
|---|
| ១) សូមជួយទប់ស្កាត់ បង្កាការកាប់បំផ្លាញព្រៃឈើនៅស្រុក គងពិសី ឱរ៉ាល់ ភ្នំស្រួច ថ្ពង [ឱ្យបាន ១០០%[៣]] ចាប់ពីត្រឹមឆ្នាំ ២០១០ និងសុំបង្កើតព្រៃសហគមន៍នៅតំបន់ភ្នំព្រះ ឃុំយាអង្គ ស្រុកថ្ពង ចំនួន ៣.៨៧៥ហិកតា នៅឆ្នាំ២០០៩ និងសុំអោយរដ្ឋបាលព្រៃឈើជួយរៀបចំសំណុំឯកសារ និងទទួលស្គាល់សហគមន៍ព្រៃឈើនៅឃុំ ទ័ពមាន ស្រុកថ្ពង។ |
| ២) សុំជួយដោះស្រាយដីសម្បទានសង្គមកិច្ចនៅឃុំអមលាំង ៨ភូមិ ១.៨៥០ហិកតា នៅឃុំយាអង្គ ៣ភូមិ ១.៤០០ហិកតា នៅឃុំមហាសាំង និងតាំងស្យា នៅតំបន់ អា សេ អូ ផ្ទៃដីស្រែ ៤២៩.២៧ហិកតា ដីចំការ ១១៥.៤៧ហិកតា (១០សហគមន៍) និងសុំដោះស្រាយវិវាទដីនៅភូមិព្រីង ឃុំរលាំងចក ស្រុកសំរោងទង។ សុំផ្តល់ប្លង់កម្មសិទ្ធដីនៅឃុំតាសាល់ ស្រុកឱរ៉ាល់។ |
| ៣) ផ្តល់ថ្នាំវ៉ាក់សាំង បង្កាជំងឺសត្វអោយបានគ្រប់គ្រាន់មួយឆ្នាំម្តង (ឬតាមជំនាញបច្ចេកទេស) និងគ្រប់តំបន់ និងសូមត្រួតពិនិត្យទីសត្តឃាតជារៀងរាល់ថ្ងៃអោយបានដិតដល់ចាប់ពីខែមេសា ឆ្នាំ២០០៩ តទៅ។ |
| ៤) លុបបំបាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ (ប្រដាប់ឆក់ត្រី) អោយមានប្រសិទ្ធភាពមួយរយភាគរយនៅក្នុង ឆ្នាំ ២០១០ និងលុបបំបាត់ការប្រមាញ់ និងបំពុលសត្វព្រៃអោយបានមួយរយភាគរយចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៥) បញ្ហាអនាម័យ : ប្រមូលសំរាមក្នុងផ្សារកំពង់ស្ពឺ និងក្នុងទីកស្ទឹងឱ្យស្អាត និងសណ្តាប់ធ្នាប់នៅក្នុងផ្សារឱ្យហើយ ឆ្នាំ ២០០៩ តទៅ។ |
| ៦) សុំឱ្យរដ្ឋជួយទិញកសិផលនៅពេលគ្មានទីផ្សារសម្រាប់ផលិតផលកសិកម្ម ឬពេលដែលតម្លៃកសិផលធ្លាក់ចុះដោយរដ្ឋត្រូវឱ្យតម្លៃថ្លៃជាងទីផ្សារ។ |
| ៧) តម្លើងប្រាក់បៀវត្សដល់មន្ត្រីរាជការ ជាពិសេសគ្រូបង្រៀន និងគ្រូពេទ្យពី ១០០ ដុល្លារ ឡើងទៅ ចាប់ពីឆ្នាំ ២០១០ និងផ្តល់ វគ្គបណ្តុះបណ្តាលដល់គ្រូតាមក៏រិត និងមុខជំនាញម្នាក់ៗឱ្យបានម្តងក្នុងមួយឆ្នាំនៅគ្រប់ភូមិសិក្សាចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៨) នៅគ្រប់មណ្ឌលសុខភាពត្រូវមានថ្នាំគ្រប់គ្រាន់ និងមានបុគ្គលិកជំនាញប្រចាំការគ្រប់ម៉ោងចាប់ពីចុងឆ្នាំ ២០០៩ និងបង្កើនការព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ។ |
| ៩) សុំឱ្យច្បាប់ប្រឆាំងអំពើពុករលួយចេញឱ្យបានឆាប់យ៉ាងយូរដើមឆ្នាំ ២០១០។ |
| ១០) សុំឱ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់ពីមូលដ្ឋាន រហូតដល់ថ្នាក់ខេត្តសុំឱ្យដោះស្រាយទំនាស់ដីធ្លីចាប់ពីខែមេសា ឆ្នាំ២០០៩ ជាពិសេសដី អា សេ អូ ដោះស្រាយឱ្យចប់នៅក្នុងឆ្នាំ ២០០៩ និងសុំឱ្យមានច្បាប់ផ្តន្ទាទោសដល់តុលាការ មន្ត្រីរាជការ យោធា ប៉ូលីស ប៉េអឹម នៅទូទាំងខេត្តកំពង់ស្ពឺដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ និងប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូកពីជនល្មើស ។ |

[៣] មានការពន្យល់បន្ថែមឱ្យកាន់តែច្បាស់ពីសិក្ខាកាមមួយចំនួនបន្ទាប់ពីសិក្ខាសាលា

## ក.៦. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពត

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង ១០ នៅក្នុងខេត្តកំពត |
|---|
| ១) ជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្ររាល់មួយឆ្នាំម្តងក្នុងចំណោម ៧ ស្រុករួមមានស្រុកទឹកឈូ ស្រុកឈូក ស្រុកដងទង់ ស្រុកកំពង់ត្រាច ស្រុកបន្ទាយមាស ស្រុកជុំគីរី និងស្រុកអង្គរជ័យ ចាប់ពីឆ្នាំ ២០០៩ ដល់ ២០១២ យ៉ាងយូរត្រូវស្តារអោយបានគ្រប់ស្រុក ។ |
| ២) ផ្តល់ការបណ្តុះបណ្តាលទំនាក់ទំនងទីផ្សារ និងបង្កើតទីផ្សារដល់កសិករ ព្រមទាំងបង្កើនពន្ធការនាំចូលនូវផលិតផលកសិកម្ម (អោយលើសពីពន្ធបច្ចុប្បន្ន) ពីខាងក្រៅដែលខេត្តកំពតមាន (ស្រូវ បន្លែ ដូង ពោត..) ចាប់ពីឆ្នាំ ២០០៩ ដល់ ២០១២។ |
| ៣) ចាប់ពីឆ្នាំ ២០០៩ ទៅ អាជ្ញាធរជលផលត្រូវតែទទួលស្គាល់ និងចុះបញ្ជីសហគមន៍នេសាទរបស់ប្រជាពលរដ្ឋដែលបានបង្កើតឡើងហើយបានដាក់ពាក្យទៅ និងបង្ក្រាបបទល្មើសនេសាទទាំងអស់អោយបាន [100%] ។ |
| ៤) ផ្តល់មេធាវីដល់ប្រជាពលរដ្ឋក្រីក្រដោយឥតគិតថ្លៃ ហើយ [តុលាការ] ស៊ើបអង្កេតរឿងក្តី និងបណ្តឹងអោយបានច្បាស់លាស់ដល់ទីកន្លែងគ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់នៅខេត្តកំពតចាប់ពីឆ្នាំ ២០១០តទៅ។ |
| ៥) ចាត់វិធានការតាមផ្លូវច្បាប់ម៉ឺងម៉ាត់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ កងកំលាំងប្រដាប់អាវុធ និងអ្នកមានអំណាចមួយចំនួនដែលឃុបឃិតជាមួយជនល្មើសកាប់បំផ្លាញព្រៃឈើដែលខុសច្បាប់ក្នុងខេត្តកំពត ចាប់ពីឆ្នាំ ២០០៩ តទៅ ឱ្យបាន ១០០%។ |
| ៦) តម្លៃសេវាទូរស័ព្ទ ការប្រើប្រាស់ប្រព័ន្ធនីមួយៗសូមបញ្ចុះតម្លៃទូរស័ព្ទត្រឹមតែ ៣សេន [ដុល្លារ] ក្នុងមួយនាទី [ឆ្លងប្រព័ន្ធ] យ៉ាងយូរត្រឹមឆ្នាំ ២០១០ និងនៅគ្រប់សាលាស្រុកទាំងអស់ត្រូវមានប្រព័ន្ធអ៊ីនធឺណែតសំរាប់ប្រជាពលរដ្ឋប្រើប្រាស់ជា សាធារណៈដោយឥតគិតថ្លៃនៅស្រុកទាំង ៧ និងក្រុងកំពត ខេត្តកំពត យ៉ាងយូរអោយបាននៅឆ្នាំ២០១១។ |
| ៧) បង្កើនប្រាក់បៀវត្សដល់គ្រូបង្រៀនឱ្យបានសមរម្យ គឺឱ្យបាន៤៥% ជារៀងរាល់ឆ្នាំដើម្បីលើកទឹកចិត្តគ្រូបង្រៀន។ |
| ៨) បង្កើតមជ្ឈមណ្ឌលសម្រាប់អប់រំកែប្រែអត្តចរិត និងបណ្តុះបណ្តាលវិជ្ជាជីវៈ (កាត់ដេរ ជួសជុលម៉ូតូ....) សម្រាប់ក្មេងអនាថា និងយុវជនគ្មានការងារធ្វើនៅក្រុងកំពតដោយកសាងអាគារចំនួន ២ខ្នង (សម្រាប់ប្រមូលក្មេង និងយុវជនអនាថា) ឱ្យរួចរាល់ក្នុងឆ្នាំ ២០១២។ |
| ៩) ស្តារឡើងវិញនូវទំនប់ទឹក ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត នៅចន្លោះឆ្នាំ២០០៩ ដល់ឆ្នាំ២០១០ និងសូមបញ្ចុះតម្លៃ ប្រេងសាំងត្រឹមតែ ២០០០ រៀលក្នុងមួយលីត និងប្រេងម៉ាសូតក្នុងតម្លៃ ១០០០ រៀលក្នុងមួយលីត្រ។ |
| ១០) គ្រប់ស្ថាប័នឥណទានត្រូវយកការប្រាក់ទាបជាង ១%ក្នុងមួយខែ និងត្រូវមានការបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋពីការប្រើប្រាស់លុយកម្ចី មុននឹងអនុញ្ញាតខ្ចីចាប់ពីឆ្នាំ ២០១០តទៅ។ |

## ក.៧. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកែប

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត កែប |
|---|
| ១) សុំអាជ្ញាធរខណ្ឌរដ្ឋបាលជលផល បង្ក្រាបបទល្មើសនេសាទខុសច្បាប់ នៅដែននេសាទសហគមន៍ (នៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ដូចជាទូកអួសឆក់ មួងកៃរ ក្រឡាល្អិត) និងដែននេសាទសមុទ្រខេត្តកែប និងបទល្មើសនេសាទអន្តរជាតិ អោយបាន ១០០% និងឱ្យបាននៅក្នុងឆ្នាំ២០០៩។ |
| ២) សុំមន្ទីរកសិកម្មខេត្តផ្តល់ការបណ្តុះបណ្តាលធនធានមនុស្សលើបច្ចេកទេសធ្វើជីកំប៉ុស ដាំដំណាំស្រូវ ដំណាំរួមផ្សំ និងការចិញ្ចឹមសត្វ (គោ ជ្រូក មាន់ ទា...) ដល់ប្រជាពលរដ្ឋទូទាំងខេត្តកែបឱ្យបានជារៀងរាល់ឆ្នាំ ដោយចាប់ផ្តើមនៅដើមឆ្នាំ២០១០។ |
| ៣) សុំមន្ទីរកសិកម្មខេត្តផ្តល់ពូជស្រូវដែលមានផ្លែល្អ និងពូជសត្វ (គោ ជ្រូក មាន់ ទា...) ដល់ប្រជាពលរដ្ឋដែលធ្វើកសិកម្មនៅទូទាំង ខេត្តកែប ឱ្យបាននៅដើមឆ្នាំ២០១០។ |
| ៤) សុំឱ្យរដ្ឋាភិបាលផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី តាមរយៈការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធដល់ប្រជាពលរដ្ឋដោយមិនគិតថ្លៃនៅទូទាំងខេត្តកែបឱ្យបាន ១០០% នៅក្នុងឆ្នាំ២០១០។ |
| ៥) សុំឱ្យមានមណ្ឌលសុខភាពនៅសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ចំនួន ១កន្លែង និង [បុគ្គលិក] ប្រកបដោយជំនាញវិជ្ជាជីវៈគ្រប់គ្រាន់ និងក្រមសីលធម៌ និងកុំឱ្យមានការបង់ប្រាក់ថ្លៃសេវាព្យាបាលឱ្យបាននៅចុងឆ្នាំ២០១០។ |
| ៦) សុំបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ (ជួសជុលម៉ូតូ កង់ ឡាន និងម៉ាស៊ីនទូក) ១ កន្លែងនៅក្នុងភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ឱ្យហើយនៅឆ្នាំ២០១២។ |
| ៧) សុំឱ្យអាជ្ញាធរមូលដ្ឋាន និងកំលាំងមានសមត្ថកិច្ចលុបបំបាត់ឱ្យបាន [១០០%] នូវបញ្ហាចំនួន ៣ ដូចជាក្មេងទំនើង គ្រឿងញៀន ល្បែងស៊ីសង នៅទូទាំងខេត្តកែបឱ្យបាននៅឆ្នាំ២០១០។ |
| ៨) សុំឱ្យអាជ្ញាធរខេត្តជួយជំរុញក្រុង [ស្រង់ស្ថិតិក្មេងតាមផ្ទះ] ដែលគ្រប់អាយុចូលរៀន និងក្មេងកំព្រាឱ្យបានចូលរៀនគ្រប់ៗគ្នា [អោយបាន ១០០%] នៅទូទាំងខេត្តកែប ចាប់ពីឆ្នាំ២០១០ នេះតទៅ។ |
| ៩) សុំអោយអាជ្ញាធរមូលដ្ឋានជួយសហការបង្កើតសហគមន៍ទេសចរណ៍ព្រៃកោងកាងមួយនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ចាប់ពីខែ ១០ ឆ្នាំ២០០៩ បញ្ចប់នៅក្នុងឆ្នាំ២០១០។ |
| ១០) ស្ពានប្រឡាយទឹក និងធ្វើទ្វារទឹកនៅក្នុងភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ប្រវែង ៥០០ម ឱ្យបាននៅដើមឆ្នាំ២០១០ និងផ្លូវលំ២ខ្សែ គឺ ខ្សែទី១ ពីចំណុចផ្លូវតាពីងដល់ស្រែយុល (ភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ)ខ្សែទី២ ពីផ្លូវជាតិលេខ៣៣ ដល់មាត់ព្រែក (ភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប) ឱ្យបាន និងបញ្ចប់នៅចុងឆ្នាំ២០១០។ |

## ក.៨. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកោះកុង

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ១០ នៅក្នុងខេត្ត កោះកុង |
|---|
| ១) សុំផ្លូវ (មានដាក់ស្ពាន និងបណ្ដាញលូ) ក្រាលគ្រួសក្រហម ចុះពីផ្លូវជាតិលេខ៤៨ ដល់ស្រុកថ្មបាំងប្រវែង ៣៥ គ.ម ទទឹង ១២ ម នៅស្រុកថ្មបាំង និងជួសជុលផ្លូវ លូ និងស្ពាន ពី ចាំយាម ទៅតំបន់ វ៉ងកចាក់ (ស្ថិតនៅឃុំ ប៉ាក់ខ្លង ស្រុក មណ្ឌលសីមា) ចំនួន ៦គ.ម ធ្វើអោយហើយក្នុងឆ្នាំ ២០១១។ |
| ២) ចែកដីសម្បទានសង្គមកិច្ចជូនគ្រួសារដែលគ្មានដីកសិកម្មចាប់ ពីឆ្នាំ២០០៩ នៅទូទាំង ៧ស្រុកក្នុងខេត្តកោះកុង។ |
| ៣) សុំអោយសមត្ថកិច្ច (ប៉ូលីស ប៉េអឹម) រួមសហការលុបបំបាត់ចរាចរគ្រឿងញៀនទាំងស្រុងនៅក្នុងខេត្តកោះកុង មុនឆ្នាំ២០១១។ |
| ៤) បញ្ចុះតម្លៃ ៤០ភាគរយ នៃតំលៃសេវាព្យាបាលបច្ចុប្បន្នតាមមន្ទីរពេទ្យ មណ្ឌលសុខភាព និងបុស្ដិ៍សុខភាពនៅទូទាំងខេត្ត ចាប់ពីចុងឆ្នាំ ២០០៩ តទៅ។ |
| ៥) សុំការបណ្ដុះបណ្ដាលបច្ចេកទេសដាំដំណាំ ដូចជាដំណាំស្រូវ និងដំណាំហូបផ្លែ (ធូរេន សាវម៉ាវ និងកៅស៊ូ) និងផ្ដល់ពូជដើម្បីដាំដំណាំជាពិសេសសុំអោយរដ្ឋាភិបាលជួយរកទីផ្សារដើម្បីលក់ផលិតផលទាំងនេះអោយបានចន្លោះឆ្នាំ២០០៩-២០១០ នៅស្រុកបូទុមសាគរ ស្រែអំបិល ថ្មបាំង និងកោះកុង។ |
| ៦) ជំរុញតំបន់សេដ្ឋកិច្ចពិសេសចាំយាម អោយមានដំណើរការនៅក្នុងឆ្នាំ ២០១១។ |
| ៧) សុំបុគ្គលិកពេទ្យយកចិត្តទុកដាក់ចំពោះអ្នកជម្ងឺក្រីក្រ (មានសីលធម៌វិជ្ជាជីវៈដោយព្យាបាលអ្នកជំងឺភ្លាមៗពេលទៅដល់មន្ទីរពេទ្យដោយមិនគិតពីថ្លៃព្យាបាល) តាមមន្ទីរពេទ្យ មណ្ឌលសុខភាព និងបុស្ដិ៍សុខភាពនៅទូទាំងខេត្ត ចាប់ពីចុងឆ្នាំ ២០០៩។ |
| ៨) សុំលូទឹកសងខាងផ្លូវលេខ៤៨ ដែលមានមុខកាត់ ៨តឹក (០.៨ ម) ចាប់ពីសាលាស្រុកមណ្ឌលសីមា ដល់មាត់សមុទ្រ ត្រូវធ្វើអោយហើយក្នុងឆ្នាំ ២០១២។ |
| ៩) សុំការបណ្ដុះបណ្ដាលបច្ចេកទេស និងពូជក្នុងការចិញ្ចឹមសត្វ (គោ ជ្រូក មាន់ ត្រី សត្វសមុទ្រ )តាមសហគមន៍ និងគ្រួសារ និងសុំផ្ដល់ថ្នាំបង្ការក្នុងការចិញ្ចឹមសត្វជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០០៩ នៅក្នុងស្រុកទាំង ៧។ |
| ១០) បង្កើនប្រាក់បៀវត្សរ៍ឱ្យដល់គ្រូបឋមសិក្សាដែលរស់នៅតាមសហគមន៍ក្នុងខេត្តអោយបានច្រើនជាងសែសិបម៉ឺនរៀល នៅឆ្នាំ ២០១២ទៅ។ |

## ក.៩. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តក្រចេះ

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត ក្រចេះ |
|---|
| ១) សុំឱ្យរាជរដ្ឋាភិបាលចេញប័ណ្ណកម្មសិទ្ធិដីធ្លី ជូនដល់ប្រជាពលរដ្ឋឱ្យបានទូទាំងខេត្តក្រចេះ [អោយបាន ១០០%] ចាប់ពី ឆ្នាំ២០១០ ដល់ឆ្នាំ២០១៣។ |
| ២) សុំឱ្យរាជរដ្ឋាភិបាលជួយលុបបំបាត់នូវឧបករណ៍នេសាទខុសច្បាប់គ្រប់ប្រភេទ ដូចជា ឆក់ ស្បៃមុង លបស្បៃ... នៅក្នុងព្រែក បឹង និងទន្លេក្នុងខេត្តក្រចេះ ឱ្យបាននៅក្នុង ឆ្នាំ២០១០ នេះតទៅ។ លុបបំបាត់ឱ្យបានការចិញ្ចឹមត្រីឆ្តោរ នៅទូទាំងខេត្តក្រចេះ ចាប់ពីខែ តុលា ឆ្នាំ២០០៩ នេះតទៅ។ |
| ៣) សុំឱ្យតុលាការមានការអនុវត្តច្បាប់ទាំងអស់ឱ្យមានប្រសិទ្ធិភាព ដោយកុំស៊ីសំណូកតាមគ្រប់រូបភាព និងកុំយកថវិកា [កណ្តាប់ក្តី] ពីជនរងគ្រោះ [ក្រីក្រ]។ សុំឱ្យអនុវត្តចាប់ពីខែតុលា ឆ្នាំ២០០៩ នេះតទៅ។ |
| ៤) ស្នើសុំឱ្យឃើញមានការដកហូត [តំណែង] និងការដាក់ពិន័យយ៉ាងធ្ងន់ស្របតាមច្បាប់ជាមូលដ្ឋានលើមន្រ្តីដែលបានឃើញថា ប្រព្រឹត្តអំពើពុករលួយលើវិស័យព្រៃឈើ ជលផល និងដីធ្លីនៅក្នុងខេត្តក្រចេះទាំងមូល ឱ្យបាននៅត្រឹមដើមឆ្នាំ២០១០ នេះតទៅ។ |
| ៥) សុំឱ្យឃើញមានការដាក់ពិន័យរដ្ឋបាល [អោយស្របតាមការពិន័យដែលមានចែងស្រាប់] ដល់បុគ្គលិកពេទ្យដែលមិនមានក្រមសីលធម៌ និងមិនគោរពនូវពេលវេលាធ្វើការនៅគ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកទូទាំងខេត្តក្រចេះឱ្យបានយ៉ាងយូរត្រឹមឆ្នាំ ២០១០។ |
| ៦)សុំឱ្យរាជរដ្ឋាភិបាលធ្វើការបែងចែកដីសម្បទានសេដ្ឋកិច្ច និងដីព្រៃសហគមន៍ នៅក្នុងភូមិច្រវ៉ា ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ ឱ្យបានដាច់ពីគ្នា យ៉ាងយូរនៅក្នុងឆ្នាំ២០០៩។ សុំឱ្យអាជ្ញាធរមានសមត្ថកិច្ចខេត្តក្រចេះជួយផ្តល់ដីសម្បទានសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋក្រីក្រ និងគ្មានដី (ដីលំនៅដ្ឋាន ដីកសិកម្ម) ស្របតាមអនុក្រឹត្យលេខ១៩ សុំឱ្យបានចាប់ពីខែតុលា ឆ្នាំ២០០៩ នេះតទៅ។ |
| ៧) សុំឱ្យរាជរដ្ឋាភិបាលបង្កើតរោងចក្រស្ករសចំនួន ០១កន្លែង ដែលត្រូវការកំលាំងពលកម្មចំនួន ១៥០-២០០នាក់ នៅក្នុងក្រុងក្រចេះ ខេត្តក្រចេះ ឱ្យបាននៅក្នុង ឆ្នាំ២០១០។ |
| ៨) សុំឱ្យមានការបំបាត់ការរើសអើងចំពោះស្រ្តីអោយបាន១០០% ក្នុងការបញ្ចេញមតិ [អោយមានការបញ្ចេញមតិនៅរាល់កិច្ចប្រជុំ] ចាប់ពីដើមឆ្នាំ២០១០ នេះតទៅនៅទូទាំងខេត្តក្រចេះ។ |
| ៩) សុំឱ្យរាជរដ្ឋាភិបាល និងសភាជំរុញអនុម័តច្បាប់ប្រឆាំងអំពើពុករលួយឱ្យបាននៅក្នុងចុងឆ្នាំ២០០៩។ ចាប់ពីឆ្នាំ ២០១០ សុំឱ្យពង្រឹងការផ្តន្ទាទោសដល់ជនប្រព្រឹត្តអំពើពុករលួយឱ្យបានត្រឹមត្រូវតាមនីតិវិធីកំណត់របស់ច្បាប់។ |
| ១០) សុំផ្លូវ ៤ខ្សែៈ ១ខ្សែក្រាលគ្រួសក្រហម ដែលមានប្រវែង ៣គម ទំហំ ៦ម នៅភូមិសោបក្រោម ឃុំសោប ស្រុក ព្រែកប្រសព្វ ខេត្តក្រចេះ ចាប់ផ្តើមដើមឆ្នាំ២០១០ ដល់ចុងឆ្នាំ២០១០។ ១ខ្សែ សុំជួសជុលប្រវែង ៥០០ម ក្រាលគ្រួសក្រហម ដែលមានទំហំ ៦ម នៅក្នុងភូមិច្រវ៉ា ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ ចាប់ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១១។ ១ខ្សែ ក្រាលគ្រួស ក្រហម ប្រវែង ៤០គម ទំហំ ៦ម នៅក្នុងភូមិក្រូច ឃុំដីរឺផុង រហូតដល់ ឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ ឱ្យបានចាប់ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១១។ ១ខ្សែ ជួសជុលក្រាលគ្រួសក្រហមប្រវែង ៣គម ទំហំ ៦ម នៅក្នុងភូមិព្រែករកា ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ឱ្យបានចប់ក្នុងដើមឆ្នាំ២០១០ ដល់ចុងឆ្នាំ២០១០។ |

## ក.១០. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តតាកែវ

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត តាកែវ |
| --- |
| ១) សុំឱ្យរាជរដ្ឋាភិបាលសម្រួលអត្រាការប្រាក់ឥណទានទាបដើម្បីអោយប្រជាពលរដ្ឋខ្ចីប្រាក់យកមកប្រើប្រាស់ក្នុងវិស័យកសិកម្ម ឱ្យមានការប្រាក់មកនៅត្រឹម១,៥% ក្នុង១ខែ ដែលបច្ចុប្បន្នការប្រាក់មានដល់ ៣%នៅក្នុងទូទាំង ខេត្ត ចាប់ពីខែ សីហា ឆ្នាំ២០០៩ នេះតទៅ។ ២) សុំអោយរាជរដ្ឋាភិបាល និងមន្ទីរកសិកម្មខេត្ត ជួយបណ្តុះបណ្តាលវិធីធ្វើជីកំប៉ុសទឹក និងកំប៉ុសគោកដល់កសិករគ្រប់ស្រុកនៅទូទាំង ខេត្តតាកែវអោយបានមួយដងក្នុងមួយឆ្នាំចាប់ពីឆ្នាំ២០០៩តទៅ ។ និងជីសម្រាប់បង្កបង្កើនផលមានដូចជា ជីគីមី និងជីសរីរាង្គសុំឱ្យបញ្ចុះតម្លៃ ៣០% នៃតម្លៃបច្ចុប្បន្ន និងមានគុណភាពល្អទូទាំង ១០ស្រុកក្នុងខេត្តតាកែវចាប់ពីខែ កក្កដា ឆ្នាំ ២០០៩។ |
| ៣) សុំឱ្យស្តារប្រឡាយទឹកប្រវែង ១៥គីឡូម៉ែត្រ ក្នុងភូមិតាយឹង ឃុំដូងខ្ពស់ ស្រុកបូរីជលសា ចាប់ធ្វើពីថ្នល់ ដល់ប្រឡាយលេខ ០១ និងធ្វើអោយរួចនៅឆ្នាំ ២០១១ និងសុំឱ្យជីកប្រលាយទឹកនៅឃុំក្រាំងលាវ ស្រុកបាទី ដែលមានប្រវែង ៣ គីឡូម៉ែត្រ និងមុខកាត់មានប្រវែង ៤ ម៉ែត្រ សូមធ្វើឱ្យរួចរាល់នៅខែ មិថុនា ឆ្នាំ ២០១០ ។ |
| ៤) សុំឱ្យរដ្ឋសភាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយក្នុងឆ្នាំ ២០១០ អោយបាន ។ |
| ៥) សុំជួយបង្កើនតម្លៃផលិតផលកសិកម្មស្រូវឱ្យបានមួយភាគបី នៃតម្លៃប្រេងសាំងក្នុងមួយលីត្រ ក្នុងស្រូវ១គីឡូក្រាម នៅក្នុងខេត្តតាកែវ ចាប់ពីខែសីហា ឆ្នាំ២០០៩។ |
| ៦) សុំឱ្យពេទ្យសត្វមានកម្មវិធីចុះចាក់ថ្នាំបង្ការអោយបាន២ដងក្នុង១ឆ្នាំ អោយបានទៀងទាត់ទៅតាមប្រភេទសត្វ មាន គោ ក្របី មាន់ ទា ជ្រូក ... នៅទូទាំង១០ស្រុក ក្នុងខេត្តតាកែវ ចាប់ពីខែកក្កដា ឆ្នាំ២០០៩ តទៅ។ |
| ៧) សុំឱ្យតភ្ជាប់ប្រព័ន្ធសារទូរគមនាគមន៍ ICT និងបង្កើតវគ្គបង្រៀនខ្លីៗអំពីបច្ចេកវិទ្យាព័ត៌មាននៅតាមវិទ្យាល័យទូទាំង ១០ស្រុក ក្នុងខេត្តតាកែវ ចាប់ពីឆ្នាំ២០១០ ។ |
| ៨) សុំអោយរដ្ឋាភិបាលបង្កើតសកលវិទ្យាល័យរដ្ឋមួយនៅខេត្តតាកែវ ហើយផ្តល់អាហារូបករណ៍យ៉ាងហោចណាស់ ៧០ភាគរយ សិស្សប្រលងជាប់ទី ១២ ក្នុងខេត្ត សុំអោយបានក្នុងឆ្នាំ២០១១។ |
| ៩) សុំឱ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកច្បាប់ និងជំនាញ [ទាក់ទងការងារ ]ដល់កងកំលាំងប្រដាប់អាវុធចាប់ពីឆ្នាំ ២០១០ នេះទៅ។ |
| ១០) សុំតប្រព័ន្ធទឹកស្អាត និងបញ្ចុះតម្លៃប្រើប្រាស់ ១០០០រៀល ក្នុង១ម៉ែត្រគូប នៅក្រុងដូនកែវ ចាប់ពីឆ្នោំ ២០០៩ ឱ្យហើយនៅឆ្នាំ ២០១០។ |

## ក.១១. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តបន្ទាយមានជ័យ

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត បន្ទាយមានជ័យ |
|---|
| ១) សុំឱ្យមន្ទីរពេទ្យបង្អែកទូទាំងខេត្តបន្ទាយមានជ័យទទួលព្យាបាលអ្នកជំងឺក្រីក្រដោយមិនយកកំរៃ និងយកចិត្តទុកដាក់ដល់អ្នកជំងឺ ព្រមទាំងសុំកាត់បន្ថយការបង់ថ្លៃសេវាព្យាបាលឱ្យបាន ៣៥% ចាប់ពីដើមឆ្នាំ២០១០ នេះតទៅ។ |
| ២) សុំឱ្យរាជរដ្ឋាភិបាលជួយជំរុញដល់សភាឱ្យអនុម័តច្បាប់ប្រឆាំងអំពើពុករលួយអោយបាននៅដើមឆ្នាំ២០១០ ។ |
| ៣) សុំឱ្យរាជរដ្ឋាភិបាលជួយបង្កើនប្រាក់បៀវត្សរ៍ដល់គ្រូឱ្យបាន ៤០% [ក្នុងមួយឆ្នាំរហូតប្រាក់ខែកើនសមល្មមសំរាប់ជីវភាព] ព្រមទាំងផ្តល់កន្លែងស្នាក់នៅដល់គ្រូមកពីឆ្ងាយ យ៉ាងតិចមួយសាលាឱ្យបាន ២បន្ទប់ ឱ្យបានចាប់ពីឆ្នាំ២០១០ នេះតទៅ។ |
| ៤) សុំឱ្យរដ្ឋាភិបាលជួយទប់ស្កាត់ការកាប់ព្រៃឈើនៅតំបន់ស្វាយចេក និងតំបន់ភ្នំដងរែក នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យឱ្យបាន ១០០% ដែលចាប់អនុវត្តពីខែធ្នូ ឆ្នាំ២០០៩ តទៅ។ |
| ៥) សុំរាជរដ្ឋាភិបាលជួយបញ្ចុះតម្លៃអគ្គិសនីឱ្យមកត្រឹមតែ ៦០០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ទូទាំងខេត្តបន្ទាយមានជ័យ ចាប់ពីខែមករា ឆ្នាំ២០១០ នេះតទៅ។ |
| ៦) សុំរាជរដ្ឋាភិបាលជួយឱ្យមានរោងចក្រកាត់ដេរ នៅក្នុងក្រុងប៉ោយប៉ែត (នៅភូមិគីឡូម៉ែត្រលេខ៤ សង្កាត់ ប៉ោយប៉ែត ក្រុង ប៉ោយប៉ែត) អាចប្រើប្រាស់កម្លាំងកម្មករប្រហែល ១០០០នាក់ ចាប់ដំណើរការពីឆ្នាំ២០១០ នេះតទៅ។ |
| ៧) សុំរាជរដ្ឋាភិបាលជួយជួសជុលផ្លូវលំចំនួន ៦ខ្សែ មានដូចជា ខ្សែទី១ ពីភូមិព្រៃមាន់ ទៅទីរួមស្រុកភ្នំស្រុក មានប្រវែង ១៧គម និងទទឹង ៧ម។ ខ្សែទី២ ពីឃុំរហាត់ទឹក ទៅឃុំសឿ ក្នុងស្រុកមង្គលបុរី ដែលមានប្រវែង ១០គម ទទឹង ៥ម ។ ខ្សែទី៣ ពីទីរួមស្រុកមង្គលបុរី ទៅឃុំស្រះរាំង ប្រហែល ១៥គម និងទទឹង ៧ម។ ខ្សែទី៤ ពីទីរួមស្រុកស្វាយចេក ទៅឃុំតាផូ មានប្រវែង ១០គម និង ទទឹង ៦ម។ ខ្សែទី៥ ភូមិចក សង្កាត់ព្រះពន្លា មានប្រវែង ៣០០០ម និង ទទឹង ៦ម។ ខ្សែទី៦ ចូល ក្រុមទី៥ ភូមិ១ សង្កាត់ព្រះពន្លា ប្រវែង ១០០ម ទទឹង ២ម ហើយផ្លូវទាំងអស់នេះ សុំឱ្យចាប់កសាងនៅក្នុងដើមឆ្នាំ២០១០ បញ្ចប់នៅក្នុងចុងឆ្នាំ២០១០។ |
| ៨) សំណូមពរដល់ក្រសួងសុខាភិបាលចាត់វិធានការជួយពង្រឹងដល់បុគ្គលិកសុខាភិបាលឱ្យគោរពតួនាទី និងឱ្យមានក្រមសីលធម៌ដល់អ្នកជំងឺ និងសុំជួយបង្កើនប្រាក់ខែបុគ្គលិកពេទ្យឱ្យបាន៤០% [ក្នុងមួយឆ្នាំរហូតប្រាក់ខែកើនសមល្មមសំរាប់ជីវភាព] នៅក្នុងខេត្តបន្ទាយមានជ័យ ចាប់ពីដើមឆ្នាំ២០១០ នេះតទៅ។ |
| ៩) សុំឱ្យរដ្ឋាភិបាលជួយរកទីផ្សារសំរាប់លក់កសិផលនៅទូទាំងខេត្តបន្ទាយមានជ័យ ឱ្យមានតម្លៃប្រហាក់ប្រហែលប្រទេសជិតខាង ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ១០) សុំឱ្យរាជរដ្ឋាភិបាលជួយលើកស្ទួយតួនាទីរបស់ស្ត្រីដែលមានសមត្ថភាពក្នុងការដឹកនាំនៅគ្រប់លំដាប់ថ្នាក់ក្នុងខេត្តបន្ទាយមានជ័យឱ្យបាន ៥០% ចាប់ពីឆ្នាំ២០១០នេះតទៅ។ |

## ក.១២. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តប៉ៃលិន

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត ប៉ៃលិន |
|---|
| ១) សុំរកទីផ្សារសេរីសំរាប់លក់ផលិតផលកសិកម្មដូចជា ស្រូវ ដំឡូងមី សណ្តែកបាយ ពោត... យ៉ាងហោចណាស់មួយគីឡូក្រាមជាមធ្យម ឱ្យបាន ២៥% នៃតម្លៃសាំង ១លីត្រ នៅខេត្តប៉ៃលិន ចាប់ពី ខែ វិច្ឆិកា ឆ្នាំ២០០៩ នេះតទៅ។ |
| ២) សុំឱ្យមានការនាំចេញ ចូល កសិផល និងយកពន្ធតិចជាងតម្លៃបច្ចុប្បន្នប្រហែល ៥០% នៅក្នុងខេត្តប៉ៃលិន ចាប់ពីឆ្នាំ២០០៩។ |
| ៣) ត្រូវឱ្យមានការត្រួតពិនិត្យ និងបណ្តុះបណ្តាលតាមបច្ចេកទេសដោយមន្ទីរកសិកម្មខេត្ត។ ពូជជីណាំកសិកម្មដែលនាំចូលអោយមានតម្លៃទាបជាងតម្លៃបច្ចុប្បន្នដល់កសិករក្នុងខេត្តប៉ៃលិន ចាប់ពីឆ្នាំ២០១០ នេះតទៅ។ |
| ៤) សុំឱ្យមានប្រឡាយទឹកនៅឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅដែលប្រឡាយមានប្រវែង ៣០គម ទំហំ មាត់លើ ៩ម៉ែត្រ ពីចំណុចភូមិទំនប់ដល់ទីប្រជុំជនឃុំស្ទឹងត្រង់ ចាប់ពីឆ្នាំ២០១០ ដល់២០១២។ |
| ៥) សុំ ផ្លូវក្រួសក្រហម និងស្ពាន ចំនួន ០៤ខ្សែ ចាប់ពីឆ្នាំ២០១០ ដល់២០១៥<br>- ទី១ នៅក្នុងសង្កាត់អូរតាវៅ ពីភូមិប៉ាងរលឹម ដល់ភូមិក្រចាប់លើ ប្រហែល ១២គម ។<br>- ទី២ ក្នុងឃុំអូរអណ្តូងចាប់ភូមិថ្មល់កែង ដល់ភូមិកូនដំរី ឃុំស្ទឹងត្រង់ មានប្រវែងប្រហែល ១៨គម។<br>- ទី៣ ពីភូមិភ្នំកុយ ដល់ភូមិស្រែអន្ទាក់ ក្នុងឃុំសាលាក្រៅ ប្រវែង ៨គម។<br>- ទី៤ សុំស្ពានមួយកន្លែងនៅ ភូមិបរតាំងស៊ូ សង្កាត់បយ៉ាខា។ |
| ៦) សុំតម្លើងប្រាក់ឧបត្ថម្ភចាប់ពីមេភូមិ មេឃុំ សុំតម្លើងឱ្យបាន ១០០% [នៃប្រាក់ឧបត្ថមបច្ចុប្បន្ន]។ សំរាប់មន្ត្រីរាជការគ្រប់ស្ថាប័នក្នុងខេត្តប៉ៃលិន សុំតម្លើងប្រាក់ខែប្រចាំខែឱ្យបាន ៤០% ជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១០នេះតទៅ។ |
| ៧) សុំឱ្យមានឥណទានដែលមានការប្រាក់ទាប (១% ក្នុង១ខែ) សំរាប់ប្រជាពលរដ្ឋ ដែលជាកសិករខ្ចីនៅក្នុងខេត្តប៉ៃលិន ពីឆ្នាំ២០១០ ដល់២០១៥។ |
| ៨) សុំឱ្យមានការព្យាបាលជំងឺដោយពុំយកកំរៃសេវាព្យាលបាលក្នុងមន្ទីរពេទ្យបង្អែក ក្នុងខេត្តប៉ៃលិន ឬបញ្ចុះតំលៃ ៥០%ពីតម្លៃបច្ចុប្បន្នឱ្យបាននៅក្នុងឆ្នាំ២០១០។ |
| ៩) សុំឱ្យបង្កើតច្បាប់ប្រឆាំងអំពើពុករលួយឱ្យបាននៅចុងឆ្នាំ២០០៩ ខាងមុខនេះតទៅ។ |
| ១០) សុំតម្លើងប្រាក់បៀវត្សរ៍គ្រូបង្រៀនយ៉ាងតិច ៤០ម៉ឺនរៀលក្នុងមួយខែ បើកឱ្យបានទៀតទាត់រៀងរាល់ខែនៅក្នុងខេត្តប៉ៃលិន ចាប់ពីឆ្នាំ២០១០។ |

## ក.១៣. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តបាត់ដំបង

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត បាត់ដំបង |
|---|
| ១) ស្នើសុំរកទីផ្សារដើម្បីលក់ផលិតផលកសិកម្មនៅក្នុងស្រុក និងក្រៅស្រុក ដូចជា ស្រូវ ពោត ដំឡូងមី ល្ង បន្លែផ្លែឈើ...។ល។ ជាពិសេស សុំឱ្យតម្លៃស្រូវ ១គីឡូក្រាម ស្មើនឹងតម្លៃ ៤០% នៃតម្លៃសាំង ១លីត្រ ចាប់ពី ខែ តុលា ឆ្នាំ២០០៩ នេះតទៅ។ |
| ២) ស្នើសុំឱ្យបង្កើតមជ្ឈមណ្ឌលប្រឹក្សាយោបល់ និងដោះស្រាយបញ្ហាលើដំណាំកសិកម្ម និងសត្វចំនួន ១កន្លែង ក្នុងស្រុកមោងឫស្សី អោយហើយនៅចុងឆ្នាំ២០១២ តទៅ។ |
| ៣) សុំឱ្យមានការកំណត់តម្លៃរថយន្តឈ្នួលដឹកនាំអ្នកដំណើរ (សំរាប់ថ្ងៃបុណ្យឱ្យដូចថ្ងៃធម្មតា)។ សុំឱ្យមានកំណត់តម្លៃប្រេងសាំង ម៉ាស៊ូត និងជីគីមី ឱ្យសមាមាត្រទៅនឹងប្រទេសជិតខាងចាប់ពីខែ សីហា ឆ្នាំ២០០៩ នេះតទៅ។ |
| ៤) សុំបង្កើតរោងចក្រក្រចៅនៅក្នុងស្រុកឯកភ្នំ និងរោងចក្រទឹកក្រូចនៅក្នុងក្រុងបាត់ដំបងអោយដំណើរការឡើងវិញរបស់ខេត្តបាត់ដំបង ឱ្យហើយនៅចុង ឆ្នាំ២០១១។ សុំបង្កើតរោងចក្រកាត់ដេរចំនួន ១កន្លែង នៅក្នុងក្រុងបាត់ដំបង ខេត្តបាត់ដំបង ចាប់ផ្តើមក្នុងឆ្នាំ ២០១០ ដល់ឆ្នាំ២០១១។ |
| ៥) សុំអោយបង្កើតសហគមន៍នេសាទ និងសហគមន៍ព្រៃឈើ នៅស្រុកមោងឫស្សី និងស្រុកគាស់ក្រឡឱ្យបានក្នុងអំឡុង ឆ្នាំ២០០៩ រហូតដល់ចុងឆ្នាំ ២០១០ និងអនុវត្តតទៅ [រដ្ឋាភិបាលដឹកនាំបង្កើតសហគមន៍ រួចទើបប្រគល់អោយប្រជាពលរដ្ឋ]។ |
| ៦) សុំរដ្ឋាភិបាលកំណត់ជាគោលការណ៍ឱ្យច្បាស់ ជំរុញ និងលើកទឹកចិត្តស្ត្រីចូលរួមក្នុងថ្នាក់ដឹកនាំថ្នាក់ភូមិ ឃុំ ស្រុក ខេត្ត និងជាតិឱ្យបាន ៤០% ក្នុងខេត្តបាត់ដំបង ចាប់ពីឆ្នាំ២០១០ នេះតទៅ។ |
| ៧) ស្នើសុំឱ្យរដ្ឋាភិបាលបោសសំអាតមីន ក្នុងស្រុកគាស់ក្រឡ ឃុំឆ្នាល់មាន់ ភូមិឆ្លាក ដើម្បីផ្តល់ដីសម្បទានសង្គមកិច្ចដល់ប្រជាពលរដ្ឋក្រីក្រ ចំនួន ៥ហិចតា ក្នុងមួយគ្រួសារអោយបានគ្រប់គ្រួសារដើម្បីធ្វើកសិកម្មក្នុងស្រុកគាស់ក្រឡ ចាប់ពីខែសីហា ឆ្នាំ២០០៩ នេះតទៅ។ |
| ៨) សុំឱ្យរដ្ឋាភិបាលមានការផ្តល់ប្រាក់កម្ចីដល់ប្រជាពលរដ្ឋដើម្បីយកទៅធ្វើកសិកម្មក្នុងអត្រាការប្រាក់ទាបប្រហែល ១% ក្នុងមួយឆ្នាំ នៅក្នុងខេត្តបាត់ដំបង ចាប់ពីចុងឆ្នាំ២០០៩ នេះតទៅ។ |
| ៩) សុំសាងសង់ស្ពានថ្មីមួយ (ជំនួសស្ពានចាស់) ធ្វើពីបេតុង មានបណ្តោយប្រវែង ១២ម៉ែត្រ ទទឹង ៨ម៉ែត្រ ក្នុងភូមិខ្នាចរមាស ឃុំខ្នាចរមាស ស្រុកបវេល ខេត្តបាត់ដំបង ចាប់ផ្តើមពីចុងឆ្នាំ២០០៩ ដល់ចុងឆ្នាំ២០១០។ |
| ១០) សុំឱ្យសភាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយឱ្យបាននៅដើមឆ្នាំ២០១០។ |

## ក.១៤. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រៃវែង

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង ១០ នៅក្នុងខេត្ត ព្រៃវែង |
|---|
| ១) សុំកាត់បន្ថយរាល់បទល្មើសសង្គមដូចជា ឆក់ប្លន់ ល្បែងស៊ីសង ក្រុមក្មេងទំនើង គ្រឿងញៀន ជួញដូរកុមារ បានរំលោភ កុមារ និងបទល្មើសនេសាទឆក់ត្រីអោយបាន ៧០% នៃឆ្នាំ២០០៩ នៅទូទាំងខេត្តព្រៃវែងដោយចាប់ផ្តើមក្នុងឆ្នាំ២០០៩តទៅ។ |
| ២) សុំឱ្យក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្មជួយរកទីផ្សារសហគមន៍ដើម្បីលក់ផលិតផលស្រូវ ពោត សណ្តែក ល្ង ចំនួន ៦កន្លែង សំរាប់ប្រជាពលរដ្ឋនៅក្នុងស្រុកស៊ីធរកណ្តាល ស្រុកពាមរ ស្រុកបាភ្នំ ស្រុកកំពង់ត្របែក ស្រុកស្វាយអន្ទរ និងក្រុងព្រៃវែងឱ្យបាននៅក្នុងឆ្នាំ ២០១១។ សុំឱ្យរាជរដ្ឋាភិបាលបន្ថយការយកពន្ធជីនាំចូលក្នុងប្រទេសទាបជាង ៥០% នៃតម្លៃបច្ចុប្បន្នចាប់ពីឆ្នាំ២០១០ តទៅ។ និងសុំឱ្យមន្ទីរកសិកម្មជួយផ្តល់បច្ចេកទេសសមស្រប (ធ្វើជីកំប៉ុស និងដាំបន្លែ) ដល់ប្រជាពលរដ្ឋក្នុងខេត្តព្រវែង។ |
| ៣) សុំប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង ជួយសំរួលដល់មន្ទីរពេទ្យបង្អែកព្រៃវែង និងអ្នកលឿង ដូចជា:<br>- សុំឱ្យគ្រូពេទ្យព្យាបាលសិនទើបយកប្រាក់ជាក្រោយពីអ្នកជំងឺ<br>- សុំឱ្យមានថ្នាំគ្រប់គ្រាន់សំរាប់ព្យាបាល<br>- សុំកាត់បន្ថយសេវាព្យាបាលឱ្យបាន ៥០% នៃថ្លៃសេវាបច្ចុប្បន្ន ចាប់ពីចុងឆ្នាំ២០០៩ តទៅ។ |
| ៤) សុំឱ្យក្រសួងកសិកម្មសហការជាមួយ អង្គការនានា ដើម្បីបង្កើតសហគមន៍ ចិញ្ចឹមសត្វ ដូចជា គោ ជ្រូក ត្រី មាន់... និងផ្តល់ពូជ ស្មៅ ចំណីសត្វដល់ [ សហគមន៍ ] នៅទូទាំងខេត្តព្រៃវែងឱ្យបាននៅក្នុងឆ្នាំ២០១០។ |
| ៥) សុំអោយមានការពន្លឿននៃការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយឱ្យបានត្រឹមឆ្នាំ២០១០។ |
| ៦) សុំឱ្យរាជរដ្ឋាភិបាលជួយជួសជុលផ្លូវកៅស៊ូ ប្រវែង ១០០ម ទទឹង ៨ម នៅភូមិលេខ៣ សង្កាត់កំពង់លាវ ខេត្តព្រៃវែង (ផ្លូវក្រោយវត្តសំសមី ចូលផ្សារ) ចាប់ផ្តើមពីដើមឆ្នាំ ២០១០ និងបញ្ចប់នៅឆ្នាំ២០១០។<br>- សុំជួសជុលផ្លូវគ្រួសក្រហម ប្រវែង ១៣គម ពីចំណុចភូមិពានា ឃុំអំពិលក្រៅ ដល់ភូមិដើមថ្នឹង ឃុំព្រៃដើមថ្នឹង ស្រុកស៊ីធរកណ្តាល ចាប់ពីឆ្នាំ២០១០ បញ្ចប់ ១០០% ក្នុងឆ្នាំ២០១១។<br>- សុំជួសជុលផ្លូវគ្រួសក្រហម ប្រវែង ១៨០០ម ពីផ្លូវជាតិលេខ ១១ ក្នុងភូមិ និគមព្រះសុរាម្រឹតសីហនុ ឃុំបាបោង ស្រុកពាមរ ខេត្តព្រៃវែង ចាប់ពីឆ្នាំ២០១០ បញ្ចប់ ១០០% ក្នុងឆ្នាំ២០១១។ |
| ៧) សុំរាជរដ្ឋាភិបាលជួយបង្កើតរោងចក្រកាត់ដេរឱ្យបានគ្រប់ស្រុក (មួយស្រុក មួយកន្លែង) នៅក្នុងខេត្តព្រៃវែងឱ្យបានចាប់ពី ឆ្នាំ២០១០ ដល់ឆ្នាំ ២០១២។ |
| ៨) សុំឱ្យអភិបាលនៃគណៈអភិបាលខេត្តបំពាក់អំពូលភ្លើងគ្រប់ដងវិថីទាំងអស់នៅក្នុងក្រុងព្រៃវែង ខេត្តព្រៃវែង ចាប់ពីដើមឆ្នាំ ២០១០ បញ្ចប់ ក្នុងនៅចុងឆ្នាំ២០១០។ |
| ៩) ពេលបង្កើតរោងចក្របានហើយសុំឱ្យរាជរដ្ឋាភិបាលជួយបង្កើនប្រាក់បៀវត្សរ៍ដល់កម្មកររោងចក្រឱ្យបានចំនួន ១០០ដុល្លារ ក្នុងមួយខែ ឡើងទៅចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២។ |
| ១០) សុំតម្លើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការ (គ្រូបង្រៀន និងគ្រូពេទ្យ) អោយបានចាប់ពី ៤០ម៉ឺនរៀល ឡើងទៅ ចាប់ផ្តើមនៅខែ១១ ឆ្នាំ២០០៩ នេះតទៅ នៅទូទាំងខេត្តព្រៃវែង។ |

## ក.១៥. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តពោធិ៍សាត់

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង ១០ នៅក្នុងខេត្ត ពោធិ៍សាត់ |
|---|
| ១) - ស្ពានប្រឡាយពីក្បាលហុង(ឃុំវាល) ស្រុកកណ្ដៀងទៅស្រុកបាកាន ១ ខ្សែ ដោយចាប់ផ្ដើមពីឆ្នាំ ២០១០ដល់ឆ្នាំ ២០១៣<br>- ស្ពានប្រឡាយ ២ខ្សែ ចាប់ពីសង្កាត់ផ្ទះព្រៃទៅ ឃុំស្វាយដូនកែវ ស្រុកបាកាន និងមួយកន្លែងទៀតនៅ ភូមិប្រឡាយធំ សង្កាត់ព្រៃញី ទៅដល់ស្រុកក្រគរខេត្តពោធិ៍សាត់ ដោយចាប់ផ្ដើមកសាងចាប់ពី ឆ្នាំ ២០១០ ដល់ ២០១២ និងស្ពានប្រឡាយនេះ ក្នុងរយៈពេល ២ឬ ៣ឆ្នាំម្ដង។ |
| ២) សុំអោយរដ្ឋសភាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ហើយអោយមានប្រសិទ្ធិភាពក្នុងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយអោយបាន ១០០% អោយបាននៅចុងឆ្នាំ ២០០៩ ។ |
| ៣) - សុំបញ្ចុះតំលៃសេវាព្យាបាលនៅមន្ទីរពេទ្យខេត្តពោធិ៍សាត់ទាំងអស់(សំរាប់រដ្ឋ)៥០%នៃតំលៃបច្ចុប្បន្ន<br>- សុំអោយបុគ្គលិកពេទ្យប្រចាំការ២៤ម៉ោង ហើយបុគ្គលិកនីមួយៗត្រូវមានអាកប្បកិរិយារួសរាយរាក់ទាក់ មិនរើសអើង ចំពោះអ្នកជំងឺក្រីក្រ។ មានរថយន្តសង្គ្រោះបន្ទាន់ដោយឥតគិតថ្លៃ (គ្រប់ស្រុកទាំងប្រាំមួយ) នៅគ្រប់មណ្ឌលសុខភាពស្រុក និងបុគ្គលិកសុខាភិបាលនៅតាមមូលដ្ឋានត្រូវមានជំនាញវិជ្ជាជីវៈពិតប្រាកដ ចាប់ពីឆ្នាំ ២០១០នេះតទៅ។ |
| ៤) ស្នើសុំពេលដែលវារីអគ្គិសនីខេត្តពោធិ៍សាត់ដំណើរការ សុំអោយតំលៃអគ្គិសនី ១ គីឡូវ៉ាត់ម៉ោងក្រោមតំលៃ ១០០០រៀល។ |
| ៥) សុំអោយស្ថាប័នតុលាការខេត្តពោធិ៍សាត់ ចាត់វិធានការដោះស្រាយរាល់បណ្ដឹងរបស់ប្រជាពលរដ្ឋអោយបានឆាប់រហ័សទៅតាមនីតិវិធីច្បាប់ប្រកបដោយភាពយុត្តិធម៌អោយបាន១០០% ដោយមានការទទួលស្គាល់ទាំងភាគីចាញ់ និងភាគីដែលឈ្នះអោយបានចាប់ពីពេលនេះតទៅ ។ |
| ៦) គ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យក្នុងខេត្តពោធិ៍សាត់ កុំយកប្រាក់មុនការព្យាបាលនិងបន្ថយតំលៃសេវាមកត្រឹម៣០% នៃតំលៃបច្ចុប្បន្នចាប់ពីពេលនេះតទៅ ។ |
| ៧) សុំពូជស្រូវទិន្នផលខ្ពស់ (ស្រូវសុម៉ាលីប៊ុនវ៉ានីហ៊ុនសែន) ដែលក្នុង ១ ឆ្នាំ ធ្វើបាន ២ ដង អោយគ្រប់កសិករក្រីក្រ ក្នុង ១ គ្រួសារ ២៥ គីឡូក្រាម នៅទូទាំងខេត្តពោធិ៍សាត់អោយបានចាប់ពីខែ ១ ឆ្នាំ ២០១០ តទៅ។ |
| ៨) សុំបង្កើតសាលាសកលវិទ្យាល័យ(រដ្ឋ)ស្ថិតនៅក្រុងពោធិ៍សាត់ ចំនួន ១ខ្នង ពីរជាន់ មាន ៣០បន្ទប់ ហើយមានឧបករណ៍ (សំភារៈសិក្សា) ប្រើប្រាស់គ្រប់គ្រាន់ ចាប់ផ្ដើមកសាងពីឆ្នាំ ២០១០ និងបញ្ចប់នៅឆ្នាំ ២០១១ ព្រមទាំងបង្កើតមជ្ឈមណ្ឌលបង្ហាត់ ការងារដើម្បីធានាដល់សិស្ស-និស្សិតនៅពេលបញ្ចប់ការសិក្សាត្រូវឱ្យមានការងារធ្វើ។ |
| ៩) សុំតំលើងប្រាក់បៀវត្សគ្រូបង្រៀននៅខេត្តពោធិ៍សាត់គ្រូបឋមសិក្សាដល់វិទ្យាល័យបន្ថែម ៥០%នៃប្រាក់ខែបច្ចុប្បន្នចាប់ពីដើមឆ្នាំ ២០១០តទៅ។ ផ្ដល់ប្រាក់លើកទឹកចិត្តសំរាប់គ្រូប្រជុំជនអោយបាន៥០% នៃប្រាក់ខែបច្ចុប្បន្ន និងបន្ថែម ១០០% នៃប្រាក់លើកទឹកចិត្តបច្ចុប្បន្នសំរាប់គ្រូនៅតំបន់ដាច់ស្រយាល ។ |
| ១០) សូមបញ្ឈប់ការស៊ីសំណូកគ្រប់រូបភាពក្នុងប្រព័ន្ធយុត្តិធម៌គ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងប្រព័ន្ធយុត្តិធម៌ក្នុងខេត្តពោធិ៍សាត់ អោយបាន ១០០% (ស្ថាប័នពាក់ព័ន្ធ តុលាការ ប៉ូលីស ប៉េអ៊ឹម ជលផល រដ្ឋបាលព្រៃឈើ ស្ថាប័នគយ) ដោយចាប់អនុវត្ត ចាប់ពីពេលនេះ តទៅ ។ |

## ក.១៦. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រះវិហារ

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត ព្រះវិហារ** |
| --- |
| ១) សុំអោយមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលតភ្ជាប់បណ្តាញអគ្គីសនីដល់ប្រជាពលរដ្ឋទូទាំងខេត្តព្រះវិហារ អោយបានប្រើប្រាស់គ្រប់គ្រាន់ និងមានតម្លៃត្រឹម ១០០០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ចាប់ពីឆ្នាំ២០០៩ បញ្ចប់ក្នុង ឆ្នាំ២០១៣។ សុំមន្ទីរឧស្សាហកម្មរ៉ែ និថាមពលជួយតបណ្តាញអគ្គិសនីពីស្ទឹងត្រែងមកព្រះវិហារឱ្យបានរួចរាល់ក្នុង ឆ្នាំ២០១០។ |
| ២) សុំមន្ទីរកសិកម្មជួយទប់ស្កាត់ការប្រព្រឹត្តបទល្មើសនេសាទ ដូចជាការប្រើថ្នាំបំពុល ម៉ាស៊ីនឆក់ ការដាក់ដៃ នៅគ្រប់រដូវនៅតាមដងស្ទឹងសែន អនុវត្តឱ្យបាន ១០០% ចាប់ពីឆ្នាំ២០០៩ នេះតទៅ។ |
| ៣) សុំផ្លូវមាន ចំនួន ៣ខ្សែ ដែលខ្សែទី១ ក្រាលកៅស៊ូ មានប្រវែង ៨០គម ទទឹង ១៥ម ចាប់ពីទីរួមខេត្ត ដល់ស្រុកឆែប ចាប់ពី ឆ្នាំ២០១០ បញ្ចប់ក្នុងឆ្នាំ២០១២។ ខ្សែទី២ផ្លូវលំដែលមានក្រាលគ្រួសក្រហមចាប់ពីកុងស៊ីចាស់ ទៅភូមិខ្យងហោង ក្រុងព្រះវិហារ ដែលមានប្រវែង ២គម ទទឹង ៧ម ចាប់ផ្តើមពីឆ្នាំ២០១០ អោយរួចនៅឆ្នាំ ២០១១។ ខ្សែទី៣ ផ្លូវលំក្រាលគ្រួសក្រហម ចាប់ពីភូមិគូលែនជើងដល់ភូមិព្យូរជ្រូក ស្រុកគូលែន ប្រវែង ៣គ.ម ទទឹង ៧ម អោយរួចនៅឆ្នាំ ២០១១។ សុំស្ថាបនាលូតាមផ្លូវ ក្នុងក្រុងព្រះវិហារ សង្កាត់កំពង់ប្រណាក ដែលមានមុខកាត់ ០,៨ម អោយ បាន១០០% ចាប់កសាងពីដើមឆ្នាំ២០១០ និងបញ្ចប់ចុងឆ្នាំ២០១០។ |
| ៤) សុំឱ្យមន្ទីរពាណិជ្ជកម្ម ជួយរកទីផ្សារនាំចេញផលិតផលកសិកម្ម ដោយ ស្រូវ និងសណ្តែកសៀង ឱ្យមានតំលៃទាបបំផុតត្រឹម ១០០០រៀល ក្នុងមួយគីឡូក្រាមស្រូវ ។ និងសណ្តែកទាបបំផុតត្រឹម ២៥០០រៀល ក្នុងមួយគីឡូក្រាម នៅទូទាំងខេត្តព្រះវិហារ ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៥) សុំឱ្យមន្ទីរបរិដ្ឋានសហការជាមួយស្ថាប័នពាក់ព័ន្ធជួយថែរក្សាព្រៃឈើនៅតំបន់ជួរភ្នំត្បែងក្នុងស្រុកសង្គមថ្មី ស្រុកគូលែន ស្រុកត្បែងមានជ័យ និងស្រុករវៀង ដោយទប់ស្កាប់បទល្មើសកាប់បំផ្លាញព្រៃឈើឱ្យបាន១០០% នៅក្នុងខេត្តព្រះវិហារ ដោយអនុវត្តចាប់ពីឆ្នាំ ២០០៩ តទៅ។ |
| ៦) សុំមន្ទីរសូរិយោដី និងផ្នែកពាក់ព័ន្ធផ្តល់ដីស្រែដល់គ្រួសារក្រីក្រ ដោយមួយគ្រួសារ ៥ហិចតា នៅក្នុងនៅភូមិគោកបេង សង្កាត់កំពង់ប្រណាក់ ប្រហែល៥០គ្រួសារ និងនៅក្នុងភូមិឆែបខាងលិច ឃុំឆែបមួយ ស្រុកឆែប ៥០គ្រួសារ និងដីចំការចំនួន ៨០គ្រួសារទៀតនៅភូមិអូរក្លែងពណិ សង្កាត់ប៉ាលហាល ក្រុងព្រះវិហារឱ្យបានក្នុងឆ្នាំ២០១១។ |
| ៧) សុំឱ្យសមត្ថកិច្ចជួយចាត់កំលាំងការពារសន្តិសុខដល់ជនងាយរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ ការគំរាមកំហែងពីក្មេងទំនើងតាមទីសាធារណៈ ការប្រើប្រាស់ថ្នាំញៀន និងលំបំបាត់ការជំរិតយកលុយពីប្រជាពលរដ្ឋរបស់ប៉ូលីសចរាចរដោយខុសច្បាប់ឱ្យបាន ១០០% នៅទូទាំងខេត្តព្រះវិហារឱ្យបានចាប់ពីឆ្នាំ២០១០ តទៅ។ |
| ៨) សុំមន្ទីរអប់រំខេត្តជួយផ្តល់គ្រូបង្រៀនឱ្យបានគ្រប់គ្រាន់ និងសុំឱ្យមានវគ្គបណ្តុះបណ្តាលកម្មវិធីសិក្សាថ្មីក្នុងមួយឆ្នាំ ២វគ្គ ដល់គ្រូទាំង ៧ស្រុក ក្នុងខេត្តព្រះវិហារ ចាប់ពីឆ្នាំ២០១០ តទៅ។ សុំមន្ទីរអប់រំបង្កើតវិទ្យាល័យមួយកន្លែងនៅក្នុងស្រុកឆែប ១អគារ មាន ៥បន្ទប់ ទីចាត់ការមួយ បណ្ណាល័យមួយ ចាប់ផ្តើមពីឆ្នាំ២០១០ បញ្ចប់ក្នុងឆ្នាំ២០១២។ សុំអាគារនៅសាលាបឋមសិក្សាហ្វូសែត នៅសង្កាត់ប៉ាហាល |

| |
|---|
| ក្រុងព្រះវិហារ អោយបាននៅឆ្នាំ២០១២។ សុំអាគារនៅអនុវិទ្យាល័យសង្គមថ្មីមួយខ្នង ៥បន្ទប់ ទីចាត់ការមួយ និងសុំបន្ថែមគ្រូបង្រៀន ដោយចាប់ផ្តើមនៅឆ្នាំ២០១០ បញ្ចប់នៅឆ្នាំ២០១១។ សុំបង្កើតសកលវិទ្យាល័យមួយកន្លែងនៅក្នុងខេត្តព្រះវិហារ ដោយចាប់ផ្តើមនៅឆ្នាំ ២០១០ បញ្ចប់នៅឆ្នាំ២០១១។ |
| ៩) សុំមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជួយរកការងារដល់ស្ត្រីមេម៉ាយរងគ្រោះអោយបាន ១០០% ដោយមិនប្រកាន់បក្សពួក នៅខេត្តព្រះវិហារចាប់ពីឆ្នាំ ២០១០ នេះតទៅ។សុំតម្លើងប្រាក់ខែដល់គ្រូបង្រៀន និងមន្ត្រីរាជការឱ្យបាន ៥០% ជារៀងរាល់ឆ្នាំនៃប្រាក់ខែបច្ចុប្បន្នចាប់ពីឆ្នាំ២០១០ នេះតទៅ។ |
| ១០) សុំឱ្យរាជរដ្ឋាភិបាល ជួយរកទីផ្សារលក់ផលិតផល និងកំណត់តំលៃផលិតផល ដូចជា ដំឡូងមី សណ្តែក ស្រូវ ពោត ល្ង ព្រមទាំងឱ្យមានតំលៃខ្ពស់ជាងតម្លៃបច្ចុប្បន្ន៣០% ចាប់ពីឆ្នាំ២០១០ តទៅ។ សុំឱ្យរាជរដ្ឋាភិបាលបង្កើតរោងចក្រផលិតម្សៅមី និងស្ករសនៅក្នុងក្រុងព្រះវិហារ ឱ្យបានក្នុងឆ្នាំ២០១០ និងបញ្ចប់ក្នុងឆ្នាំ ២០១១។ |

## ក.១៧. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រះសីហនុ

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត ព្រះសីហនុ |
|---|
| ១) សុំអោយបង្កើត និងអនុម័តច្បាប់ប្រឆាំងអំពើពុករលួយអោយបាននៅឆ្នាំ ២០១០។ |
| ២) សុំជួសជុលផ្លូវលំ និងផ្លូវជាតិដោយធ្វើពីបេតុង ឬកៅស៊ូ ឱ្យបានទូទាំងខេត្តព្រះសីហនុចាប់ពីឆ្នាំ២០១០ ឱ្យហើយរួចរាល់នៅឆ្នាំ ២០១២។ |
| ៣) សុំតប្រព័ន្ធអគ្គិសនីឱ្យបានទូទាំងខេត្តព្រះសីហនុ ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១២ ដោយមានតំលៃចន្លោះពី ៥០០រៀល ទៅ ៧០០រៀល ក្នុង១គីឡូវ៉ាត់/ម៉ោង ហើយមានភ្លើងអគ្គិសនីប្រើប្រាស់គ្រប់ ២៤ម៉ោង។ |
| ៤) សុំដីសម្បទានសង្គមកិច្ចដល់គ្រប់គ្រួសារគ្មានដីនៅទូទាំងខេត្តព្រះសីហនុ អោយបានចាប់ពីឆ្នាំ ២០១០ ដល់ ២០១២ អោយបានគ្រប់គ្រួសារ ដោយក្នុង១ គ្រួសារអោយបាន ១ហិចតា។ |
| ៥) រដ្ឋាភិបាលមុននឹងផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់អ្នកវិនិយោគត្រូវអនុវត្តលើការសិក្សាពីទីតាំងផ្តល់ដីអោយបានច្បាស់លាស់ និងវាយតំលៃពីផលប៉ះពាល់ផ្នែកបរិស្ថានព្រមទាំងធ្វើការផ្សព្វផ្សាយពីគំរោងត្រូវអភិវឌ្ឍន៍នឹងផ្សព្វផ្សាយរបាយការណ៍ស្តីពីផលប៉ះពាល់ឱ្យដល់តំបន់ ដែលត្រូវអភិវឌ្ឍន៍ មុនពេលអនុវត្តគំរោង តាមរយៈសារព័តមាន វិទ្យុ ទូរទស្សន៍ សិក្ខាសាលា ប្រជុំដោយអនុវត្តចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៦) សេវាព្យាបាលជម្ងឺ (ជំងឺគ្រុនឈាម គ្រុនពោះវៀន វះកាត់ពេលឆ្លងទន្លេ) នៅមន្ទីរពេទ្យរដ្ឋ ជូនប្រជាពលរដ្ឋមិនត្រូវយកប្រាក់ទូទាំងខេត្តព្រះសីហនុ ចាប់ពី ឆ្នាំ២០១០ តទៅ។ |
| ៧) បំបាត់ការយកលុយពេលប្រលងឌីប្លូម បាក់ឌុប និងការបង្រៀនគួរក្នុងម៉ោងរដ្ឋ ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៨) សុំអោយមានការដាក់តារាងកំណត់តំលៃអោយបានជាក់លាក់សំរាប់ប្រជាពលរដ្ឋដែលត្រូវការដោះស្រាយទំនាស់តាមផ្លូវតុលាការ (ប្រាក់ប្រដាប់ក្តី ប្រាក់ចុះបញ្ជីពាក្យបណ្តឹង...) នៅខេត្តព្រះសីហនុអោយបាននៅឆ្នាំ ២០១០ តទៅ។ |
| ៩) សុំវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសកសិកម្មដំណាំស្រូវ ស្ពៃ ផ្សិត សាលាដ និងសត្វពាហនៈ ដូចជាគោ ជ្រូក ក្របី ក្នុង១ ឆ្នាំអោយបាន ២ វគ្គ ដល់កសិករអោយបានទូទាំងខេត្ត ព្រះសីហនុ ចាប់ពីឆ្នាំ២០១០ តទៅ។ |
| ១០) សុំអោយមានការបិទផ្សាយជាសាធារណៈអោយប្រជាពលរដ្ឋដឹងពីតំលៃសេវា និងរយៈពេលដែលត្រូវទទួលបានសេវា ដែលប្រជាពលរដ្ឋចង់បានដូចជា (សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ ការសរសេរពាក្យបណ្តឹង ការសំរុះសំរួលទំនាស់,..) ធ្វើអោយបានគ្រប់ឃុំ ចាប់ផ្តើមពីឆ្នាំ ២០១០។ ត្រូវមានការពិភាក្សាគ្នាជាមុនរវាងប្រជាពលរដ្ឋអោយបានគ្រប់ឃុំដែលពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន មុននឹងសំរេចចិត្តបោះបង្គោល ឬផ្តល់ការវិនិយោគ ឬកំនត់តំបន់ការពារ ឬការផ្តល់សម្បទានសេដ្ឋកិច្ច ដោយអនុវត្ត ចាប់ផ្តើមពីឆ្នាំ ២០១០ តទៅ។ |

## ក.១៨. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងរាជធានីភ្នំពេញ

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងរាជធានី ភ្នំពេញ |
|---|
| ១) សូមរដ្ឋាភិបាលជួយអនុវត្ត និងពង្រឹងការដាក់ពិន័យដល់បុគ្គលិកសុខាភិបាលដែលធ្វើខុសនឹងក្រមសីលធម៌វិជ្ជាជីវៈ [ទៅតាមច្បាប់ និងក្រម-សីលធម៌ដែលមានស្រាប់] ព្រមទាំងកាត់បន្ថយតម្លៃសេវាកម្ម ឬមិនយកប្រាក់ចំពោះអ្នកក្រីក្រដែលគ្មានលទ្ធភាពបង់ថ្លៃសេវានៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យរដ្ឋទាំងអស់នៅក្នុងក្រុងភ្នំពេញ ចាប់ពីឆ្នាំ ២០១០ នេះតទៅ ។ |
| ២) សុំបញ្ចុះតម្លៃទឹក និងភ្លើង ក្នុងទីក្រុង និងជាយក្រុងឱ្យបាន ៣០% នៃតម្លៃបច្ចុប្បន្ន ចាប់ពីដើមឆ្នាំ ២០១០ តទៅ ។ និងសុំឱ្យរាជរដ្ឋាភិបាលជួយបញ្ចុះតម្លៃប្រេងឥន្ធនៈឱ្យមានតម្លៃប្រហាក់ប្រហែល ឬស្មើនឹងតម្លៃប្រេងនៃប្រទេសជិតខាង [ប្រទេសជិតខាងដែល មានតំលៃទាប] ចាប់ពីដើមឆ្នាំ ២០១០ តទៅ។ |
| ៣) សុំឱ្យរដ្ឋាភិបាលតម្លើងប្រាក់ខែដល់មន្ត្រីរាជការ (វិស័យអប់រំ) ចំនួន ៤០% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០១០ តទៅ ។ និងសុំឱ្យរដ្ឋាភិបាលមានវិធានការដល់គ្រូបង្រៀនឱ្យបញ្ឈប់ការទារប្រាក់ក្រៅផ្លូវការពីសិស្ស (ក្រសួងមិនបានកំនត់) អោយបាន១០០% ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៤) សូមឱ្យរាជរដ្ឋាភិបាលជំរុញការអនុម័ត ច្បាប់ប្រឆាំងនឹងអំពើពុករលួយ ឱ្យបានក្នុងឆ្នាំ ២០១០ ។ |
| ៥) សុំឱ្យស្តារប្រព័ន្ធលូទឹក ដើម្បីកុំឱ្យស្ទះទឹក លិចផ្ទះ លិចផ្លូវ (ទំហំលូ ឱ្យបាន ២ ម) ក្នុងខណ្ឌសែនសុខ ខណ្ឌឫស្សីកែវ ចាប់ពីឆ្នាំ ២០១០ និងបញ្ចប់នៅឆ្នាំ ២០១២ ។ |
| ៦) សូមឱ្យរាជរដ្ឋាភិបាលបង្កើតទីផ្សារការងារឱ្យបានយ៉ាងហោចណាស់៥០% ជារៀងរាល់ឆ្នាំនៃយុវជន និងនិស្សិតបញ្ចប់ការសិក្សា [មហាវិទ្យា-ល័យ] ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៧) សុំឱ្យរដ្ឋាភិបាលជំរុញ និងផ្តល់ឱកាសដល់ស្ត្រីឱ្យចូលរួមគ្រប់សកម្មភាពការងារក្នុងសង្គម ពិសេសវិស័យនយោបាយតាំងពីថ្នាក់ជាតិ ទៅដល់ថ្នាក់មូលដ្ឋានឱ្យបានពី ៣០% នៅ ក្នុងនីតិកាលទី ៤ ។ (វិស័យនយោបាយថ្នាក់ជាតិមាន : រដ្ឋសភា ព្រឹទ្ធសភា ហើយថ្នាក់មូលដ្ឋានគឺនៅ តាមភូមិ ឃុំ ស្រុក) ។ |
| ៨) សុំឱ្យក្រសួងសុខាភិបាលមានវិធានការពង្រឹងការចុះត្រួតពិនិត្យ និងបិទឱសថស្ថានណាដែលគ្មានច្បាប់អនុញ្ញាត្ត និងគ្មានសមត្ថភាពវិជ្ជាជីវៈនៅក្នុងក្រុងភ្នំពេញទាំងអស់អោយបានក្នុងឆ្នាំ ២០១០ នេះទៅ ។ |
| ៩) សុំឱ្យរាជរដ្ឋាភិបាលផ្សព្វផ្សាយព័ត៌មានពីអ្វីដែលរដ្ឋាភិបាលបានធ្វើក្នុងព្រះរាជាណាចក្រកម្ពុជារាល់ ៣ខែម្តង ដោយផ្សព្វផ្សាយ តាមរយៈវិទ្យុ ទូរទស្សន៍ កាសែត និងប្រព័ន្ធផ្សព្វផ្សាយនានា ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១០ ។ |
| ១០) សុំឱ្យរាជរដ្ឋាភិបាលចេញប័ណ្ណកម្មសិទ្ធិដីធ្លី (ប្លង់រឹង) ជូនដល់ប្រជាពលរដ្ឋនៅទូទាំងរាជធានីភ្នំពេញឱ្យបានគ្រប់គ្រួសារចាប់ពីឆ្នាំ ២០១០ ដល់ ២០១២ ។ |

## ក.១៩. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តមណ្ឌលគិរី

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង ១០ នៅក្នុងខេត្ត មណ្ឌលគិរី** |
|---|
| ១) សុំឱ្យរាជរដ្ឋាភិបាលផ្តល់ពូជស្រូវ (ផ្កាខ្ញី ផ្កាដូង សែនពិដោរ) នៅស្រុកអូររាំង ស្រុកកែវសីម៉ា ស្រុកកោះញែក ស្រុកពេជ្រាដា និងក្រុងសែនមនោរម្យឱ្យបានមួយគ្រួសារ៥០ គីឡូក្រាម គ្រប់គ្រួសារឱ្យបាននៅឆ្នាំ ២០១០។ |
| ២) សុំឱ្យរាជរដ្ឋាភិបាលផ្តល់ដីសម្បទានសង្គមកិច្ច (ដល់ប្រជាពលរដ្ឋដែលគ្មានដី) នៅគ្រប់ស្រុកនៃខេត្តមណ្ឌលគិរី ដោយក្នុងមួយ ស្រុក ៥០០០ ហិកតា ចាប់ផ្តើមពី ឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៥។ |
| ៣) សុំអណ្តូងទឹកស្អាតចំនួន ៥ អណ្តូង ក្នុងមួយភូមិ (គ្រប់ភូមិ) ឱ្យបានគ្រប់ស្រុកក្នុងខេត្តមណ្ឌលគិរី ឱ្យបាននៅឆ្នាំ ២០១០។ |
| ៤) សុំធ្វើផ្លូវចំនួន ៤ ខ្សែ (ស្ពាន និង លូ)។ ១ ខ្សែក្រាលគ្រួសក្រហមពីផ្សារកែវសីម៉ា ទៅដល់ភូមិការទី ឃុំស្រែព្រះ ស្រុកកែវសីម៉ា ទទឹង៨ ម៉ែត្រ ប្រវែង២៤ គីឡូម៉ែត្រ ចាប់ផ្តើមនៅឆ្នាំ២០១០ បញ្ចប់នៅឆ្នាំ២០១២។ និងផ្លូវលំ១ខ្សែ ពីភូមិស្រែព្រះ ដល់ភូមិស្រែអំពិល ទទឹង៧ម៉ែត្រ ប្រវែង ៨គីឡូម៉ែត្រ ចាប់ផ្តើមពីឆ្នាំ២០១១ ដល់២០១២។ ផ្លូវ១ខ្សែក្រាលកៅស៊ូនៅភូមិដោះក្រមុំ ឃុំស្រែព្រះ ស្រុកកែវសីម៉ា ទទឹង ៧ម៉ែត្រ បណ្តោយ ១០០០ម៉ែត្រ ចាប់ផ្តើមឆ្នាំ២០១០ បញ្ចប់ឆ្នាំ២០១១។ ផ្លូវ១ខ្សែ នៅភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ ទទឹង១០ម៉ែត្រ ប្រវែង១០០០ម៉ែត្រ ចាប់ផ្តើមចុងឆ្នាំ ២០០៩ បញ្ចប់នៅឆ្នាំ ២០១០។ |
| ៥) សុំឱ្យរាជរដ្ឋាភិបាលជួយរកទីផ្សារឱ្យផលិតផលដំឡូងមី និងផ្លែឈើ (ខ្នុរ ចេក ទាប) ដោយដំឡូងមីមួយគីឡូក្រាម ស្មើពាក់កណ្តាលនៃតំលៃអង្ករមួយគីឡូក្រាម និងតំលៃផ្លែឈើប្រភេទ ខ្នុរ ចេក ទាប ស្មើតំលៃប្រេងសាំងមួយលីត្រ និងតំលៃផ្លែប័រ ១គីឡូក្រាម ស្មើ ២គីឡូក្រាមតំលៃអង្ករ ចាប់ផ្តើមពីដើមឆ្នាំ២០១០។ |
| ៦) សុំរាជរដ្ឋាភិបាលបង្កើតរោងចក្រម្សៅមីចំនួន ១ នៅទីរួមខេត្ត និងសុំត្រាក់ទ័រចំនួន ៤ គ្រឿងនៅក្រុងសែនមនោរម្យ ឱ្យបាននៅចុងឆ្នាំ ២០១០។ |
| ៧) ចង់ឱ្យតុលាការកាត់ក្តីឱ្យមានយុត្តធម៌ នឹងមិនមានលំអៀង (ស្របតាមនិតិវិធី) ឱ្យបាន ១០០% កុំស៊ីសំណូកជាមួយជនអ្នកមានលុយចាប់ពីចុងឆ្នាំ ២០០៩។ |
| ៨) សុំឱ្យរាជរដ្ឋាភិបាលផ្តល់ពូជសត្វណាមួយក្នុងចំណោមសត្វទាំងនេះ (គោ ក្របី ជ្រូក មាន់ ទា....) នៅស្រុកអូររាំង ស្រុកកែវសីម៉ា ស្រុកពេជ្រាដា និងក្រុងសែនមនោរម្យ ដោយក្នុង១គ្រួសារ១ក្បាល គ្រប់ភូមិ យ៉ាងហោចណាស់៥០គ្រួសារក្នុង១ឆ្នាំ ចាប់ផ្តើមនៅដើមឆ្នាំ ២០១០។ |
| ៩) សុំកសាងសាលារៀនអនុវិទ្យាល័យថ្មីមួយ ដែលមានអាគារចំនួន ១ខ្នង ៦បន្ទប់ នៅក្នុងសង្កាត់រមនា ក្រុងសែនមនោរម្យ សង់ជាថ្ម ដំបូលប្រក់ក្បឿង ចាប់ផ្តើមធ្វើនៅដើមឆ្នាំ ២០១០ បញ្ចប់នៅឆ្នាំ ២០១១។ |
| ១០) សុំបង្កើតរោងចក្រកាត់ដេរយ៉ាងហោចណាស់ចំនួន ១ សំរាប់យុវជន យុវនារីមានការងារ នៅទីរួមខេត្តមណ្ឌលគិរី ឱ្យបាននៅ ចុងឆ្នាំ ២០១០។ |

## ក.២០. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តរតនគិរី

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង ១០ នៅក្នុងខេត្ត រតនគិរី |
|---|
| ១) រាជរដ្ឋាភិបាលត្រូវបង្កើតច្បាប់ប្រឆាំងអំពើពុករលួយឱ្យបាននៅយ៉ាងយូរត្រឹមថ្ងៃទី ០១ ខែ ០១ ឆ្នាំ ២០១០ ហើយត្រូវអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធិភាព ដោយជនណាប្រព្រឹត្តផ្ទុយនឹងច្បាប់ប្រឆាំងអំពើពុករលួយត្រូវផ្តន្ទាទោសតាមច្បាប់ ដោយមិនរើសអើងទៅលើឋានៈ បុណ្យសក្តិ ហើយត្រូវបង្កើតគណៈកម្មាធិការឯករាជ្យប្រឆាំងអំពើពុករលួយនៅដើមឆ្នាំ ២០១០ ដែរ។ |
| ២) ចាប់ពីដើមឆ្នាំ ២០១០ សុំកុំយកកងកំលាំងប្រដាប់អាវុធជាតិ ទៅបំរើផលប្រយោជន៍ក្រុមឯកជនមួយក្តាប់តូច ឬជនមានអំណាចប្រើប្រាស់គំរាមគំហែងប្រជាពលរដ្ឋ កម្មករ ហើយរាល់បញ្ហាដែលកើតមានឡើងជាមួយប្រជាពលរដ្ឋ ត្រូវដោះស្រាយដោយសន្តិវិធីនិងតាមច្បាប់ដែលមានស្រាប់។ |
| ៣) ចង់ឱ្យមន្ត្រីកសិកម្មចុះបង្រៀនពី វិធីចិញ្ចឹមមាន់ ទា គោ ជ្រូក (១ ឆ្នាំ ៣ ដង : ខែ ០១ ខែ ០៤ ខែ ០៩ ចាប់ពីឆ្នាំ ២០១០) នៅភូមិ ណងឡិ ឃុំអូរជុំ ស្រុកអូរជុំ ភូមិកំផ្លិញ ឃុំល្បាំង ស្រុកលំផាត់ ភូមិ ៣ ត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគីរី។ |
| ៤) តុលាការមិនត្រូវយកប្រាក់ពីប្រជាពលរដ្ឋក្រីក្រដែលជាជនរងគ្រោះ នៅពេលពួកគាត់ដាក់ពាក្យបណ្តឹងចូលតុលាការចាប់ពីដើមឆ្នាំ ២០១០ តទៅ ហើយរាល់ការទៅសួរសុខទុក្ខអ្នកទោស ក្នុងពន្ធនាគារមិនត្រូវយកប្រាក់ឡើយចាប់ពីដើមឆ្នាំ ២០១០ តទៅ។ |
| ៥) កសាងផ្លូវពីទីរួមស្រុកលំផាត់ ទៅភូមិបាតាង ឃុំបាតាង ស្រុកលំផាត់ ប្រភេទថ្នល់កៅស៊ូ ឱ្យរួចរាល់នៅឆ្នាំ ២០១១ ។ ថ្នល់ចាក់កៅស៊ូពីស្រុកបានលុង ទៅភូមិតាស៊ុយ ឃុំកាចាញ ឱ្យហើយនៅឆ្នាំ ២០១១ ។ ស្រុកអូរយ៉ាដាវ ដល់ ភូមិគងធំ ឃុំបាតេ ឱ្យហើយត្រឹមឆ្នាំ២០១១ (ក្រាលកៅស៊ូ) ។ ផ្លូវចូលភូមិពីផ្លូវធំ (ផ្លូវ ៧៨) ទៅភូមិ ឡាអិន ឃុំ តឺន ស្រុកកូនមុំ ប្រវែង ៥០០ ម៉ែត្រ ក្រាលគ្រោះ ឬកៅស៊ូ ឱ្យហើយត្រឹមឆ្នាំ ២០១១ ។ ផ្លូវគ្រោះ ឬកៅស៊ូ ពីផ្លូវជាតិចូលភូមិយ៉ឺន ឃុំកក់ ស្រុកបរកែវ ប្រវែងប្រហែល ៥០០ ម៉ែត្រ។ |
| ៦) សង់សាលារៀនបឋមសិក្សា ថ្មី (៦ បន្ទប់) នៅភូមិ តាអង ឱ្យរួចរាល់នៅឆ្នាំ ២០១១។ សង់សាលារៀនបឋមសិក្សា (៤ បន្ទប់) នៅភូមិកាឡៃសាពូន ឃុំភ្នំកុក ស្រុកវ៉ឺនសៃ និងសាលារៀនមតេយ្យមួយ នៅភូមិ ១ ឃុំកាចាញ ឱ្យរួចរាល់នៅឆ្នាំ ២០១២។ សង់សាលារៀន បឋមសិក្សា (៥ បន្ទប់) នៅភូមិសាលា ឃុំកក់ ស្រុកបរកែវ និងមណ្ឌលសុខភាព (សំណង់ថ្មប្រក់ក្បឿង) នៅឃុំត្រពាំងក្រហម ឱ្យរួចរាល់នៅឆ្នាំ ២០១២ និងមណ្ឌលសុខភាពនៅឃុំ តាអង ឱ្យហើយនៅឆ្នាំ ២០១១។ ជំរុញការកសាងផ្សារស្រុកកូនមុំ នៅឃុំត្រពាំងច្រេស (សំណង់ថ្ម) ឱ្យហើយនៅឆ្នាំ ២០១០។ |
| ៧)សុំអោយមន្ត្រីកសិកម្មចុះបង្រៀនរបៀបចិញ្ចឹមជ្រូក និងសុំពូជជ្រូកមួយចំនួន (បង្រៀន ៣ ដង ក្នុងមួយឆ្នាំ នៅខែ ០១ ខែ ០៤ ខែ ០៧) និងសុំពូជជ្រូកយ៉ក់ខ្សៀ ចំនួន ៦០ក្បាល (ញី ៤០ ឈ្មោល ២០) សម្រាប់ភូមិកាឡៃ សាពួន ភ្នំកុក ឃុំភ្នំកុក ស្រុកវ៉ឺនសៃ និងភូមិកាតេ ឃុំលុងជ័រ ស្រុកអូរយ៉ាដាវ ដោយសុំអោយមេភូមិជាអ្នកចែកអោយអ្នកដែលអត់ទាន់មាន ចាប់ពីឆ្នាំ ២០១០តទៅ។ |
| ៨) សុំអោយមន្ត្រីពេទ្យសត្វចុះចាក់ថ្នាំ (គោ ក្របី) ២ ដង ក្នុងមួយឆ្នាំ (ខែ០៦ និងខែ ១២) ។ មន្ត្រីចុះមានគ្នា ៣ នាក់ ចាក់នៅគ្រប់ស្រុកចាប់ពីដើមឆ្នាំ ២០១០។ |
| ៩) សុំអោយបង្កើតរោងចក្រធុនតូច ចំនួន ៣ មានដូចជា រោងចក្រគ្រាប់ស្វាយចន្ទី រោងចក្រកែច្នៃម្រេមី និងរោងចក្រកែច្នៃ សណ្តែកសៀង នៅទីរួមខេត្តរតនគីរី យ៉ាងយូរឆ្នាំ ២០១២ ។ |
| ១០) សុំសាលាបឋមសិក្សាចំនួន ២ ខ្នង (មួយខ្នងនៅភូមិ ១ ក្រុមតាស៊ុយ ឃុំកាចាញ ស្រុកបានលុង) ។ មួយខ្នងទៀត នៅភូមិកងយុ ឃុំប៉ាតេ ស្រុកអូរយ៉ាដាវ ឱ្យបានក្នុងឆ្នាំ ២០១០) ។ |

## ក.២១. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តសៀមរាប

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត សៀមរាប |
|---|
| ១) ជំរុញអោយរាជរដ្ឋាភិបាល និងសភាអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយអោយបានឆាប់រហ័សនៅដើមឆ្នាំ ២០១០។ ត្រូវអនុវត្តអោយបានត្រឹមត្រូវ និងតម្លាភាព [តាមច្បាប់កំណត់] ព្រមទាំងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អោយបានទូលំទូលាយ ទូទាំងប្រទេស ។ |
| ២) - ជួយផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ៤ វគ្គ ក្នុង មួយឆ្នាំ ក្នុងមួយស្រុកអោយបាននៅគ្រប់ស្រុកដើម្បីអោយទិន្នផល ពី ១តោន ដល់ ៣តោន ក្នុង ១ហិកតា ចាប់ពីដើមឆ្នាំ ២០១០នេះតទៅ។<br>- សុំផ្តល់ទុនកម្ចីដោយមានអត្រាការប្រាក់ទាប ប្រហែល ២ ភាគរយក្នុងមួយឆ្នាំ សំរាប់ការងារកសិកម្ម នៅខេត្តសៀមរាបចាប់ពីដើមឆ្នាំ ២០១០ តទៅ។<br>- ជួយរកទីផ្សារ បង្កើនតំលៃស្រូវ ១ គីឡូក្រាមយ៉ាងហោចណាស់ស្មើមួយភាគបីនៃ តំលៃប្រេងសាំង ក្នុង ១ លីត្រ អោយបាន នៅដើមឆ្នាំ ២០១០។ |
| ៣) ត្រូវទប់ស្កាត់ផលិតផលក្រៅស្រុក កុំអោយចូលមកខេត្តសៀមរាប មាន មាន់ ទា ត្រី ចាប់ពីឆ្នាំ ២០១០ ។ លុបបំបាត់ឧបករណ៍នេសាទខុសច្បាប់អោយបាន [១០០ ភាគរយ] ចាប់ពី ខែ ១០ ឆ្នាំ ២០០៩តទៅ ។ |
| ៤) ផ្តល់ដីសម្បទានសង្គមកិច្ចដល់អ្នកក្រីក្រខ្វះដីពិតប្រាកដ មួយគ្រួសារអោយបាន ៣ ហិកតា នៅខេត្តសៀមរាប អោយបាននៅ ដើមឆ្នាំ ២០១០។ |
| ៥) សុំតម្លើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការព្រមទាំងកងកំលាំងប្រដាប់អាវុធអោយបានយ៉ាងតិច ១៥០ ដុល្លារក្នុងមួយខែ ឡើងទៅ ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៦) កំណែទំរង់ប្រព័ន្ធតុលាការអោយមានភាពឯករាជ្យ អព្យាក្រឹត និងយុត្តិធម៌ ១០០ ភាគរយ ចាប់ពីដើមឆ្នាំ ២០១០។ |
| ៧) សុំអោយចាត់វិធានការតំលៃអគ្គិសនីនៅខេត្តសៀមរាបដោយ ១ គីឡូវ៉ាត់ ស្មើ ១ ភាគ ៤ នៃតំលៃប្រេងសាំង ចាប់ពីឆ្នាំ ២០១០។ |
| ៨) ផ្តល់សំណងថ្លៃដីនៅស្រុកវ៉ារិន្ទអោយបានសមរម្យ (តាមតំលៃទីផ្សារ) ដែលអាចទិញដីកន្លែងក្បែរៗនោះបាន ចាប់ពីឆ្នាំ ២០១០ និងបញ្ឈប់ការប្រើប្រាស់កំលាំងប្រដាប់អាវុធទៅគំរាមប្រជាពលរដ្ឋក្នុងខេត្តសៀមរាបចាប់ពីឆ្នាំ ២០០៩ តទៅ។ |
| ៩) សុំអោយអាជ្ញាធរអប្សរាដោះដូរដីស្រែ (ដីកន្លែងថ្មីដែលនៅជិតភូមិប្រជាពលរដ្ឋ) អាចបង្កបង្កើនផលបានចាប់ពីឆ្នាំ ២០១០។ ស្នើសុំអោយបញ្ឈប់ការដកហូតដីស្រែដែលនៅសល់របស់ប្រជាពលរដ្ឋបន្តទៅទៀតនៅក្នុងតំបន់អប្សរាចាប់ពីខែ សីហា ឆ្នាំ២០០៩ នេះតទៅ។ |
| ១០) លុបបំបាត់សេវាបំរើផ្លូវភេទគ្រប់រូបភាពអោយបាន ១០០ ភាគរយ នៅក្នុងខេត្តសៀមរាប ចាប់ពីដើមឆ្នាំ ២០១០ នេះតទៅ។ |

## ក.២២. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តស្ទឹងត្រែង

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង ១០ នៅក្នុងខេត្ត ស្ទឹងត្រែង |
|---|
| ១) សុំអោយលុបបំបាត់ការរំលោភដីធ្លីគ្រប់រូបភាពស្ថិតនៅក្នុងភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ពីសំណាក់យោធាភូមិភាគមួយអោយបាន ១០០% ចាប់ពីដើមឆ្នាំ ២០១០តទៅ ។ |
| ២) សុំអោយលុបបំបាត់នូវវប្បធម៌និទណ្ឌភាពអោយបាន ១០០% នៅក្នុងខេត្តស្ទឹងត្រែង ចាប់ពីដើមឆ្នាំ ២០១០។ |
| ៣) សុំអោយជួយបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដល់កសិករ អោយបាន១ឆ្នាំ ២វគ្គ សំរាប់មួយស្រុក នៅទូទាំង ខេត្តស្ទឹងត្រែង ចាប់ពីដើមឆ្នាំ ២០១០ តទៅ។ |
| ៤) សុំកសាងបន្ថែមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញគ្រប់ប្រភេទ (ជួសជុលម៉ាស៊ីន, កាត់ដេរ...) ចំពោះប្រជាពលរដ្ឋទូទៅ មួយកន្លែង នៅក្នុងក្រុងស្ទឹងត្រែង អោយបាន នៅឆ្នាំ ២០១១។ |
| ៥) -សូមអោយរដ្ឋាភិបាលដកដីពីអ្នករានព្រៃខុស ច្បាប់អោយបាន១០០% ចាប់ផ្តើមនៅឆ្នាំ ២០១០ តទៅ ។<br>-សុំផ្តល់ដីសម្បាទានសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រដែលគ្មានដីអោយបាន យ៉ាងហោចណាស់ ៣ហិកតា ក្នុង មួយគ្រួសារនៅក្នុងខេត្ត ស្ទឹងត្រែង ចាប់ផ្តើមពីឆ្នាំ ២០១០ ដល់ ២០១២ ។ |
| ៦) សុំមន្ទីរពេទ្យបង្អែកព្យាបាលអ្នកជំងឺដោយមិនយកប្រាក់ និងយកចិត្តទុកដាក់ ចំពោះប្រជាជនក្រីក្រ ពិតប្រាកដនៅទូទាំង ខេត្តស្ទឹងត្រែង ចាប់ពីឆ្នាំ ២០១០តទៅ ។ |
| ៧) សុំអោយរដ្ឋាភិបាលជួយជំរុញការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយអោយបាននៅដើមឆ្នាំ ២០១០ ។ |
| ៨) សុំអោយរដ្ឋាភិបាលជួយកំណត់តំលៃផលិតផលកសិកម្មដោយ សុំអោយ គ្រាប់ស្វាយចន្ទី មួយគីឡូក្រាម ៤០០០ ទៅ ៥០០០រៀល សណ្តែកសៀង ៣៥០០រៀល ក្នុងមួយគីឡូក្រាម ដំឡូងមីក្រៀម ១០០០រៀល ក្នុងមួយគីឡូក្រាម ចាប់ផ្តើមនៅដើមឆ្នាំ ២០១០។ |
| ៩) សុំអោយរដ្ឋាភិបាលកុំផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលប៉ះពាល់ដល់អាជីព និងជីវបស់ប្រជាពលរដ្ឋ អោយបាន ១០០% នៅស្រុក ថាឡាបរិវ៉ាត់ ស្រុកសៀមបូក និងក្រុងស្ទឹងត្រែង ចាប់ពីដើមឆ្នាំ ២០១០ តទៅ ។ |
| ១០) សុំអោយឃុំសង្កាត់ អនុវត្តគោលនយោបាយ វិមជ្ឈការ ដោយឡែកអភិបាលកិច្ចល្អនៅមូលដ្ឋានដែលឃុំ/សង្កាត់ត្រូវ ផ្សព្វផ្សាយអំពីប្រាក់បង់ថ្លៃសេវា (អាត្រានុកូលដ្ឋាន លិខិតអាពាហ៍ពិពាហ៍ ,,,,,,,) ជាសាធារណៈ តាមរយៈការបិទនៅតាម ក្តារព័ត៌មានឃុំសង្កាត់ អោយបាន ១០០% នៅទូទាំង ខេត្តស្ទឹងត្រែង ចាប់ពីឆ្នាំ ២០១០ តទៅ ។ |

## ក.២៣. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តស្វាយរៀង

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពនាំង ១០ នៅក្នុងខេត្ត ស្វាយរៀង |
|---|
| ១) សុំប្រព័ន្ធធារាសាស្ត្រដើម្បីធ្វើស្រូវប្រាំង និងស្រូវវស្សារចំនួន ២ខ្សែ។ ប្រព័ន្ធបង្ហូរទឹកទី១ ចាប់ពីទន្លេវៃគោ ឃុំកំពង់ចក ទៅឃុំពងទឹកប្រហែល ៥០០០ម៉ែត្រ ទំហំ ១៥ម៉ែត្រ មាត់លើជំរៅ ៤ម៉ែត្រ និទី២ ចាប់ពីកំពង់ត្រាចមក ម៉ឺនជ័យប្រវែង ១៨គម មាត់លើ ១២ម៉ែត្រ ជំរៅ ៤ម៉ែត្រ ចាប់ផ្តើមពីឆ្នាំ ២០១០ នឹងបញ្ចប់នៅឆ្នាំ ២០១២។ |
| ២) សុំប្រព័ន្ធភ្លើងអគ្គិសនី ចាប់ពីប្រជុំជន ដល់ជនបទ (ចាប់ពីផ្សារជីភូ ដល់ផ្សារកំពង់ចក កាត់តាមឃុំច្រកម្ទេស ឃុំពពែត ឃុំព្រៃតាអី ឃុំគគីរសោម ឃុំស្វាយរំពារ ) ដោយគិតតម្លៃសេវា ៤៥០រៀល ក្នុង ១គីឡូវ៉ាត់ម៉ោង ចាប់ពីឆ្នាំ២០០៩ រហូតដល់ឆ្នាំ ២០១០ ឱ្យបានប្រើប្រាស់ និង ចាប់ពីផ្សារជីភូ ដល់ទីរួមស្រុកចន្ទ្រា កាត់តាមឃុំព្រៃអង្គុញ ឃុំព្រៃគគីរ និងឃុំ មេសថ្ងក មានប្រវែង ១៥គម ចាប់ពីឆ្នាំ២០០៩ បញ្ចប់ឆ្នាំ២០១០។ |
| ៣) សុំវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដំណាំស្រូវ ចិញ្ចឹមសត្វ (ដូចជា ជ្រូក មាន់ ទា...) ចិញ្ចឹមត្រី ដាំបន្លែ ជីកស្រះ ធ្វើជីធម្មជាតិ ទាំង ៦ស្រុក ឱ្យបាន ៣ដង ក្នុង ១ឆ្នាំ ចាប់ពី ២០០៩តទៅ។ សុំរាជរដ្ឋាភិបាលជួយ រកទីផ្សារ និងធានាតម្លៃ ផលិតផលកសិកម្ម ចាប់ពីឆ្នាំ២០០៩។ |
| ៤) សុំអោយរាជរដ្ឋាភិបាលកំណត់តំលៃទំនិញលើទីផ្សារ (ជីគីមី ប្រេងឥន្ទនៈ ទំនិញសព្វសារពើ..) ជីគីមីគុណភាពខ្ពស់ តំលៃខ្ពស់ ៨០០០០រៀល មួយបាវ (៥០គក) ប្រេងសាំង ២៥០០រៀល ប្រេងម៉ាសូត ២០០០រៀល និងធ្វើអោយបាន ចាប់ពី ឆ្នាំ២០០៩។ |
| ៥) សុំអោយខាងផ្នែកមន្ទីរសុខាភិបាល ជួយពង្រឹងគ្រូពេទ្យឱ្យគោរពតាមក្រមសីលធម៌ ចំពោះអ្នកជំងឺ (កុំឱ្យមានការ រើសអើង) ចំពោះអ្នកជំងឺ។ កំណត់តំលៃព្យាបាលឱ្យចុះជាងតម្លៃបច្ចុប្បន្ន ៥០% នៅគ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យនៅខេត្តស្វាយរៀងទាំងមូលអោយបាននៅឆ្នាំ២០១០។ |
| ៦) សុំឱ្យមន្ទីរកសិកម្មខេត្ត ជួយបណ្តុះបណ្តាលធ្វើជីធម្មជាតិ និងត្រួតពិនិត្យជីគីមី ដែលធ្វើឱ្យខូចគុណភាពដី និងនាំឱ្យបាត់ទិន្នផលស្រូវ និងបាត់បង់ជីវចំរុះ នៅទូទាំងខេត្ត ចាប់ពីឆ្នាំ២០០៩ តទៅ និងគំរោងត្រូវត្រួតពិនិត្យគុណភាពដីអោយបាន គ្រប់ដី កសិកម្មក្នុង ០១ឆ្នាំ ២ដង។ |
| ៧) សុំឱ្យស្ថាប័នមានសមត្ថកិច្ច (គណៈកម្មការសុរិយោដី និងតុលាការ) ជួយសំរួលដីទំនាស់ឱ្យបានសមស្របដល់ប្រជាពលរដ្ឋក្រីក្រ ដែលខ្វះដីបង្កបង្កើនផល មានដូចជាស្រុករមាសហែក ចន្ទ្រា រំដួល ស្វាយទាប កំពង់រោទ៍ និងបាវិត ឱ្យបាន ១០០% ក្នុងឆ្នាំ ២០១៣។ |
| ៨) កសាងផ្លូវជាតិថ្មីលេខ១៣ ក្រាលកៅស៊ូចាប់ពីភូមិក្រូច ឃុំជ្រុងពពែល ស្រុករំដួលទៅកាន់ទីរួមស្រុករមាសហែក ប្រហែល ២៥គីឡូម៉ែត្រ និងស្ពានសំរោង ទទឹង ៨ម៉ែត្រ បណ្តោយ ៣០ម៉ែត្រ សង់អំពីថ្មចាក់បេតុង។ សុំកសាងស្ពាន ចុងអូរ ភូមិចុងអូរ ឃុំត្រពាំងត្រាច ទំហំទទឹង ៨ ម៉ែត្រ បណ្តោយ ១០ម៉ែត្រ សង់អំពីថ្ម ចាក់បេតុង អោយហើយចាប់ពីឆ្នាំ២០០៩ និងបញ្ចប់ ឆ្នាំ២០១១។ |
| ៩) ជួសជុលផ្លូវជាតិពីផ្សារជីភូ ដល់ព្រំដែន ឃុំទួលស្ដី មានទទឹង ១០ម បណ្តោយ ៣៥គម ក្រាលកៅស៊ូ ស្ពានមានចំនួន ០២: ស្ពានទី១ ស្ពានតាអឹម នៅក្នុងភូមិដីក្រហម ឃុំមេសថ្ងក ស្រុកចន្ទ្រា ទទឹង ៨ម និងបណ្តោយ ១២ម ធ្វើអំពីថ្មចាក់បេតុង។ ស្ពានទី២: ស្ពានដូនទៃ ឃុំទួលស្ដី ទទឹង ៨ម បណ្តោយ ១៥ម និងលូ ២៥កន្លែង មុខកាត់ ០១ម ទទឹងថ្នល់ ១០ម ធ្វើចាប់ពីឆ្នាំ២០០៩ ឱ្យហើយនៅឆ្នាំ២០១១។ |
| ១០) សុំអោយសភាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ អោយបានក្នុងឆ្នាំ២០១០។ |

## ក.២៤. លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តឧត្តរមានជ័យ

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ នៅក្នុងខេត្ត ឧត្តរមានជ័យ** |
| --- |
| ១) សុំឱ្យរាជរដ្ឋាភិបាលជួយតបណ្តាញអគ្គិសនីអោយបានគ្រប់ស្រុកក្នុងខេត្តឧត្តរមានជ័យជូនដល់ប្រជាពលរដ្ឋក្នុងខេត្ត ដោយចាប់ផ្តើមរៀបចំអោយបាននៅឆ្នាំ២០១២។ សុំឱ្យដាក់ទោសដល់ក្រុមហ៊ុនមិនទទួលយករូបិយប័ណ្ណខ្មែរ និងសុំអោយកំណត់តម្លៃអគ្គិសនី ៥០០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោងចាប់ពីឆ្នាំ២០១០ តទៅ។ សុំបញ្ចុះតម្លៃសេវាតភ្លើងចូលផ្ទះឱ្យបាន៥០%នៃតម្លៃបច្ចុប្បន្នឱ្យបានចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ២) សុំរាជរដ្ឋាភិបាលជួយក្រាលកៅស៊ូលើផ្លូវ ចំនួន ៣ខ្សែ: ខ្សែទី១ ពីសង្កាត់អូរស្មាច់ ក្រុងសំរោង ទៅស្រុកក្រឡាញ់ ក្នុងខេត្ត សៀមរាប និងពីក្រុងសំរោង ទៅឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មានប្រវែង ១៧៥គម ខ្សែទី២ ពីក្រុងសំរោង ទៅភូមិជើងភ្នំ ក្នុងសង្កាត់បន្សាយរាក់ ក្រុងសំរោង មានប្រវែង ៤០គម និងខ្សែទី៣ ចាប់ពីស្រុកអន្លង់វែង ដល់ស្រុកសំរោង មាន ប្រវែង ៨២គម ដោយផ្តើមកសាងក្នុងឆ្នាំ២០១០ និងបញ្ចប់ក្នុងឆ្នាំ២០១២។ |
| ៣) សុំបង្កើតមជ្ឈមណ្ឌលសំរាប់បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងផ្តល់ពូជផលិតផល ដូចជា ស្រូវ ( ស្រូវស្រាល) ពោត ដំឡូង ដំណាំផ្សេងៗ... និងផ្តល់បច្ចេកទេសធ្វើជីធម្មជាតិ ឱ្យបានមួយកន្លែង ក្នុងមួយស្រុក ដល់កសិករទូទាំងខេត្ត ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១១។ |
| ៤) សុំអោយរាជរដ្ឋាភិបាលជួយរកវិយោគិនមកធ្វើរោងចក្រស្ករស [ យ៉ាងហោច ១ កន្លែង ] នៅក្រុងសំរោងអោយបាននៅឆ្នាំ២០១០ ហើយមានឈ្មួញ ឬអ្នកវិនិយោគទិញអំពៅតាមតម្លៃទីផ្សារ ឬមានកិច្ចកុងត្រាទិញ ១ តោនអំពៅ ស្មើ ២០ ដុល្លារអាមេរិក។ |
| ៥) សុំប្រឡាយទឹក ១ខ្សែ មានប្រវែង ២០០០ម x ២ម ( ផ្ទៃបាតលើ) x ១.៥០ម ( ផ្ទៃបាតក្រោម) នៅសង្កាត់បន្សាយរាក់ ក្រុងសំរោង ដោយចាប់ផ្តើមនៅឆ្នាំ២០១០ បញ្ចប់ក្នុងឆ្នាំ២០១១។ |
| ៦) សុំឱ្យសភាពាណិជ្ជកម្ម ប្រកាសតម្លៃផលិតផល ដូចជា ពោត ស្រូវ សណ្តែក ដំឡូង... ៣ដង ក្នុងមួយឆ្នាំ និងបង្កើនតម្លៃ ឱ្យបាន ២០% នៃតម្លៃផលិតផលបច្ចុប្បន្ន អោយបានចាប់ពីឆ្នាំ ២០០៩ នេះតទៅ។ |
| ៧) សុំអោយរាជរដ្ឋាភិបាលជួយរកវិនិយោគិនធ្វើរោងចក្រម្សៅមី [ យ៉ាងហោច ១ កន្លែង ] នៅក្រុងសំរោង ឱ្យបាននៅឆ្នាំ២០១០ និងមានឈ្មួញ ឬវិនិយោគិន ទិញដំឡូងមីស្រស់ ៤០០រៀល ក្នុង ១គីឡូក្រាម និងស្ងួត ៨០០រៀល ក្នុងមួយគីឡូក្រាម។ |
| ៨) សុំមន្ទីរសុរិយោដីខេត្តចុះបញ្ជីដីធ្លីដល់ប្រជាជន ( ប្រព័ន្ធ) បញ្ឈប់ការយកតម្លៃសេវាដោយចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០តទៅ។ |
| ៩) សុំជួយដោះស្រាយដីសម្បទានសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋក្រីក្រគ្មានដីប្រហែលចំនួន១៥០០គ្រួសារទូទាំងខេត្តឧត្តរមានជ័យយ៉ាងហោចណាស់ ឱ្យបាន ២ហិកតា ក្នុង ១គ្រួសារ ដោយចាប់ផ្តើមនៅឆ្នាំ២០១០ បញ្ចប់នៅក្នុងឆ្នាំ២០១១។ |
| ១០) សុំអោយរាជរដ្ឋាភិបាលតម្លើងប្រាក់បៀវត្សរ៍ដល់គ្រូបង្រៀនជាអប្បបរមាឱ្យបានចំនួន ៤០ម៉ឺនរៀល ក្នុងមួយខែ និងបន្ថែម ២០%នៃប្រាក់ខែ ចាប់ពីឆ្នាំ២០១០នេះតទៅ ។ |

# ឧបសម្ព័ន្ធ ខ: វិធីសាស្ត្រ

## ១. ដំណើរការសិក្ខាសាលា

- **ការបំពេញបញ្ជីសំណួរ** (pre-test) **ស្ដីពីកម្មវិធីនយោបាយ/យុទ្ធសាស្ត្រចតុកោណ:** ដើម្បីវាស់ស្ទង់ពី ចំណេះដឹងរបស់សិក្ខាកាមចំពោះកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៤ សិក្ខាកាមត្រូវបំពេញបញ្ជីសំណួរចំណេះដឹងមុនសិក្ខាសាលា (pre-test) បន្ទាប់ពីបានចុះឈ្មោះរួចហើយ ។

- **ការចុះឈ្មោះ និងកញ្ចប់ឯកសារសម្រាប់សិក្ខាកាម:** កន្លែងសម្រាប់ចុះឈ្មោះត្រូវមានយ៉ាងតិចចំនួនពីរ ហើយនៅ ន្លែងចុះឈ្មោះត្រូវមានដាក់លេខពី **១ ដល់ ៥** ដែលតំណាងឱ្យក្រុមពិភាក្សានីមួយៗ ទៅតាមយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២។ ហើយក្រុមទី ១ ពិភាក្សាជ្រុងនៃយុទ្ធសាស្ត្រចតុកោណទី **១) ការលើកស្ទួយវិស័យកសិកម្ម**។ **ក្រុមទី ២** ពិភាក្សាជ្រុងនៃយុទ្ធសាស្ត្រចតុកោណទី **២) ការបន្តស្តារ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត**។ ក្រុមទី ៣ ពិភាក្សាជ្រុងនៃយុទ្ធសាស្ត្រចតុកោណទី **៣) ការអភិវឌ្ឍ វិស័យឯកជន និងការងារ។ ក្រុមទី ៤** ពិភាក្សាជ្រុងនៃយុទ្ធសាស្ត្រចតុកោណទី **៤) ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស**។ និងក្រុមទី ៥ ពិភាក្សាទៅលើចំនុច **ស្នូល និងបរិស្ថានគ្របដណ្តប់យុទ្ធសាស្ត្រចតុកោណ។**

ពេលចុះឈ្មោះអ្នកចូលរួម អ្នកចុះឈ្មោះត្រូវឱ្យសិក្ខាកាមរើសយកលេខក្រុមដែលខ្លួនពេញចិត្ត (លេខ ១ ដល់ លេខ ៥ ដោយរើសបានតែមួយក្រុមប៉ុណ្ណោះ ហើយមួយក្រុមមានយ៉ាងច្រើនត្រឹម ២០ នាក់)។ បន្ទាប់ពីចុះឈ្មោះ រួចរាល់ហើយអ្នកចុះឈ្មោះ សិក្ខាកាមត្រូវប្រគល់ **បញ្ជីសំណួរចំណេះដឹងមុនសិក្ខាសាលា និងប៊ិច** ជូនដល់សិក្ខាកាម ហើយប្រាប់ថា ត្រូវបំពេញនៅពេលនេះ ហើយក្រោយពេលបំពេញចប់ត្រូវប្រគល់ឱ្យកន្លែងមួយទៀតដើម្បីយក សឺមីកញ្ចប់ឯកសាររួមមាន **របៀបវារៈ បញ្ជីសំណួរចំណេះដឹងក្រោយសិក្ខាសាលា និងឯកសារផ្សេងៗរបស់វាគ្មិន និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤។ លទ្ធផលនៃវិស័យអាទិភាពទាំង ១០** នឹងចែកជូនពេល សិក្ខាសាលាបញ្ចប់។

- **ការបើកកម្មវិធី (និងតួនាទីអ្នកសម្របសម្រួល):** សិក្ខាសាលានេះនឹងត្រូវបើកដោយការថ្លែងសុន្ទរកថា ស្វាគមន៍ដោយអភិបាលខេត្ត ឬអ្នកតំណាងអាជ្ញាធរខេត្ត (១៥ នាទី) ឬអ្នកសម្របសម្រួលកម្មវិធី។ អ្នកសម្របសម្រួលសិក្ខាសាលានឹងពន្យល់សិក្ខាកាមពី កម្មវិធី និងដំណើរការសិក្ខាសាលា (ដូចជា របៀបវារៈ ការបង្ហាញដោយសង្ខេបពីយុទ្ធសាស្ត្រចតុកោណ ការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ការចែកក្រុម ពិភាក្សា ការបង្ហាញតាមក្រុមក្នុងអង្គសិក្ខាសាលា ការជ្រើសរើសលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ការបោះ ឆ្នោតផ្តល់សេចក្តីទុកចិត្តដល់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំង១០ ការបង្ហាញលទ្ធផល...)។

- **ការសង្ខេបយុទ្ធសាស្ត្រចតុកោណដោយអ្នកសម្របសម្រួលៈ** (មុនបទបង្ហាញនេះ អ្នកសម្របសម្រួល ត្រូវពន្យល់ពីសារៈសំខាន់ និងទំនាក់ទំនងនៃបទបង្ហាញទៅនឹងការពិភាក្សាក្នុងក្រុម។ វាគ្មិន/ អ្នកសម្របសម្រួល នឹងបង្ហាញដោយសង្ខេបពីជ្រុងនីមួយៗនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដល់ សិក្ខាកាមដោយភ្ជាប់ ជាមួយនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីឱ្យសិក្ខាកាមអាចកំណត់លក្ខខណ្ឌ សន្ទស្សន៍នៃវិស័យ អាទិភាពក្នុងមូលដ្ឋានខេត្តរបស់ខ្លួនស្របទៅតាមយុទ្ធសាស្ត្រចតុកោណ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៤ (ទោះបីយ៉ាងណា សិក្ខាកាមអាចលើកវិស័យអាទិភាពផ្សេងទៀតបានទោះមាន ឬមិនមានក្នុងកម្មវិធី នយោបាយរបស់រាជរដ្ឋាភិបាលក្តី)។

**ជាងនេះទៅទៀត វាគ្មិន/អ្នកសម្របសម្រួលត្រូវពន្យល់ឱ្យបានច្បាស់ នឹងស៊ីជម្រៅពីរបៀបកំណត់លក្ខខណ្ឌសន្ទស្សន៍ដែលមានសូចនាករច្បាស់លាស់ដល់សិក្ខាកាមដោយត្រូវលើកឧទាហរណ៍ច្បាស់លាស់ ជាក់ស្តែង ដែលទាក់ទងនឹងខេត្តដែលធ្វើសិក្ខាសាលា (ចង់បានអ្វី? ចំនួនប៉ុន្មាន? របៀបណា? គុណភាព? ពេលណា? ទីកន្លែងណា?)**

ជ្រុងនៃយុទ្ធសាស្ត្រចតុកោណរួមមានជ្រុងទី **១) ការលើកស្ទួយវិស័យកសិកម្ម** (ការលើកកម្ពស់ផលិតភាព និងពិពិធភាវូនីយកម្មកសិកម្ម, កំណែទម្រង់ជលផល, កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន, កំណែទម្រង់ ព្រៃឈើ) **២) ការបន្តស្តារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** (ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍, ការអភិវឌ្ឍវិស័យថាមពល, ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ, ការអភិវឌ្ឍបច្ចេកវិទ្យា ព័ត៌មាន គមនាគមន៍) **៣) ការអភិវឌ្ឍវិស័យឯកជន និងការងារ** (ការពង្រឹងវិស័យឯកជននិងការទាក់ទាញ វិនិយោគ, ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម, ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរ, ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម) **៤) ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស** (វិស័យអប់រំ និងសុខាភិបាល/(ការពង្រឹងវិស័យគុណភាពអប់រំ, ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ, ការលើកកម្ពស់ សេវាសុខាភិបាល, ការអនុវត្តគោលនយោបាយជាតិប្រជាជន)) និង **៥)** ចំនុច **ស្នូល និងបរិស្ថានគ្របដណ្តប់ យុទ្ធសាស្ត្រចតុកោណៈ** អភិបាលកិច្ចល្អ (ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ, កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, កំណែទម្រង់រដ្ឋបាលសាធារណៈ, កំណែទម្រង់កងប្រដាប់អាវុធ) និង (សន្តិភាព ស្ថិរភាពនយោបាយសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម, សមាហរណកម្មកម្ពុជានៅក្នុងតំបន់ និងពិភពលោក, ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ, បរិស្ថានម៉ាក្រូ សេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ)។(**រយៈពេល សរុប ៣០ នាទី**)

- **ការបែងចែកក្រុមៈ** ក្រុមពិភាក្សាត្រូវបានបែងចែកពេលចុះឈ្មោះ នៅពេលដែលសិក្ខាកាមរើសយកលេខ ក្រុមដែលខ្លួនចង់ពិភាក្សា (លេខក្រុមទី **១ ដល់ ៥** ដែលតំណាងឱ្យក្រុមពិភាក្សានីមួយៗ ទៅតាមយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២)។ អ្នកសម្របសម្រួលនឹងពន្យល់ដល់សិក្ខាកាមពីការពិភាក្សាក្នុង ក្រុម។ ក្រុមពិភាក្សាត្រូវបានកំណត់ជា៥ក្រុមស្របទៅតាមជ្រុងទាំង៤ និងចំនុចស្នូល និងបរិស្ថានគ្របដណ្តប់ យុទ្ធសាស្ត្រចតុកោណ។

ក្រុមពិភាក្សានីមួយៗត្រូវមានសិក្ខាកាមមកពីស្រុកផ្សេងៗគ្នា។ ហើយចំនួនសមាជិកត្រូវនៅចន្លោះពី ១០ ទៅ ២០ នាក់ក្នុងមួយក្រុមដោយផ្តល់អាទិភាពទៅលើវិស័យដែលសិក្ខាកាមចង់ពិភាក្សាៈ ពេលចុះឈ្មោះត្រូវមានតារាង ប្រាប់ពីតំបន់ដែលសិក្ខាកាមមក ហើយសិក្ខាកាមត្រូវឱ្យជ្រើសរើសលេខក្រុមដែលតំណាងឱ្យយុទ្ធសាស្ត្រចតុកោណ ដែលសិក្ខាកាមចង់ពិភាក្សា (សិក្ខាកាមមួយរូបអាចចូលបានក្រុមពិភាក្សាមួយប៉ុណ្ណោះ។ បន្ទាប់មក អ្នករៀបចំ ត្រូវកំណត់សមាជិកក្នុងក្រុមពិភាក្សាទៅតាមលក្ខណៈដូចខាងលើ តែចំនួនសមាជិកក្នុងក្រុមអាចនឹងមិនស្មើគ្នា។ អ្នករៀបចំក្រុមពិភាក្សាត្រូវធ្វើយ៉ាងណាឱ្យមានក្រុមពិភាក្សាចំនួន ៥ក្រុម។ ក្នុងករណីនេះ លេខក្នុងមួយក្រុមៗ (លេខ១, លេខ ២....,លេខ ៥ មានមិនលើសពី ២០ សន្លឹកនោះទេ)។ នៅពេលបែងចែកក្រុមពិភាក្សា អ្នកសម្រប សម្រួលនឹងប្រកាសឱ្យសិក្ខាកាមចូលក្នុងក្រុមដែលខ្លួនបានចាប់លេខពេលចុះឈ្មោះ។

- **ការពិភាក្សាក្នុងក្រុមៈ** តំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងខេត្តដែលមានការយល់ដឹង និងមានការ ពន្យល់ជាមុនពីជ្រុងនៃចតុកោណនីមួយៗ វិធីសាស្ត្រសិក្ខាសាលា នឹងក្លាយជាអ្នកសម្របសម្រួលក្នុងក្រុមរបស់ខ្លួន កំពុងពិភាក្សា។ អ្នកសម្របសម្រួលក្នុងក្រុមពិភាក្សានឹងត្រូវបានពន្យល់ពីគោលការណ៍នៃការពិភាក្សាក្នុងក្រុម វិធីសាស្ត្រសិក្ខាសាលា កម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណ និងគំរូនៃវិស័យអាទិភាពដែល មានសូចនាករ ច្បាស់លាស់ដើម្បីធានាភាពរលូន និងបន្ថែមគំនិតនៃការពិភាក្សាក្នុងក្រុម។ ក្នុងន័យនេះ ឯកសារទាក់ទងនឹងសិក្ខា សាលាទាំងអស់រួមមាន វិធីសាស្ត្រសិក្ខាសាលា កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរាជរដ្ឋាភិបាលនីតិកាល ទី ៤ គោលការណ៍ណែនាំសម្រាប់សម្របសម្រួលតាមក្រុមពិភាក្សានឹងត្រូវចែកដល់អ្នកសម្របសម្រួលក្នុងក្រុម ជាមុន ហើយការពិភាក្សារវាងក្រុមការងារស្នាក់ការកណ្តាលខុមហ្វ្រែល និងអ្នកសម្របសម្រួលក្នុងក្រុមពិភាក្សា នឹងត្រូវធ្វើឡើងមុនពេលថ្ងៃសិក្ខាសាលាចាប់ផ្តើម។

អ្នកសម្របសម្រួលក្នុងក្រុមត្រូវចេះបំផុសសំណួរ និងឱ្យសមាជិកក្រុមទាំងអស់ចូលរួមក្នុងពេលកំពុងពិភាក្សា។ ក្រុមនីមួយៗត្រូវកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពចំនួន៥ ដែលមានន័យថារកឱ្យឃើញសូចនាករ សម្រាប់វាស់វែងច្បាស់លាស់ និងវាស់វែងបាន (**ចង់បាន អ្វី នៅពេលណា ទីកន្លែងណា ចំនួនប៉ុន្មាន គុណភាពយ៉ាងណា របៀបណា**) ដែលចាំបាច់សម្រាប់ខេត្តរបស់ខ្លួន។ លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ទាំង៥នេះ ត្រូវស្ថិតក្នុងយុទ្ធសាស្ត្រចតុកោណដែលក្រុមរបស់ខ្លួនកំពុងពិភាក្សា។

ជាលទ្ធផលនឹងមានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពច្រើនបំផុតត្រឹមចំនួន២៥ ដែលប្រជាពលរដ្ឋយល់ថាចាំបាច់ សម្រាប់មណ្ឌល (ខេត្ត) របស់ខ្លួន។ លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពពិភាក្សាក្នុងក្រុមនីមួយៗ នឹងត្រូវយក មកបង្ហាញនៅក្នុងអង្គសិក្ខាសាលាទាំងមូលដើម្បីជ្រើសរើសលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពចំនួនតែ ១០ ប៉ុណ្ណោះ ដើម្បីបញ្ជូនទៅកាន់មន្ត្រីជាប់ឆ្នោត (តំណាងរាស្ត្រក្នុងខេត្ត សមាជិករាជរដ្ឋាភិបាល ក្រុមប្រឹក្សា/គណៈ អភិបាលខេត្ត-រាជធានី និងស្ថាប័នពាក់ព័ន្ធនានា)។

- **បទបង្ហាញរបស់ក្រុមនីមួយៗក្នុងអង្គសិក្ខាសាលា:** បន្ទាប់ពីការពិភាក្សាក្នុងក្រុមនីមួយៗ តំណាងក្រុម នីមួយៗត្រូវធ្វើបទបង្ហាញពីវិស័យអាទិភាពក្នុងក្រុមរបស់ខ្លួនទៅកាន់អង្គសិក្ខាសាលាទាំងមូល។ ក្រុមដែលមក បង្ហាញត្រូវមានសមាសភាព ១) អ្នកបង្ហាញ/អ្នកនិយាយ ២) អ្នកសម្របសម្រួលក្រុម និង៣) អ្នកជំនួយ សម្រាប់ការបង្ហាញ។ ដូចនេះ ក្រុមនីមួយៗពេលមកបង្ហាញត្រូវមានគ្នា ៣នាក់ ដើម្បីជួយគ្នា នៅពេលមានសំណួរ ចោទឡើង។ ក្នុងបទបង្ហាញតាមក្រុមនីមួយៗ អង្គសិក្ខាសាលាទាំងមូលអាចចោទជាសំនួរបាន។ លើសពីនេះទៅទៀត អង្គសិក្ខាសាលាទាំងមូលអាចស្នើធ្វើការកែប្រែទៅលើចំនុចនីមួយៗរបស់ក្រុមដែលកំពុងតែបង្ហាញ ក៏ប៉ុន្តែ ការកែប្រែនោះមិនត្រូវប៉ះពាល់ដល់អ្វីដែលក្រុមដើមចង់បាននោះឡើយ លើកលែងតែចំនួន និងទីកន្លែង។ ឧទាហរណ៍ ក្រុមទី ១ បានលើកឡើងថា "ត្រូវកសាងផ្លូវថ្នល់មានក្រាលកៅស៊ូភ្ជាប់ពីស្រុក "ក" ទៅស្រុក "ខ" ឱ្យហើយត្រឹមបំណាច់ឆ្នាំ ២០១០"។ អង្គសិក្ខាសាលាអាចស្នើបន្ថែមទៅជា "ត្រូវកសាងផ្លូវថ្នល់មានក្រាល កៅស៊ូភ្ជាប់ពីស្រុក "ក" ទៅស្រុក "ខ" **និងភ្ជាប់ពីស្រុក "ខ" មកកាន់ក្រុង "គ"** ឱ្យហើយត្រឹមបំណាច់ឆ្នាំ ២០១០"។ (មួយក្រុម ១០នាទី រួមទាំង បទបង្ហាញ សំណួរ និងការពិភាក្សា x ៥ = **៥០ នាទី**)។

- **ការជ្រើសរើសវិស័យអាទិភាពទាំង ១០:** (ក្រុមការងារនឹងវាយបញ្ចូលវិស័យអាទិភាពទាំងអស់ ក្នុងកុំព្យូទ័រ ហើយព្រីនឯកសារទាំងនោះចេញជា ១០ច្បាប់ ដើម្បីសម្រួលដល់ការជ្រើសរើស និងការការបោះឆ្នោត ជ្រើសរើសលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពចំនួន១០): បន្ទាប់ពីក្រុមទាំងអស់បានបង្ហាញពីវិស័យអាទិភាព ក្នុងក្រុមរបស់ខ្លួនរួចហើយ ក្រុមការងារនឹងព្រីនវិស័យអាទិភាពទាំង២៥ ហើយបិទដាក់ ១០ កន្លែង/ជួរ ក្បែរៗគ្នា (កន្លែង /ជួរនីមួយៗមានការត្រួតពិនិត្យពីអ្នកសម្របសម្រួលក្រុមពិភាក្សាដើម្បីធានាថា សិក្ខាកាមយល់ពីវិធីគូស និងគូស មិនលើសពីចំនួនកំណត់។ ដូចនេះ អ្នកសម្របសម្រួលក្នុងក្រុមម្នាក់ៗត្រូវត្រួតពិនិត្យពីរជួរ)។ សិក្ខាកាម អាចចូលជួរណាក៏បាន។ សិក្ខាកាមទាំងអស់ត្រូវធ្វើការជ្រើសរើសលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពយ៉ាងច្រើន បំផុតចំនួន១០ ក្នុងចំណោម ២៥ តាមរយៈការគូសសញ្ញា (| → ┌...) នៅពីក្រោយវិស័យអាទិភាពនីមួយៗ។

ជារួម វិធីសាស្ត្រនៃការជ្រើសរើសត្រូវធ្វើដូចតទៅ: ១) វិស័យអាទិភាព ទាំង២៥ នឹងត្រូវបង្ហាញតាមអេក្រង់ អិលស៊ីឌី ២) ដើម្បីសម្រួលសិក្ខាកាមដល់ការជ្រើសរើសលក្ខខណ្ឌ សន្ទស្សន៍នៃវិស័យអាទិភាពនេះ អ្នករៀបចំនឹង រៀបចំឱ្យមាន ១០ទីកន្លែង/ជួរ សម្រាប់ឱ្យសិក្ខាកាមជ្រើសរើស /គូសលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ដោយកន្លែង/ជួរនីមួយៗមានបិទ និងបង្ហាញពីលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង២៥ផងដែរ ហើយឱ្យ សិក្ខាកាមគូស (| → ┌...) នៅពីក្រោយវិស័យអាទិភាពនីមួយៗ (គូសជាប់គ្នាឱ្យបាន ៥ជារាងការេ ហើយទើបចាប់ផ្តើមគូសថ្មីទៀត)។ ៣) ដើម្បីបញ្ជាក់ថា សិក្ខាកាមមិនគូសលើសពីចំនួនកំណត់ អ្នកសម្របសម្រួល ក្នុងក្រុមពិភាក្សានឹងត្រូវនៅក្បែរកន្លែង/ជួរដែលត្រូវគូសដើម្បីផ្ទៀងផ្ទាត់ និងពិនិត្យថាការគូសរបស់សិក្ខាកាម មិនខុសទីកន្លែង ឬលក្ខណៈបច្ចេកទេសតម្រូវឱ្យ (អ្នកសម្របសម្រួលក្នុងក្រុមត្រូវពិនិត្យមើល ២ ជួរ)។

៤) បន្ទាប់ ពីការជ្រើសរើសរួចហើយ ក្រុមការងារនឹងបូកសរុបលទ្ធផលពិន្ទុ ហើយរើសយកលក្ខខណ្ឌសន្ទស្សន៍ នៃវិស័យ អាទិភាព ចំនួន ១០ ដែលមានសម្លេងច្រើនជាងគេ។

- **ការបោះឆ្នោតសម្រេចយកលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០:** បន្ទាប់ពីបានកំណត់លក្ខខណ្ឌ សន្ទស្សន៍នៃវិស័យអាទិភាពទាំង១០បានហើយ អ្នករៀបចំនឹងបង្ហាញតែលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ទាំង១០ប៉ុណ្ណោះ នៅលើ អេក្រង់អិលស៊ីឌី ហើយឱ្យសិក្ខាកាមបោះឆ្នោតលើកដៃផ្ដល់សេចក្ដីសម្រេចថា ទទួលយក លក្ខខណ្ឌសន្ទស្សន៍នៃវិស័យ អាទិភាពទាំង១០ ដែលបានជ្រើសរើសឬអត់ ដោយកំណត់សម្លេងច្រើនដាច់ខាត (៥០%+១) នៃចំនួនសិក្ខាកាមដែលកំពុងមាន វត្តមាន។ ក្នុងករណីពុំបានទទួលសម្លេង ៥០%+១ ទេ នោះដំណើរការជ្រើសរើសតាមក្រុមនឹងត្រូវធ្វើឡើងវិញ និងអនុវត្តតាម នីតិវិធីដដែល។

- **ករណីពិសេសដែលលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពលើសពី ១០ ហើយមានសម្លេងស្មើគ្នា** (ឧទាហរណ៍ វិស័យទីចុងក្រោយ ១០, ១១, ១២ មានសម្លេង ៤០ ដូចគ្នា): ក្នុងករណីនេះ វិស័យអាទិភាពដែល មានសម្លេងស្មើគ្នានេះក៏នឹង ត្រូវដាក់បង្ហាញដល់សិក្ខាកាមទាំងមូលដែរ។ ក៏ប៉ុន្តែ វិស័យអាទិភាពចុងក្រោយ ដែលមានសម្លេងស្មើគ្នានេះនឹងត្រូវបោះឆ្នោត ដោយសិក្ខាកាមទាំងមូលហើយកំណត់យកតែមួយប៉ុណ្ណោះ។ បន្ទាប់មកគឺមានវិស័យអាទិភាពចំនួន ១០ ហើយធ្វើការបោះឆ្នោត ដូចចំនុច "**ការបោះឆ្នោតសម្រេចយកលក្ខខណ្ឌ សន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០" (រយៈពេល ១៥ នាទី)**។

- **ការប្រកាស និងចែកលទ្ធផល:** បន្ទាប់ពីការបោះឆ្នោតរួចរាល់ហើយ អ្នកសម្របសម្រួលត្រូវបង្ហាញ លក្ខខណ្ឌសន្ទស្សន៍ នៃវិស័យអាទិភាពទាំង១០ ដែលអង្គសិក្ខាសាលាទាំងមូលយល់ថាចាំបាច់សម្រាប់ខេត្តរបស់ ខ្លួន។ លក្ខខណ្ឌសន្ទស្សន៍ទាំង ១០ ដែលបានបោះឆ្នោតជ្រើសរើសរួចហើយនឹងត្រូវព្រីនចេញចែកជូនសិក្ខាកាម នីមួយៗ ដើម្បីទុកជាឯកសារសម្រាប់ឱ្យពួកគាត់ តាមដានពីអ្វីដែលពួកគាត់ចង់បាន។ (**រយៈពេល ៣០ នាទី** យូរដោយសារការព្រីន តែក្នុងចន្លោះពេលនេះគឺអាចមានការសម្រាក ពិសារអាហារសម្រន់ និងការបំពេញសំណួរ ក្រោយសិក្ខាសាលា) ហើយពេលចូលពីការសម្រាកវិញគឺត្រូវប្រមូលបញ្ជីសំណួរ។

- **ការបិទសិក្ខាសាលា:** ដើម្បីឱ្យមានការចូលរួមពីតំណាងរាស្ត្រក្នុងមណ្ឌលនៅក្នុងសិក្ខាសាលានេះ ខុមហ្វ្រែល នឹងអញ្ជើញតំណាងរាស្ត្រមកពីគ្រប់គណបក្សនយោបាយដែលមានអាសនៈក្នុងមណ្ឌលនោះមកថ្លែងពី ចំណាប់អារម្មណ៍ចំពោះ លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងមណ្ឌលរបស់ខ្លួន។ ជាមួយគ្នានេះ អ្នកសម្របសម្រួល និងថ្លែងបិទដោយរំលឹក ដល់សិក្ខាកាមពីការតាមដាន និងជម្រុញឱ្យមន្ត្រីជាប់ឆ្នោតអនុវត្ត លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០។

## ២. ទីកន្លែងសិក្ខាសាលា និងពេលវេលា

សិក្ខាសាលានេះនឹងធ្វើឡើងនៅទីរួមខេត្ត (ក្រុង) រាជធានី។ ដោយយោងថាសិក្ខាកាមមកពីតំបន់ផ្សេងៗនៃខេត្ត ពេលវេលានឹងធ្វើឡើងចន្លោះពីម៉ោង ៨.៣០ ព្រឹក ទៅ ៣.០០ រសៀល ដោយមានការផ្ដល់ជូនអាហារថ្ងៃត្រង់។

## ៣. អ្នកចូលរួម

ចំនួនសិក្ខាកាមចូលរួមត្រូវកំណត់ចន្លោះពី **៧០ ទៅ ១០០ នាក់** ហើយដែល ជាពលរដ្ឋរស់នៅក្នុងតំបន់ផ្សេងៗក្នុងខេត្តដែលជាអ្នកបោះឆ្នោតកន្លងមក ហើយមានលទ្ធភាពអានអក្សរខ្មែរបាន។ អ្នកចូលរួមត្រូវមកពីចម្រុះវិស័យៈ កសិកម្ម, វិស័យឯកជន, វិស័យអប់រំ, វិស័យសុខាភិបាល, វិស័យហេដ្ឋា រចនាសម្ព័ន្ធ/សាងសង់...)។ លក្ខណៈវិនិច្ឆ័យផ្សេងទៀតរបស់សិក្ខាកាមរួមមានៈ

- មកពី ឬជាតំណាងឱ្យសហគមន៍នានា (កសិកម្ម ជលផល បរិស្ថាន ព្រៃឈើ ក្រុមជួយខ្លួនឯង...) អ្នកស្ម័គ្រចិត្តភូមិ ឬអង្គការនៅមូលដ្ឋាននានា, អ្នកទំនាក់ទំនងស្រុក/សកម្មជនឃុំ ខុមហ្វ្រែល (តម្រូវ យ៉ាងហោចណាស់ឱ្យបាន **៧៥%** នៃចំនួនសិក្ខាកាម ហើយមកពីគ្រប់សហគមន៍ និងពីតំបន់នានាក្នុងខេត្ត)
- បុគ្គលិក អ្នកធ្វើការ ឬតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល សមាគម ធ្វើការលើវិស័យផ្សេងៗដែលមានមូលដ្ឋាននៅតំបន់នានាក្នុងខេត្ត-រាជធានីធ្វើសិក្ខាសាលា
- មកពី ឬតំណាងឱ្យវិស័យឯកជនក្នុងខេត្ត អ្នកជំនួញ ឬអ្នករកស៊ី លក់ដូរ
- បុគ្គលិករាជការៈ សាស្ត្រាចារ្យ គ្រូបង្រៀន ពេទ្យ...
- សិស្ស ឬនិស្សិត កម្មករ កសិករ...

## ៤. ការផ្សព្វផ្សាយរបាយការណ៍ស្តីពីលទ្ធផលដល់តំណាងរាស្ត្រ គណបក្សនយោបាយ និងសាធារណជន

បន្ទាប់ពីសិក្ខាសាលាត្រូវបានបញ្ចប់ ខុមហ្វ្រែលនឹងសរសេរបាយការណ៍ស្តីពីលទ្ធផលនៃសិក្ខាសាលា ដោយបង្ហាញពីលក្ខខណ្ឌ សន្ទស្សន៍នៃវិស័យអាទិភាពដែលប្រជាពលរដ្ឋក្នុងខេត្តចង់បានក្នុង នីតិកាលទី៤នេះ។ របាយការណ៍នេះនឹងផ្សព្វផ្សាយដល់ប្រព័ន្ធផ្សព្វផ្សាយ ដាក់ជូនសមាជិករដ្ឋសភា/គណបក្ស នយោបាយជាប់ឆ្នោតក្នុងខេត្ត សមាជិករាជរដ្ឋាភិបាល និងគណៈអភិបាលខេត្ត-រាជធានី ក្រុមប្រឹក្សាខេត្ត-រាជធានី។ ជាងនេះទៅទៀត ខុមហ្វ្រែលនឹងខិតខំរកវិធីជួបជាមួយតំណាងរាស្ត្រទាំងអស់ប្រចាំមណ្ឌលដែលធ្វើសិក្ខាសាលាដើម្បីឱ្យខុមហ្វ្រែល និងតំណាងសិក្ខាកាមពន្យល់ និងបង្ហាញឱ្យបានពិស្តារថែមទៀតពីលទ្ធផលនៃសិក្ខាសាលា។ ខុមហ្វ្រែលក៏នឹងស្នើសុំជួបជាមួយគណបក្សនយោបាយតាមមណ្ឌលដែលមានអាសនៈសភា ក្នុងមណ្ឌលដើម្បីរាយការណ៍ជូន និងផ្តល់លទ្ធផល។

## ៥. ការតាមដាន

បន្ទាប់ពីធ្វើសិក្ខាសាលានេះហើយ នៅឆ្នាំបន្ទាប់ខុមហ្វ្រែលនឹងធ្វើវេទិកាម្ចាស់ឆ្នោត ដោយអញ្ជើញសិក្ខាកាមដដែលឱ្យចូលរួម វាយតម្លៃតាមរយៈការឱ្យពិន្ទុទៅលើការសម្រេចបាន របស់មន្ត្រីជាប់ឆ្នោតទៅលើលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ដែលសិក្ខាកាមក្នុងខេត្ត-រាជធានី បានស្នើ/កំណត់។

## ៦. ការពិភាក្សាតាមរយៈកម្មវិធីវិទ្យុ

ខុមហ្វ្រែលនឹងរៀបចំការពិភាក្សាផ្សាយតាមវិទ្យុជាមួយ អ្នកជំនាញនៃវិស័យនីមួយៗ និងតំណាងអង្គការសង្គមស៊ីវិលក្នុងការវាយតម្លៃលើការសម្រេចលើកម្មវិធី នយោបាយក្នុងវិស័យនីមួយៗ។

## ឧបសម្ព័ន្ធ គ: អង្គការ សមាគម សហការជាមួយខុមហ្វ្រែលរៀបចំសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពតាមខេត្ត-រាជធានី

| ល.រ | កាលបរិច្ឆេទ | ខេត្ត-រាជធានី | អង្គការ និងសមាគម សហការ |
|---|---|---|---|
| ១. | ០៨-មេសា-២០០៩ | កំពង់ស្ពឺ | |
| ២. | ២៩-មេសា-២០០៩ | កំពត | អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព, ក្រុមប្រឹក្សាយុវជនកម្ពុជា, មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា, សមាគមធាងត្នោត |
| ៣. | ២០-ឧសភា-២០០៩ | កោះកុង | អង្គការសង្គ្រោះសត្វព្រៃ, អង្គការម៉ារីស្តុប |
| ៤. | ២៧-ឧសភា-២០០៩ | មណ្ឌលគិរី | អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព, មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ |
| ៥. | ០២-មិថុនា-២០០៩ | ស្វាយរៀង | អង្គការសហការដើម្បីអភិវឌ្ឍនៅកម្ពុជា, អង្គការជំនួយជនបទ, មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍, បណ្តាញតស៊ូមតិខេត្តស្វាយរៀង |
| ៦. | ១១-មិថុនា-២០០៩ | រតនគិរី | អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព, មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ |
| ៧. | ១៧-មិថុនា-២០០៩ | កំពង់ធំ | អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា, សមាគមអាដហុក, អង្គការលីកាដូ, អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារជនបទ, អង្គការទ្រទ្រង់ស្ត្រីខ្មែរ |
| ៨. | ១៥-កក្កដា-២០០៩ | ប៉ៃលិន | សមាគមអាដហុក និងអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ |
| ៩. | ១៧-កក្កដា-២០០៩ | បាត់ដំបង | សមាគមអាដហុក |
| ១០. | ២២-កក្កដា-២០០៩ | តាកែវ | សមាគមអាដហុក, អង្គការពន្លឺសង្គម, សមាគមយុវជនខ្មែរ និងក្រុមប្រឹក្សាយុវជនកម្ពុជា |
| ១១. | ២៧-កក្កដា-២០០៩ | សៀមរាប | សមាគមអាដហុក, អង្គការសហការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា |
| ១២. | ១៨-សីហា-២០០៩ | កំពង់ចាម | សមាគមអាដហុក |

| | | | |
|---|---|---|---|
| ១៣. | ២៤-សីហា-២០០៩ | កែប | សមាគមអាដហុក, ក្រុមប្រឹក្សាយុវជនកម្ពុជា, សម្ព័ន្ធការពារធនធានធម្មជាតិ, សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស |
| ១៤. | ២៨-សីហា-២០០៩ | ក្រចេះ | អង្គការអាដហុក, អង្គការសហការដើម្បីការអភិវឌ្ឍនៅកម្ពុជា |
| ១៥. | ០៩-កញ្ញា-២០០៩ | កំពង់ឆ្នាំង | សមាគមអាដហុក, អង្គការការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម, សមាគមអភិវឌ្ឍន៍កុមារយុវជន, សមាគមភ្នំនាងកង្រី, អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ |
| ១៦. | ១៥-កញ្ញា-២០០៩ | ព្រៃវែង | អង្គការសហការដើម្បីអភិវឌ្ឍនៅកម្ពុជា, សមាគមអាដហុក, អង្គការពន្លឺនៃក្តីសង្ឃឹម, អង្គការអតីតយុទ្ធជនអន្តរជាតិ, គណៈកម្មាធិការអព្យាក្រិតដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា |
| ១៧. | ០២-តុលា-២០០៩ | ពោធិ៍សាត់ | អង្គការក្សាការពារសិទ្ធិមនុស្សនៃកម្ពុជា, សមាគមអាដហុក, សមាគមអភិវឌ្ឍន៍ពុទ្ធសាសនា, សមាគមទ្រទ្រង់កសិករជនបទខេត្ត, លីកាដូ |
| ១៨. | ១៣-តុលា-២០០៩ | ឧត្តរមានជ័យ | សមាគមអាដហុក, ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍, សហគមន៍អភិវឌ្ឍន៍កុមារ, អង្គការសមារហណកម្មអភិវឌ្ឍន៍សហគមន៍, សម្ព័ន្ធសិទ្ធិមនុស្ស និងសុខភាពកម្ពុជា |
| ១៩. | ១៦-តុលា-២០០៩ | ព្រះវិហារ | សមាគមអាដហុក, គណៈកម្មាធិការអព្យាក្រិតដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា, អង្គការអភិវឌ្ឍន៍ទៅលើធនធានមនុស្ស និងព្រៃឈើ |
| ២០. | ៣០-តុលា-២០០៩ | ព្រះសីហនុ | សមាគមអាដហុក |
| ២១. | ១១-វិច្ឆិកា-២០០៩ | ភ្នំពេញ | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍, សមាគមយុវជនខ្មែរ, អង្គការសហការដើម្បីការអភិវឌ្ឍន៍នៅកម្ពុជា, អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព, មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ |
| ២២. | ១៣-វិច្ឆិកា-២០០៩ | កណ្តាល | សមាគមអាដហុក, អង្គការប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ, ការិតាស់ |
| ២៣. | ១៨-វិច្ឆិកា-២០០៩ | បន្ទាយមានជ័យ | សមាគមអាដហុក |
| ២៤. | ២៧-វិច្ឆិកា-២០០៩ | ស្ទឹងត្រែង | អង្គការការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម, សមាគមអាដហុក |

**ឧបត្ថម្ភដោយ**

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា (ខុមហ្វ្រែល)**

**ចក្ខុវិស័យ**

សង្គមប្រជាធិបតេយ្យមួយដែលដំណើរការប្រជាធិបតេយ្យហូបនីយកម្ម ជាពិសេសរាល់ការបោះឆ្នោតតាមលក្ខណៈប្រជាធិបតេយ្យត្រូវបានលើកតំកើង និងមានគុណភាពដែលនាំមកនូវផលប្រយោជន៍ជូនដល់ប្រជាពលរដ្ឋ។

**អស័យដ្ឋាន**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ ០២៣ ៨៨៣ ៧៥០

អ៊ីម៉េល: comfrel@comfrel.org, comfrel@online.com.kh គេហទំព័រ: www.comfrel.org